ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង

# FACTORS INFLUENCING STUDENTS' ATTITUDES TOWARDS TICHNICAL EDUCATION AT UPPER SECONDARY SCHOOL IN SVAY RIENG PROVINCE


ដោយ/By

**គង់ បូរ៉ា**

**KONG BORA**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

## ឆ្នាំសិក្សា ២០២១-២០២៣

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង

# FACTORS INFLUENCING STUDENTS' ATTITUDES TOWARDS TICHNICAL EDUCATION AT UPPER SECONDARY SCHOOL IN SVAY RIENG PROVINCE

ដោយ/By

**គង់ បូរ៉ា**

KONG BORA

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

**គ្រូណែនាំបង្គោល ៖ បណ្ឌិត អាន វ៉ុប្រាថ**

**គ្រូណែនាំរង ៖ បណ្ឌិត ទី សុផល**

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ហើយស្នាដៃនេះពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រ នៅសាកលវិទ្យាល័យ ឬនៅវិទ្យាស្ថាននានា ដែលមានសញ្ញាបត្រស្មើឡើយ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារមួយណាដែលត្រូវបានប្រើប្រាស់នៅក្នុងការសរសេរអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឬចុះក្នុងបញ្ជីឯកសារយោងឡើយ ។

និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងឡើងដោយខ្ញុំបាទផ្ទាល់ប្រាកដមែន ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ភ្នំពេញថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣

**ហត្ថលេខាបេក្ខជន**



**គង់ ម៉ូរ៉ា**

# លិខិតបញ្ជាក់

លោកបណ្ឌិត **អាន វ៉ុប្រាជ** ជាគ្រូណែនាំបង្គោល

លោកបណ្ឌិត **ទី សុផល** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **គង់ មូរ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ ថា «**កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង** » ពិតប្រាកដមែន។

ថ្ងៃ ព្រហស្បតិ៍ ៨កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០២៣

| | |
|---|---|
| **បណ្ឌិត អាន វ៉ុប្រាជ** | **បណ្ឌិត ទី សុផល** |
| អនុប្រធានដេប៉ាតឺម៉ង់ | គ្រូឧទ្ទេសផ្នែកប្រវត្តិវិទ្យា |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៤៣២អយក.ឧចក

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំៈ

| ល.រ | គោត្តនាម-នាម គ្រូណែនាំគោល | គោត្តនាម-នាម គ្រូណែនាំរង | គោត្តនាម-នាម និស្សិត |
|---|---|---|---|
| ១ | បណ្ឌិត នៀ សុផន | បណ្ឌិត សៀង សុវណ្ណា | កង សុផារ៉ាមី |
| ២ | បណ្ឌិត នី វដ្ឋា | បណ្ឌិត ទី សុផល | កន កុល |
| ៣ | បណ្ឌិត អាន វ៉ូប្រាវ | បណ្ឌិត ទី សុផល | គង់ បូរ៉ា |
| ៤ | បណ្ឌិត ឌី ខាំបូលី | បណ្ឌិត កាន់ ពុទ្ធី | គុយ វដ្ឋា |
| ៥ | បណ្ឌិត ម៉ម ចាន់សៀន | បណ្ឌិត ប៊ិច សៀង | គៅ លឹមហ៊ាត់ |
| ៦ | បណ្ឌិត ឡឹយ សុខគា | បណ្ឌិត គួយ សូគាន | ជុំ ជឿន |
| ៧ | លោក លឹម វ៉ាន់ | បណ្ឌិត គួយ សូគាន | ឈឹម ឌីនគោ |
| ៨ | បណ្ឌិត សៀង សុវណ្ណា | បណ្ឌិត នៀ សុផន | ញឹក កិត្យា |
| ៩ | លោកស្រី នូ ចន្ទី | បណ្ឌិត ឈាង សង្វាត | ទៀន រតនៈ |
| ១០ | បណ្ឌិត ឈាង សង្វាត | លោក ម៉ន មុនិន្ទ | ធឿន វដ្ឋា |
| ១១ | បណ្ឌិត នៀ សុផន | បណ្ឌិត សៀង សុវណ្ណា | ពុំ សុធីតាមុនី |
| ១២ | បណ្ឌិត អ៊ឹម គឿន | បណ្ឌិត សោម វណ្ណៈ | ពៅ ស្រីម៉ៅ |
| ១៣ | បណ្ឌិត នូវ វីរ៉ា | បណ្ឌិត នៀ សុផន | ព្រុំ ណារិន |
| ១៤ | បណ្ឌិត អ៊ឹម គឿន | បណ្ឌិត នី វដ្ឋា | ម៉ុល មួយគា |
| ១៥ | បណ្ឌិត នូវ វីរ៉ា | លោក ចាប រតនា | ម៉ោញ សុជាវត្ត |
| ១៦ | លោកស្រី ប៊ុន សុផានី | លោក ថៃ ហេង | មឿន ផល្លា |

| | | | |
|---|---|---|---|
| ១៧ | បណ្ឌិត លី គិមឡុង | លោក ចាន់ វ៉ាដា | យ៉ម វុទ្ធី |
| ១៨ | លោក ឡុច ចាន់ថន | បណ្ឌិត បូ ច័ន្ទគុលិកា | យឹម ធារ៉ា |
| ១៩ | បណ្ឌិត សិត សេង | បណ្ឌិត អាន វ៉ូប្រាវ | លី សុផា |
| ២០ | បណ្ឌិត គួយ សូគាន | បណ្ឌិត នី វឌ្ឍា | សឹម ភក្តី |
| ២១ | លោក ចាន់ ធឿន | បណ្ឌិត ឈន ថន | សួង គឹមសាន |
| ២២ | បណ្ឌិត ឈន ថន | បណ្ឌិត សោន វណ្ណៈ | សេន ម៉ៅ |
| ២៣ | បណ្ឌិត សិត សេង | បណ្ឌិត នូវ វីរ៉ា | សែម ជ្រាន |
| ២៤ | បណ្ឌិត លី គិមឡុង | បណ្ឌិត ឌី ខាំបូលី | សោ សុផាត |
| ២៥ | បណ្ឌិត អាន វ៉ូប្រាវ | លោក ឡុច ចាន់ថន | ហ៊ីង សុវណ្ណា |
| ២៦ | លោក ចាប រតនា | បណ្ឌិត ម៉ម ចាន់សៀន | ហឿន សារ៉ុត |
| ២៧ | បណ្ឌិត សោន វណ្ណៈ | លោក ប៉ូ ប៊ុន្នួន | អ៊ិន ផល្លាក់ |
| ២៨ | លោក ចាន់ វ៉ាដា | បណ្ឌិត សិត សេង | អ៊ាង ប៊ុនរឿង |
| ២៩ | បណ្ឌិត មាឃ ចាន់ថេង | បណ្ឌិត លី គិមឡុង | អូន ពិសី |
| ៣០ | បណ្ឌិត ឡឹម សុខគា | បណ្ឌិត ឈន ថន | អៀក ចន្ទី |
| ៣១ | បណ្ឌិត ម៉ម ចាន់សៀន | លោក ចាប រតនា | វ៉ា សុភ័ក្ត្រា |
| ៣២ | បណ្ឌិត ជ័យ សារិន | បណ្ឌិត ឡឹម សុខគា | មៀច បូរ៉ា |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៥ កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វដអ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ ៤៥០១ អយក.ខ៩ន

(ការសម្រាត់)

## លិខិតឧទ្ទេសនាម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **គង់ ម៉ូរ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០២១ - ២០២៣ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានបញ្ចប់ការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ជាមួយលទ្ធផលដ៏ត្រចេះត្រចង់នេះ ខ្ញុំបាទក៏មិនភ្លេចផងដែរ ចំពោះការជួយជ្រោមជ្រែង គាំទ្រ និងយកចិត្តទុកដាក់ពីមជ្ឈដ្ឋានជាច្រើន។ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកអ្នកមានគុណទាំងពីរគឺលោកឪពុក **គង់ សេង** និងអ្នកម្តាយ **ខង សំអុល** ដែលបានផ្តល់កំណើត ផ្តល់ដំបូន្មានល្អៗ ខិតខំចិញ្ចឹមបីបាច់ថែរក្សា និងតស៊ូផ្គត់ផ្គង់ឱ្យកូនបានសិក្សា រហូតទទួលបានផ្លែផ្កាដូចសព្វថ្ងៃនេះ។

- ភរិយា **ទេព សុវណ្ណារ៉ា** និងកូនជាទីស្រឡាញ់ ដែលបានផ្តល់ពេលវេលា កម្លាំងចិត្ត និងថវិកាក្នុងការសិក្សារៀនសូត្រ។

- ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំ ផ្តល់អាហារូបករណ៍ និងផ្តល់ឱកាសដល់រូបខ្ញុំបានចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំ នាពេលកន្លងមក។

- គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់ខ្ញុំទាំងអស់គ្នាដោយមិនគិតពីការលំបាកនឿយហត់ ។

- លោកបណ្ឌិត **អាន វីរប្រាជ** ជាគ្រូណែនាំបង្គោល ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីណែនាំ ពន្យល់ និងផ្តល់អនុសាសន៍ល្អៗ ដល់រូបខ្ញុំតាំងពីដើមរហូតមក ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទបានទទួលជោគជ័យនៅពេលនេះ ។

- លោកបណ្ឌិត **ទី សុផល** ដែលជាគ្រូណែនាំរង ដែលតែងតែឆ្លាតពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់ជាអនុសាសន៍ល្អៗ កែសម្រួលពាក្យពេជន៍ ឃ្លាប្រយោគ អក្ខរាវិរុទ្ធ និងរបៀបសរសេរនិក្ខេបបទ ព្រមទាំងរបៀបវិភាគទិន្នន័យ។

- លោកគ្រូ អ្នកគ្រូដែលបានបង្រៀនខ្ញុំបាទចាប់តាំងពីបឋមសិក្សារហូតបរិញ្ញាបត្រជាន់ខ្ពស់ ។

- មិត្តភ័ក្តទាំងអស់ ក៏ដូចជាមិត្តរួមថ្នាក់ជំនាន់ទី១០ ទាំងអស់ដែលតែងផ្តល់កម្លាំងចិត្ត និងចែករំលែកឯកសារ ចំណេះដឹង បទពិសោធន៍ និងព័ត៌មានល្អៗ ដល់រូបខ្ញុំ ។

-គណៈគ្រងគ្រងសាលាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបារិត ក៏ដូចជាលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ដែលបានជួយបំពេញកម្រងសំណួរដល់រូបខ្ញុំបាទ ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យជូនចំពោះ លោកឪពុក អ្នកម្តាយ ភរិយា និងកូនជាទីស្រលាញ់ ឯកឧត្តម សាស្ត្រាចារ្យ លោក លោកស្រីទាំងអស់សូមជួបប្រទះតែ សេចក្តីសុខ សេចក្តីចម្រើនគ្រប់ប្រការ មានសុខភាពមាំមួន សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធិពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មាតិកា


**សេចក្តីអះអាងរបស់បេក្ខជន** ........................................ ii

**លិខិតបញ្ជាក់** ........................................ iii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........................................ iv

**សេចក្តីថ្លែងអំណរគុណ** ........................................ viii

**បញ្ជីតារាង** ........................................ xiv

**បញ្ជីរូបភាព** ........................................ xviii

**មូលន័យសង្ខេប** ........................................ xix

Abstract ........................................ xx

**ជំពូកទី១៖ សេចក្តីផ្តើម** ........................................ 1

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ........................................ 7

១.៤ សំណួរស្រាវជ្រាវ ........................................ 7

១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........................................ 7

១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................ 8

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ 8

**ជំពូកទី២៖ រំលឹកទ្រឹស្តី** ........................................ 8

**២.១ សេចក្តីផ្តើម** ........................................ 10

**២.២ ពាក្យគន្លឹះ** ........................................ 10

**២.៣ កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេស** ........................................ 15

២.៣.១ កត្តាខាងក្នុង ........................................ 15

២.៣.១.១ កត្តាភេទ ........................................ 15

២.៣.១.២ កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ........................................ 16

២.៣.១.៣ កត្តាសមត្ថភាព ........................................ 17

២.៣.១.៤ កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស ........................................ 17

២.៣.២ កត្តាខាងក្រៅ ........................................ 18

២.៣.២.១ កត្តាអាណាព្យាបាល ........................................ 18

២.៣.២.២ កត្តាគ្រូបង្រៀន ..... 19
២.៣.២.៣ កត្តាមិត្តភក្តិ..... 21
២.៣.២.៤ កត្តាថ្នាក់រៀន និងសាលារៀន ..... 21
២.៣.២.៥ កត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត ..... 22
**២.៤ បញ្ហាប្រឈម នៃការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្ស ..... 23**
២.៤.១ គុណភាពនៃការអប់រំបច្ចេកទេស មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ..... 23
២.៤.២ ការមិនសូវឲ្យតម្លៃទៅលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ..... 23
២.៤.៣ ឪកាមានកម្រិតសម្រាប់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ..... 24
២.៤.៤ ការទទួលស្គាល់ពុំទាន់ទូលំទូលាយចំពោះកម្មវិធីអប់រំបច្ចេកទេសឆ្លងប្រព័ន្ធ ..... 24
២.៤.៥ ជំនាញមូលដ្ឋាន និងជំនាញទន់នៅមានកម្រិត ..... 24
២.៤.៦ កម្រិតនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ ..... 25
២.៤.៧ កង្វះខាតការគាំទ្រទាំងសម្ភារៈសិក្សានិងធនធានឪកាសសម្រាប់សិស្ស ..... 25
២.៤.៨ កង្វះការគាំទ្រទាំងសម្ភារៈនិងធនធានឪកាសសម្រាប់សិស្ស ..... 25
**២.៥ ក្របខណ្ឌគំនិតនៃការស្រាវជ្រាវ ..... 26**
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ ..... 27**
**៣.១ គម្រោងវិភាគ ..... 27**
**៣.២ ការជ្រើសរើសសំណាក ..... 28**
**៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យ ..... 28**
៣.៣.១ កម្រងសំណួរសម្រាប់សិស្ស ..... 29
៣.៣.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន ..... 30
៣.៣.៣ កម្រងសំណួរសម្រាប់នាយក ..... 30
៣.៣.៤ កម្រិតចង្អុលបង្ហាញ ..... 31
**៣.៤ ដំណើរការនៃការប្រមូលទិន្នន័យ ..... 31**
**៣.៥ ការវិភាគទិន្នន័យ ..... 31**
**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា ..... 37**
**៤.១ លទ្ធផល ..... 37**
៤.១.១ កត្តាខាងក្នុង ..... 37
៤.១.១.១ កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស ..... 38

៤.១.១.២ កត្តាភេទ ........................................ 40

៤.១.១.៣ កត្តាអាយុ ........................................ 45

៤.១.១.៤ កត្តាសមត្ថភាព ........................................ 48

៤.១.១.៥ កត្តាតម្រូវការការសិក្សា និងការងារ ........................................ 53

៤.១.២ កត្តាខាងក្រៅ ........................................ 58

៤.១.២.១ កត្តាអាណាព្យាបាលរបស់សិស្ស ........................................ 59

៤.១.២.២ កត្តាមិត្តភ័ក្ត ........................................ 63

៤.១.២.៣ កត្តាគ្រូបង្រៀន ........................................ 66

៤.១.២.៤ កត្តាថ្នាក់រៀន និងសាលារៀន ........................................ 71

៤.១.២.៥ កត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត ........................................ 79

៤.១.៣ លទ្ធផលរួមនៃកត្តាខាង ........................................ 82

៤.១.៤ លទ្ធផលរួមកត្តាខាងក្រៅ ........................................ 83

៤.១.៥ លទ្ធផលរួមកត្តាខាងក្នុង និងកត្តាខាងក្រៅ ........................................ 83

**៤.២ បញ្ហាប្រឈម** ........................................ 84

៤.២.១ ប្រព័ន្ធផ្សព្វផ្សាយរបស់សាលា ........................................ 84

៤.២.២ ឥទ្ធិពលគ្រូបង្រៀន ........................................ 85

៤.២.៣ ធនធានហិរញ្ញវត្ថុរបស់សាលា ........................................ 86

៤.២.៤ កត្តាសេដ្ឋកិច្ចគ្រួសារ ........................................ 87

៤.២.៥ ឥទ្ធិពលអាណាព្យាបាលសិស្ស ........................................ 87

៤.២.៦ ការរើសអើងពីមជ្ឍដ្ឋានជុំវិញ ........................................ 88

៤.២.៧ ឥទ្ធិពលការងារពេលអនាគត ........................................ 89

៤.២.៨ លទ្ធផលរួមនៃគោលគំនិត្យលើបញ្ហាប្រឈម ........................................ 89

**៤.៣ ដំណោះស្រាយនៃបញ្ហាប្រឈម** ........................................ 91

៤.៣.១ រៀបចំផែនការចុះផ្សព្វផ្សាយ ........................................ 91

៤.៣.២ ផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា ........................................ 92

៤.៣.៣ ផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្ស ........................................ 93

៤.៣.៤ លទ្ធផលរួមនៃដំណោះស្រាយលើបញ្ហាប្រឈម ........................................ 94

**៤.៤ ការពិភាក្សា** ........................................ 94

៤.៤.១ កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេស .........95
៤.៣.១.១ សំណួរស្រាវជ្រាវទី១ ....................................................................................95
៤.៣.១.២ សំណួរស្រាវជ្រាវទី២ ....................................................................................97
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ......................................................................99
**៥.១ សេចក្តីសន្និដ្ឋាន** ................................................................................................99
**៥.២ សំណូមពរ** .......................................................................................................100
១. គណៈគ្រប់គ្រងសាលារៀន ..........................................................................................100
២. ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ............................................................................................................ 101
៣. ក្រសួងអប់រំ យុវជន និងកីឡា ................................................................................. 101
៤. អ្នកស្រាវជ្រាវបន្ត ................................................................................................. 101
ឯកសារពិគ្រោះ............................................................................................................102
**ឧបសម្ព័ន្ធ “ក”** កម្រងសំណួរ ....................................................................................104
កម្រងសំណួរសម្រាប់សិស្ស .........................................................................................104
កម្រងសំណួរសម្រាប់គ្រូបង្រៀន ..................................................................................... 110
កម្រងសំណួរសម្រាប់លោកនាយក/នាយករង ........................................................................116
**ឧបសម្ព័ន្ធ “ខ”៖** លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ.......................................................122

# បញ្ជីតារាង


តារាងទី១.១៖ ប្រៀបធៀបស្ថិតិសិស្សមធ្យមសិក្សាទុតិយភូមិចំណោះទូទៅ ឆ្នាំសិក្សា២០២០-២០២ និង ឆ្នាំសិក្សា២០២១-២០២២ .......... 4

តារាងទី១.២៖ ស្ថិតិសិស្សវិទ្យាល័យចំណោះទូទៅ និងបច្ចេកទេសប្រៀបធៀបឆ្នាំសិក្សា ២០២០-២០២១ និងឆ្នាំសិក្សា២០២១-២០២២.......... 5

តារាងទី២.១៖ របាយមុខវិជ្ជា និងម៉ោងសិក្សាឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣.......... 13

តារាងទី៣.១៖ ចំនួនសំណាកត្រូវចុះប្រមូលទិន្នន័យ .......... 28

តារាងទី៣.២៖ ចំនួនអ្នកបានចូលរួមផ្តល់ព័ត៌មាន.......... 33

តារាងទី៣.៣៖ កម្រិតវប្បធម៌ ម្តាយ និងឪពុករបស់សិស្ស.......... 34

តារាងទី៣.៤៖ ប្រាក់ចំណូលជាមធ្យមរបស់ឪពុកម្តាយរបស់សិស្ស .......... 34

តារាងទី៣.៥៖ អាយុរបស់គ្រូបង្រៀន និងនាយកសាលា.......... 35

តារាងទី៣.៦៖ កម្រិតវប្បធម៌គ្រូបង្រៀន និងនាយកសាលា.......... 35

តារាងទី៣.៧៖ កម្រិតបណ្តុះបណ្តាលរបស់លោកគ្រូអ្នកគ្រូ និងនាយកសាលា .......... 36

តារាងទី៣.៨៖ កម្រិតថ្នាក់ដែលលោកគ្រូ អ្នកគ្រូកំពុងបង្រៀន.......... 36

តារាងទី៣.៩៖ មុខវិជ្ជាបង្រៀនរបស់លោកគ្រូអ្នកគ្រូ .......... 37

តារាងទី៤.១៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន .......... 38

តារាងទី៤.២៖ ការយល់ឃើញរបស់គ្រូបង្រៀន ចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស.......... 39

តារាងទី៤.៣៖ ការយល់ឃើញរបស់នាយកសាលា ចំពោះចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស.......... 39

តារាងទី៤.៤៖ លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកចំពោះកត្តាចំណាប់អារម្មណ៍សិស្ស.......... 40

តារាងទី៤.៥៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាភេទ .......... 41

តារាងទី៤.៦៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាភេទសិស្ស.......... 42

តារាងទី៤.៧៖ ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាភេទសិស្ស ....................................... 43
តារាងទី៤.៨៖ លទ្ធផលរួមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាចំពោះកត្តាភេទ ......................... 44
តារាងទី៤.៩៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាអាយុ ....................................................... 45
តារាងទី៤.១០៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាអាយុសិស្ស ....................................... 46
តារាងទី៤.១១៖ ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាអាយុសិស្ស ................................... 47
តារាងទី៤.១២៖ លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះកត្តាអាយុរបស់សិស្ស ............... 48
តារាងទី៤.១៣៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាសមត្ថភាព ............................................. 49
តារាងទី៤.១៤៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះសិស្សលើកត្តាសមត្ថភាពសិស្ស ..................... 50
តារាងទី៤.១៥៖ ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាសមត្ថភាពសិស្ស ............................ 51
តារាងទី៤.១៦៖ លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះកត្តាសមត្ថភាពសិស្ស ............... 52
តារាងទី៤.១៧៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស .... 53
តារាងទី៤.១៨៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស
របស់សិស្ស ...................................................................................................................... 54
តារាងទី៤.១៩៖ ការយល់ឃើញរបស់នាយកសាលា ចំពោះកត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេក
ទេសរបស់សិស្ស ................................................................................................................ 56
តារាងទី៤.២០៖ លទ្ធផលរួមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាចំពោះកត្តាតម្រូវការការសិក្សា និង
ការអប់រំបច្ចេកទេសរបស់សិស្ស ............................................................................................ 58
តារាងទី៤.២១៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាអាណាព្យាបាល ....................................... 59
តារាងទី៤.២២៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាអាណាព្យាបាល ................................ 60
តារាងទី៤.២៣៖ ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាអាណាព្យាបាល ............................ 61
តារាងទី៤.២៤៖ លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកចំពោះកត្តាអាណាព្យាបាលសិស្ស ................. 62
តារាងទី៤.២៥៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាមិត្តភ័ក្ត ..................................................... 63

តារាងទី៤.២៦៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាមិត្តភ័ក្តរបស់សិស្ស ........................... 64
តារាងទី៤.២៧៖ ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាមិត្តភ័ក្តរបស់សិស្ស ........................ 65
តារាងទី៤.២៨៖ លទ្ធផលរួមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាចំពោះកត្តាមិត្តភ័ក្តសិស្ស ........ 66
តារាងទី៤.២៩៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាគ្រូបង្រៀន ............................................ 66
តារាងទី៤.៣០៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាគ្រូបង្រៀន......................................... 68
តារាងទី៤.៣១៖ ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាគ្រូបង្រៀន .................................. 69
តារាងទី៤.៣២៖ លទ្ធផលរួមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាចំពោះកត្តាគ្រូបង្រៀន ........... 70
តារាងទី៤.៣៣៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាថ្នាក់រៀន និងសាលារៀន........................... 71
តារាងទី៤.៣៤៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាថ្នាក់រៀន និងសាលារៀន ...................... 73
តារាងទី៤.៣៥៖ ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាថ្នាក់រៀន និងសាលារៀន ................. 76
តារាងទី៤.៣៦៖ លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកចំពោះកត្តាថ្នាក់រៀន និងសាលារៀន............. 78
តារាងទី៤.៣៧៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាអាជីព និងសក្តានុពលការងារពេលអនាគត ... 79
តារាងទី៤.៣៨៖ ការយល់ឃើញរបស់គ្រូចំពោះកត្តាអាជីព និងសក្តានុពលការងារពេលអនាគត ....... 80
តារាងទី៤.៣៩៖ ការយល់ឃើញរបស់នាយកចំពោះកត្តាអាជីព និងសក្តានុពលការងារពេលអនាគត....... 81
តារាងទី៤.៤០៖ លទ្ធផលរួមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាចំពោះកត្តាអាជីព និងសក្តានុពលការងារពេលអនាគត ........................................................................................... 81
តារាងទី៤.៤១៖ លទ្ធផលរួមកត្តាខាងក្នុងនៃការយល់ឃើញរវាងសិស្ស គ្រូ និងនាយកសាលា ............ 82
តារាងទី៤.៤២៖ លទ្ធផលរួមកត្តាខាងក្រៅនៃការយល់ឃើញរវាងសិស្ស គ្រូ និងនាយក ................... 83
តារាងទី៤.៤៣៖ លទ្ធផលរួមរវាងកត្តាខាងក្នុង និងកត្តាខាងក្រៅនៃការយល់ឃើញរវាងសិស្ស គ្រូបង្រៀន និងនាយកសាលា............................................................................................... 83
តារាងទី៤.៤៤៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកសាលាលើប្រព័ន្ធផ្សព្វផ្សាយរបស់សាលា....... 84
តារាងទី៤.៤៥៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះឥទ្ធិពលគ្រូបង្រៀន ................ 85

តារាងទី៤.៤៦៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកចំពោះធនធានហិរញ្ញវត្ថុរបស់សាលា............86
តារាងទី៤.៤៧៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះកត្តាសេដ្ឋកិច្ចគ្រួសារ..............87
តារាងទី៤.៤៨៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកចំពោះឥទ្ធិពលអាណាព្យាបាលសិស្ស...........87
តារាងទី៤.៤៩៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកចំពោះការរើសអើងពីមជ្ឈដ្ឋានជុំវិញ.............88
តារាងទី៤.៥០៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកចំពោះឥទ្ធិពលការងារពេលអនាគត.............89
តារាងទី៤.៥១៖ លទ្ធផលរួមនៃគោលគំនិត្យលើបញ្ហាប្រឈម .....................................................89
តារាងទី៤.៥២៖ ដំណោះស្រាយក្នុងការរៀបចំផែនការចុះផ្សព្វផ្សាយ............................................. 91
តារាងទី៤.៥៣៖ ដំណោះស្រាយក្នុងការផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា.....................................92
តារាងទី៤.៥៤៖ ដំណោះស្រាយក្នុងការផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្ស ..............................93
តារាងទី៤.៥៥៖ លទ្ធផលរួមនៃដំណោះស្រាយលើបញ្ហាប្រឈម..................................................94

# បញ្ជីរូបភាព

រូបភាពទី២.១៖ ការបង្កើតប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស ............................................ 14

រូបភាពទី២.២៖ កត្តាជះឥទ្ធិពលលើអាកប្បកិរិយាសិស្ស........................................................... 26

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងពីរ៖ ១.ដើម្បីកំណត់កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេស និង ២.ដើម្បីកំណត់បញ្ហាប្រឈម និងដំណោះស្រាយនៃការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្ស។ វិធីសាស្ត្រស្រាវជ្រាវនេះគឺអនុវត្តតាមបែបបរិមាណវិស័យ ដោយអ្នកស្រាវជ្រាវចងក្រងជាសំណួរទម្រង់បិទតាមលំដាប់លំដោយ និងទម្រង់បើកដើម្បីទទួលបានព័ត៌មានបន្ថែមសម្រាប់គាំទ្រចម្លើយមួយចំនួនឱ្យបានជាក់លាក់។ ដោយសារតែក្នុងខេត្តស្វាយរៀងមានវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេសតែមួយ ដូចនេះភាគសំណាកក្នុងការសិក្សានេះគឺ ជ្រើសរើសសាលាវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេសបារិតសម្រាប់ធ្វើការស្រាវជ្រាវ។ ក្នុងសាលានេះមានសិស្សអប់រំបច្ចេកទេសចំនួន១៣៤នាក់ គ្រូបង្រៀនអប់រំបច្ចេកទេសចំនួន២០នាក់ និងគណៈគ្រប់គ្រងសាលា០៣នាក់។ ការវិភាគទិន្នន័យតាមកម្មវិធី Ms.Excel និងការបកស្រាយទិន្នន័យគិតជាភាគរយ(%)។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានឆ្លើយតបទៅនឹងគោលបំណងទី១៖ កត្តាដែលមានឥទ្ធិពលទៅលើអាកប្បកិរិយារបស់សិស្សមានពីរកត្តាធំៗគឺកត្តាខាងក្នុង និងកត្តាខាងក្រៅ ដែលកត្តាខាងក្នុងមានភាគរយខ្ពស់ជាងកត្តាខាងក្រៅ។ កត្តាខាងក្នុងមានការយល់ស្របជាវិជ្ជមានចំនួន៦២%។ កត្តាខាងក្រៅមានការយល់ស្របជាវិជ្ជមានចំនួន៥៥%។ លទ្ធផលឆ្លើយតបទៅនឹងគោលបំណងទី២៖ សិស្សចំនួន១៥% គ្រូបង្រៀន១៨% និងគណៈគ្រប់គ្រងសាលាចំនួន៣៨% ដែលបានលើកឡើងថាសាលាមានបញ្ហាប្រឈមរួមចំនួន០៧សំខាន់ៗមានប្រព័ន្ធផ្សព្វផ្សាយ, គ្រូបង្រៀន, ធនធានហិរញ្ញវត្ថុ, សេដ្ឋកិច្ចគ្រួសារ, អាណាព្យាបាលសិស្ស, ការរើសអើងពីមជ្ឈដ្ឋានជុំវិញ, ការងារពេលអនាគត។ ដំណោះស្រាយរួម៖ សិស្សមានចំនួន៣៥% គ្រូ៨៥% និងគណៈគ្រប់គ្រងសាលាចំនួន៩៨% បានលើកឡើងថាសាលាត្រូវមានការរៀបចំផែនការចុះផ្សព្វផ្សាយ, ផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា, ប្រឹក្សាអាជីព និងតម្រង់ទិសសិស្ស។

សំណូមពរដល់គណៈគ្រប់គ្រងសាលា និងលោកគ្រូអ្នកគ្រូគួរតែរៀបចំផែនការ ឬរកវិធីសាស្ត្រយ៉ាងណាដើម្បីធ្វើឱ្យអ្នកសិក្សាក៏ដូចជាអ្នកមានឥទ្ធិពលលើអ្នកសិក្សាមានអាកប្បកិរិយាវិជ្ជមាន និងចាប់អារម្មណ៍ជ្រើសរើសជំនាញអប់រំបច្ចេកទេសនេះ។ សុំការសហការពីភាគីពាក់ព័ន្ធបន្តការផ្សព្វផ្សាយ ជំរុញនិងលើកទឹកចិត្តដល់អ្នកសិក្សាមកចាប់អារម្មណ៍ជ្រើសរើសការអប់រំបច្ចេកទេសនេះឱ្យបានទូលំទូលាយ។

## Abstract

This research study has two objectives: 1. To identify the factors that influence students' attitudes toward technical education and 2. To identify the challenges and solutions of students' choice of technical education. This research method is applied quantitatively by the researcher, compiling the questions in closed, sequential and open forms to obtain additional information to support certain answers. Because there is only one general education and technical education high school in Svay Rieng province, the sample in this study is to select Bavet Technical General Education and Technical High School for research. In this school, there are 134 technical education students, 20 technical education teachers and 3 school management. Ms.Excel data analysis and interpretation of data as a percentage (%).

The results of this study respond to Objective 1: The factors that influence student behavior are two major factors: internal factors and external factors, in which the internal factors have a higher percentage than the external factors. Internal factors were 62% positive. External factors were 55% positive. Results Respond to Objective 2: 15% of students, 18% of teachers and 38% of the school management who mentioned that the school has 7 main common challenges: media, teachers, financial resources, family economy, Guardians of students, discrimination from the environment, future work. For the joint solution have, 35% of the students, 85% of the teachers and 98% of the school management said that the school needs to have a plan to promote, provide benefits to students, career counseling and student orientation.

Suggestions to the school management and teachers should plan or find ways to make students as well as influencers have a positive attitude and interested in choosing this technical education skills. Seek cooperation from stakeholders to continue promoting And encourage students to take an interest in the wide range of technical education options.

# ជំពូកទី១

## សេចក្តីផ្តើម

### ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាមានមហិច្ឆតាក្នុងការផ្លាស់ប្តូរពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ហើយបន្តក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ដូចនេះរាជរដ្ឋាភិបាលចាំបាច់ត្រូវអភិវឌ្ឍជំនាញបច្ចេកទេសដល់យុវជន ដើម្បីបង្កើនឱកាសការងារជំនាញដល់យុវជន ក្នុងការប្រកួតប្រជែងសេដ្ឋកិច្ចនៅពេលប្រទេសកម្ពុជាចូលជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងខែធ្នូ ឆ្នាំ២០១៥ (ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ(២០១៥-២០១៩))។ ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសនេះ ត្រូវបានរៀបចំឡើងដើម្បីអប់រំពលរដ្ឋកម្ពុជាឱ្យក្លាយទៅជាពលរដ្ឋពេញលេញ តាមរយៈការធ្វើឱ្យកម្មវិធីសិក្សាមានលក្ខណៈស្តង់ដាអន្តរជាតិទាំងខ្លឹមសារ វិធីសាស្ត្របង្រៀន និងរៀន ព្រមទាំងវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងគោលបំណងធ្វើឱ្យសមត្ថភាពសិស្សឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅកម្រិតជាតិ តំបន់ និងពិភពលោក(ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស, ២០១៥)។

ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺជាកត្តាមិនអាចខ្វះបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងជំរុញឲ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេសជាមួយសមត្ថភាពពិតប្រាកដដើម្បីក្លាយខ្លួនជាពលករជំនាញ អ្នកបច្ចេកទេស ព្រមទាំងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិធំៗមួយចំនួនដែលក្នុងនោះរួមមាន "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥" និង "គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥" ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងបង្កើតការងារសមរម្យ ព្រមទាំងធានាគុណភាព និងផលិតភាព ដើម្បីចូលរួមសម្រេចខ្ពស់របស់កម្លាំងពលកម្មដែលអាចប្រកួតប្រជែងប្រសើរជាងមុនជាមួយបណ្តាប្រទេសក្នុងតំបន់ (គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

សមាហរណកម្មអាស៊ាននៅចុងឆ្នាំ២០១៥ កម្ពុជាអាចប្រកួតប្រជែងកម្លាំងពលកម្មទីផ្សារការងារតាមរយៈការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET)។ ការអប់រំបច្ចេកទេសមានតួនាទីសំខាន់ដែលគួរឲ្យកត់សម្គាល់ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរក្នុងវិស័យពលកម្មការងារនៅប្រទេសកម្ពុជា។ តាមបរិបទដែលបានលើកឡើងខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអប់រំបច្ចេកទេស ដើម្បីផ្តល់ឲ្យយុវជននូវជំនាញបច្ចេកទេសស្របតាមតម្រូវការទីផ្សារ(ផែនការគោល(២០១៥-២០១៩))។ បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA) ក្នុងអភិវឌ្ឍផែនការគោលសម្រាប់ការអប់រំបច្ចេកទេស កម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេស និងសៀវភៅសិក្សាគោលផ្នែកអប់រំបច្ចេកទេសលើ០៥ ជំនាញ៖ មេកានិច អគ្គិសនី អេឡិចត្រូនិច កសិកម្ម និង គណនេយ្យ សម្រាប់អនុវត្តនៅមធ្យមសិក្សាទុតិយភូមិ។ ម៉្យាងវិញទៀតក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗ និងសកម្មភាពការងារអប់រំបច្ចេកទេស ដោយផ្តោតការយកចិត្តទុកដាក់ជាចម្បងលើការងារតម្រង់ទិសវិជ្ជាជីវៈ កម្មវិធីអប់រំបំណិនជីវិត កម្មវិធីស្ពានចម្លង ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការប្រឹក្សាអាជីព សម្រាប់សិស្សមធ្យមសិក្សា ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការផ្តល់នូវបំណិន និងជំនាញបច្ចេកទេសវិជ្ជាជីវៈ ដល់សិស្សងាយស្រួលរកការងារដែលមានប្រាក់កម្រៃខ្ពស់ អាចដោះស្រាយបញ្ហាសេដ្ឋកិច្ចគ្រួសារ សង្គម និងបន្តការសិក្សាពេញមួយជីវិត។ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកំណែទម្រង់៨ចំណុច ក្រសួងអប់រំ យុវជន និងកីឡា បានបំបែកអាទិភាពទាំងនេះ ជាការង្ហានកំណែទម្រង់ចំនួន១៥ចំណុច ដែលក្នុងចំណោមកំណែទម្រង់ទាំង១៥ចំណុចនោះ មានកំណែទម្រង់មួយ គឺកំណែទម្រង់ទី១៣៖ ដែលលើកឡើងទាក់ទងនឹងការអប់រំបច្ចេកទេស (ផែនការគោល (២០១៥-២០១៩))។

នៅក្នុងអាស៊ាន ការអភិវឌ្ឍជំនាញមានការរីកចម្រើនយ៉ាងឆាប់រហ័សដោយសារមានការយល់ឃើញថាវាជាកត្តាមួយដ៏ចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច។ ការផ្លាស់ប្តូរត្រូវបានគាំទ្រតាមរយៈគោលនយោបាយក្នុងការអភិវឌ្ឍជំនាញដែលជាទូទៅផ្អែកលើតម្រូវការ និងបានដាក់បញ្ចូលទៅគ្រប់ក្រសួងព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលផ្តល់ការបណ្តុះបណ្តាល។ នៅតាមបណ្តាប្រទេសមួយចំនួន

ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានពង្រីកនឹងក្លាយជាអាជ្ញាធរ ឬ ភ្នាក់ងារឯករាជ្យក្នុងរដ្ឋាភិបាល ព្រមទាំងបានបង្កើតស្តង់ដាសម្រាប់វិស័យអាទិភាពមួយចំនួន មិនមែនត្រឹមតែបច្ចេកវិទ្យានោះទេ ប៉ុន្តែសម្រាប់វិស័យសុខាភិបាល និងជំនាញអាជីវកម្ម ជាពិសេសជំនាញដែលផ្អែកលើប្រព័ន្ធកុំព្យូទ័រផងដែរ។ អាស៊ាន ក៏មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រឲ្យមានស្តង់ដាជំនាញក្នុងតំបន់រួមគ្នា ហើយអត្ថប្រយោជន៍ទាំងនេះត្រូវបានមើលឃើញថាមាននៅក្នុងផ្នែកបដិសណ្ឋារកិច្ច ក៏ដូចជាអាជីវកម្មតាមបែបប្រពៃណីផងដែរ(គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវ (២០១៧-២០២៥))។

ទាំងអស់នេះគឺជាបញ្ហាដែលអ្នកសិក្សាស្រាវជ្រាវលើកឡើងមកដើម្បីឱ្យមានភាពប្រទាក់ក្រឡាគ្នាជាមួយនឹងប្រធានបទដែលកំពុងធ្វើការសិក្សាស្រាវជ្រាវនេះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការអប់រំបច្ចេកទេសនៅតាមសាលាមធ្យមសិក្សាទុតិយភូមិ នៅតែបន្តទទួលបានការចាប់អារម្មណ៍យកចិត្តទុកដាក់តិចតួច ព្រោះសាធារណជនយល់ថា ការអប់រំបច្ចេកទេស និងការងារបច្ចេកទេសគឺស្ថិតក្នុងលំដាប់ទី២ ហើយយុវជនភាគច្រើនចង់បន្តការសិក្សានៅសាកលវិទ្យាល័យ ដើម្បីទទួលបានការងារល្អ។ ការយល់ដឹងរបស់សាធារណជនទូទៅអំពីការអប់រំបច្ចេកទេស នៅមានកម្រិតទាប ហើយមានកត្តាជះឥទ្ធិពលចំនួនពីរគឺ៖ **កត្តាខាងក្នុង** (ឥទ្ធិពលភេទ, ឥទ្ធិពលអាយុ, ឥទ្ធិពលចំណាប់អារម្មណ៍ផ្ទាល់ខ្លួន, ឥទ្ធិពលសមត្ថភាព, ឥទ្ធិពលតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស) **និងកត្តាខាងក្រៅ**(ឥទ្ធិពលអាណាព្យាបាល, ឥទ្ធិពលគ្រូបង្រៀន, ឥទ្ធិពលមិត្តភ័ក្តិ, ឥទ្ធិពលថ្នាក់រៀន និងសាលារៀន, ឥទ្ធិពលអាជីព និងសក្តានុពលពេលអនាគត)។ ការអប់រំបច្ចេកទេសក៏ត្រូវបានគេយល់ឃើញផងដែរថាពុំមានភាពសមស្របសម្រាប់សិស្សស្រី ព្រោះថាវគ្គសិក្សាជាច្រើនផ្តោតលើជំនាញដូចជា អគ្គិសនី អេឡិចត្រូនិក មេកានិច និងវិស្វកម្មស៊ីវិល បសុព្យាបាល ក្សេត្រសាស្ត្រ និងសំណង់ ដែលសុទ្ធតែជាការងារដែលត្រូវប្រើកម្លាំងខ្លាំង និងជាការងារនៅខាងក្រៅដែលពេលខ្លះត្រូវធ្វើនៅក្នុងស្ថានភាពប្រកបដោយគ្រោះថ្នាក់។ ការយល់ឃើញមិនត្រឹមត្រូវទាំងនេះ ព្រមទាំងការយល់ឃើញដទៃទៀតពុំបាន

លើកទឹកចិត្តឱ្យយុវតីជាច្រើនពិចារណាចាប់យកការអប់រំបច្ចេកទេស និងវិជ្ជាជីវៈពាក់ព័ន្ធនោះឡើយ។

ក្រោយពីការផ្ទេរកម្មវិធី TVET ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅឆ្នាំ ២០០៥ ក្រសួងអប់រំ យុវជន និង កីឡា បានបង្កើតនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ដើម្បីបន្តរក្សាធាតុចូលមួយចំនួនដល់ការអប់រំបច្ចេកទេសនៅតាមសាលាមធ្យមសិក្សា ប៉ុន្តែនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈមានការលំបាកនៅក្នុងការទទួលបានថវិកាគាំទ្រឱ្យបានគ្រប់គ្រាន់ ដោយហេតុថា ហេដ្ឋារចនាសម្ព័ន្ធបរិក្ខារ ការបណ្តុះបណ្តាល ការថែទាំជួសជុល ផ្លាស់ប្តូរបរិក្ខារចាស់ៗ ត្រូវការចំណាយខ្ពស់។ ក្រៅពីនេះមិនសូវមានការសម្របសម្រួលដោយនាយកដ្ឋានដែលទទួលខុសត្រូវលើការអប់រំកម្រិតមធ្យមសិក្សា ក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍ និងដាក់បញ្ចូលកម្មវិធីសិក្សា គរុកោសល្យ និងធនធានដែលឆ្លើយតបនឹងតម្រូវការទីផ្សារការងារ។ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ផ្នែកមួយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ គឺផ្តោតសំខាន់លើកកម្ពស់ការរួមចំណែកកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការពង្រឹងធនធានមនុស្ស និងចាត់ទុកការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិជាអាទិភាព( ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជា, ២០៣០ )។

តារាងទី១.១៖ ការប្រៀបធៀបស្ថិតិសិស្សមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ឆ្នាំសិក្សា២០២០-២០២ និង ឆ្នាំសិក្សា២០២១-២០២២

| បរិយាយ | ២០២០-២០២១ | ២០២១-២០២២ | កើន/ថយ(+/-) |
|---|---|---|---|
| **អនុវិទ្យាល័យ** | | | |
| សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋសរុប | 632 303 | 662 106 | +29 803 |
| សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋស្រី | 335 972 | 348 637 | +12 665 |
| សិស្សមធ្យមសិក្សាបឋមភូមិឯកជនសរុប | 36 334 | 40 899 | +4 565 |
| សិស្សមធ្យមសិក្សាបឋមភូមិឯកជនស្រី | 18 341 | 20 714 | +2 373 |
| **វិទ្យាល័យ** | | | |
| សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋសរុប | 351 794 | 360 617 | +8 823 |
| សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋស្រី | 191 973 | 196 474 | +4 501 |
| សិស្សមធ្យមសិក្សាទុតិយភូមិឯកជនសរុប | 24 898 | 25 171 | +273 |
| សិស្សមធ្យមសិក្សាទុតិយភូមិឯកជនស្រី | 12 576 | 13 034 | +458 |

( MoEYS, 2021 )

សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋ ឆ្នាំសិក្សា ២០២០-២០២១ សរុបមានចំនួន៦៦២១០៦នាក់ ស្រី៣៤៨ ៦៣៧នាក់ និងឆ្នាំសិក្សា ២០២១-២០២២ សរុបចំនួន៦៣២ ៣០៣នាក់ ស្រី៣៣៥ ៩៧២នាក់។ សិស្សមានការកើនឡើងចំនួន២៩ ៨០៣នាក់ ស្រី១២ ៦៦៥នាក់។ សិស្សមធ្យមសិក្សាបឋមភូមិឯកជន ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន៣៦៣៣៤នាក់ ស្រី១៨៣៤១នាក់ និងឆ្នាំសិក្សា២០២១-២០២២ សរុបចំនួន៤០៨៩៩នាក់ ស្រី២០៧១៤នាក់។ សិស្សមានការកើនឡើងចំនួន២៧៣នាក់ ស្រី៤៥៨នាក់។

សិស្សមធ្យមសិក្សាទុតិយភូមិរដ្ឋឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន៣៥១ ៧៩៤នាក់ ស្រី ១៩១ ៩៧៣នាក់ និងឆ្នាំសិក្សា២០២១-២០២២ សរុបចំនួន៣៦០ ៦១៧នាក់ ស្រី១៩៦ ៤៧៤នាក់។ សិស្សមានការកើនឡើងចំនួន៨ ៨២៣នាក់ ស្រី៤ ៥០១នាក់។ សិស្សមធ្យមសិក្សាទុតិយភូមិឯកជនឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន២៤ ៨៩៨នាក់ ស្រី១២ ៥៧៦នាក់ និងឆ្នាំសិក្សា២០២១-២០២២ សរុបចំនួន២៥១៧១នាក់ ស្រី១៣០៣៤នាក់។ សិស្សមានការកើនឡើងចំនួន២៧៣នាក់ ស្រី៤៥៨នាក់។ ដូចនេះចំនួនសិស្សពីឆ្នាំសិក្សា២០១៩-២០២០ និងឆ្នាំសិក្សា២០២១-២០២២ មានការកើនឡើងទាំងសាលាចំណេះទូទៅរដ្ឋ និងសាលាចំណេះទូទៅឯកជន។

តារាងទី១.២ ៖ ស្ថិតិសិស្សវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសប្រៀបធៀបឆ្នាំសិក្សា២០២០-២០២១ និងឆ្នាំសិក្សា២០២១-២០២២

| បរិយាយ | ២០២០ - ២០២១ | | ២០២១ - ២០២២ | | កើន/ថយ(+/-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសអនុវត្តកំពង់ឈើទាលនៃវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | 593 | 295 | 533 | 188 | -60 | -107 |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន**-ROTA ខ្សាច់កណ្តាល | 376 | 41 | 403 | 57 | +27 | +16 |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** | 472 | 216 | 409 | 194 | -63 | -22 |

| | | | | | | |
|---|---|---|---|---|---|---|
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ឯកជន សន្តប្រាង់ស្វ័រ | 144 | 71 | 135 | 69 | **-9** | **-2** |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសពួក | 194 | 6 | 234 | 11 | **+40** | **+5** |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស **ហ៊ុន សែន** ជម្ពូវ័ន | 274 | 41 | 314 | 51 | **+40** | **+10** |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស បារិត | 163 | 64 | 160 | 67 | **-3** | **+3** |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស **ព្រះរាជសម្ភារ** | 92 | 22 | 106 | 28 | **+14** | **+6** |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស **ព្រះនរោត្តមសីហមុនី** | 112 | 72 | 66 | 38 | **-46** | **-34** |
| វិទ្យាល័យចំណេះទូទៅនឹងបច្ចេកទេស **ជាស៊ីម**ត្បែងមានជ័យ | 141 | 64 | 104 | 48 | **-37** | **-16** |
| សាលាចំណេះទូទៅនិងបច្ចេកទេសឯកជនអេស៊ីធី (ACT) | 58 | 37 | 74 | 46 | **+16** | **+9** |
| វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ឯកជនដុនបូស្កូប៉ោយប៉ែត | 100 | 43 | 116 | 50 | **+16** | **+7** |
| វិទ្យាស្ថានអភិវឌ្ឍន៍សហគមន៍នៃសាកលវិ.**ជាស៊ីម**កំចាយមារ | 260 | 135 | 218 | 119 | **-42** | **-16** |
| វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃសាកលវិទ្យាល័យ **ហេង សំរិន** ត្បូងឃ្មុំ | 135 | 81 | 177 | 104 | **+42** | **+23** |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស បន្ទាយផ្សារ | 24 | 0 | 39 | 15 | **+15** | **+15** |
| វិទ្យាល័យ **ហ៊ុន សែន** ពាមជីកង | 138 | 71 | 152 | 55 | **+14** | **-16** |
| វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស **តេជោសែន** កោះកុង | 48 | 10 | 42 | 2 | **-6** | **-8** |
| វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | | | 12 | 7 | **+12** | **+7** |
| **សរុប** | **3324** | **1269** | **3294** | **1149** | -30 | -120 |

(MoEYS, 2021)

តាមរយៈតារាងខាងលើ បានបង្ហាញថាសិស្សជំនាញអប់រំបច្ចេកទេសនៅមធ្យមទុតិយភូមិ ឆ្នាំសិក្សា

២០២០-២០២១ សរុបចំនួន៣ ៣២៤នាក់ ស្រី១ ២៦៩នាក់  និងឆ្នាំសិក្សា២០២១-២០២២ សរុបចំនួន៣ ២៩៤នាក់ ស្រី១ ១៤៩នាក់។ សិស្សមានការថយចុះចំនួន ៣០នាក់ ស្រី១២០នាក់។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

១. ដើម្បីកំណត់កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេស។

២.ដើម្បីកំណត់បញ្ហាប្រឈម និងដំណោះស្រាយនៃការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្ស។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវខាងលើ សំណួរស្រាវជ្រាវត្រូវបានកំណត់ដូចខាងក្រោម៖

១.តើកត្តាដែលជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសមាន លក្ខណៈដូចម្ដេច?

២.តើមានបញ្ហាប្រឈម និងដំណោះស្រាយដូចម្ដេច ចំពោះអាកប្បកិរិយាសិស្សនៃការជ្រើសរើសការអប់រំបច្ចេកទេស?

## ១.៥- សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ»**កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្ស ចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង**» ពិតជាមានសារៈសំខាន់ណាស់ ព្រោះវាបានរកឃើញនូវទំនាក់ទំនងរវាងកត្តាសំខាន់ៗដែលជះឥទ្ធិពល និងបញ្ហាផ្សេងៗដែលធ្វើឱ្យមានការរាំងស្ទះដល់ការសម្រេចចិត្តរបស់សិស្សក្នុងការជ្រើសរើសសាលាអប់រំបច្ចេកទេស ម្យ៉ាងវិញទៀតដើម្បីស្វែងយល់ពីតម្រូវការ និងការទាញចំណាប់អារម្មណ៍ពីអ្នកសិក្សា និងភាគីពាក់ព័ន្ធនានាទៅលើការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ និងស្វែងយល់ពីតួនាទី ភារកិច្ច ការវាយតម្លៃ និងស្វ័យវាយតម្លៃគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផលនៃដំណើរការដើម្បីកសាងធនធានមនុស្សឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារក្នុងប្រទេស និងក្នុងសាកលលោក និងកាន់តែធ្វើឱ្យមានការផុសផុលឡើងលើវិស័យកសាងធនធានមនុស្សផ្នែកផលិតនេះ។ លទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះ ក៏មានសារប្រយោជន៍សម្រាប់អ្នក

សិក្សាជំនាន់ក្រោយផងដែរ ដើម្បីយកទៅសិក្សា ស្រាវជ្រាវបន្ត ស្វែងរកនូវចំណុចដែលខ្វះខាត ចំណុចដែលមិនទាន់រកឃើញដើម្បីបំពេញបន្ថែមក្នុងគោលបំណងគាំទ្រ និងលើកកម្ពស់ការកសាងធនធានមនុស្សនេះ។ រួមចំណែករកឱ្យឃើញនូវចំណុចល្អ បញ្ហាប្រឈមនៃសាលារៀន សម្រាប់ផ្សព្វផ្សាយបន្ត និងធ្វើការកែតម្រូវ ក្នុងន័យស្វែងរកឧត្តមភាពនៃកត្តាសំខាន់ៗលើអាកប្បកិរិយាសិស្សចំពោះការអប់រំបច្ចេកទេស សម្រាប់ការងារកសាងធនធានមនុស្សពេញលេញផ្នែកបច្ចេកទេស ដែលជាតម្រូវការចម្បងរបស់កម្ពុជាបច្ចុប្បន្ន ដើម្បីឆ្លើយតបជាមួយគោលដៅនៃប្រទេសកម្ពុជាក្លាយជាប្រទេសផលិតនៅឆ្នាំ២០២៥ និងប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយទទួលបានជោគជ័យ គឺមានកត្តារួមផ្សំជាច្រើនក្នុងនោះដែរ ការកំណត់ពីដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវជាចំណុចដ៏សំខាន់ ដើម្បីកុំឱ្យការស្រាវជ្រាវប្រាកចាកពីប្រធានបទ ឬមិនចំគោលដៅ ហើយវិសាលភាពនៃការសិក្សាស្រាវជ្រាវគឺផ្តោតទៅលើតែផ្នែកអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀងតែប៉ុណ្ណោះ ដែលជ្រើសរើសយកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន០១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបាវិត។ ។ ខ្លឹមសារស្រាវជ្រាវនៃប្រធានបទ «**កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង**»។ ការសិក្សាស្រាវជ្រាវនេះបានជ្រើសរើសគណៈគ្រប់គ្រងសាលាចំនួន០៣នាក់ ស្រី០នាក់ គ្រូបង្រៀនអប់រំបច្ចេកទេសទាំងអស់ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣ (មុខជំនាញចំនួនបីគឺ អគ្គិសនី កេ្សត្រសាស្ត្រ និងកែច្នៃម្ហូបអាហារ) សរុប២០នាក់ ស្រី០៥ និងសិស្សផ្នែកបច្ចេកទេសចំនួន ១៥៥នាក់ ស្រី៥៥នាក់។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

**ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូកដូចខាងក្រោម៖**

**ជំពូកទី១៖** សេចក្តីផ្តើមរួមមាន លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់

នៃការស្រាវជ្រាវ  រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖** រំឭកទ្រឹស្ដី ពិនិត្យមើលឯកសារ និងការសិក្សាពីមុនៗ មានកន្លងមក ដែលបានលើក

យក  និងផ្ដោតជាសំខាន់តែទ្រឹស្ដី  ឬសេចក្ដីណែនាំដែលទាក់ទងនឹងប្រធានបទ  រួមទាំងឯកសារ នានាដែលទាក់ទងនឹងប្រធានបទតែប៉ុណ្ណោះ។

**ជំពូកទី៣៖**    រៀបរាប់អំពីវិធីសាស្ត្រស្រាវជ្រាវដែលអ្នកសិក្សាស្រាវជ្រាវបានយកមកប្រើប្រាស់ក្នុង ការសិក្សាស្រាវជ្រាវនេះ។  នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវ  បង្ហាញពីរបៀបនៃការសិក្សា  ការប្រមូលភាគ សំណាក ការប្រមូលព័ត៌មាន ការវិភាគព័ត៌មាន ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើរូបមន្តសម្រាប់គណនា និងការជ្រើសរើសវិធីសាស្ត្រនៃការប្រមូលទិន្នន័យ។

**ជំពូកទី៤៖** លទ្ធផល និងការពិភាក្សា  ក្នុងផ្នែកនេះ  អ្នកស្រាវជ្រាវលើកឡើងពីលក្ខណៈជាក់ស្ដែង ដែលខ្លួនបានធ្វើការសិក្សាស្រាវជ្រាវ រួចហើយគឺត្រូវឆ្លើយតបទៅនឹងចំណុចដែលចោទសួរនៅក្នុង ចំណោទ បញ្ហា។  ការបកស្រាយ  ត្រូវបានបកស្រាយយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវ  ដោយយោង ទៅលើលទ្ធផលនៃការស្រាវជ្រាវទ្រឹស្ដី ឬខ្លឹមសារដែលមានក្នុងកម្រងសំណួរ ។

**ជំពូកទី៥៖** សេចក្ដីសន្និដ្ឋាន  និងសំណូមពរ  ជំពូកនេះអ្នកស្រាវជ្រាវ  ត្រូវធ្វើការសង្ខេបការសិក្សា ស្រាវជ្រាវ  រួចទាញជាសេចក្ដីសន្និដ្ឋានលើចំណុចដែលបានវិភាគ  និងផ្ដល់យោបល់ឬសំណូមពរ  ទៅលើ ចំណុចដែលត្រូវដោះស្រាយ និងកែលម្អ។

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

នៅក្នុងនិក្ខេបបទនេះផ្តោតយ៉ាងសំខាន់លើកត្តាដែលជះឥទ្ធិពលដល់ការសម្រេចចិត្តនៃជ្រើសរើសមុខវិជ្ជាអប់រំបច្ចេកទេសរបស់អ្នកសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ នៅត្រង់ចំណុចរំលឹកទ្រឹស្តីនេះ អ្នកសិក្សានឹងបង្ហាញពីទ្រឹស្តីផ្សេងៗដែលមានទំនាក់ទំនងជាមួយនឹងការសិក្សាស្រាវជ្រាវ ជាពិសេសទ្រឹស្តីដែលទាក់ទងក្នុងការបង្ហាញផ្លូវ និងជួយក្នុងការសម្រេចចិត្តរើសមុខវិជ្ជាសម្រាប់សិក្សាឱ្យបានត្រឹមត្រូវ និងពាក្យគន្លឹះសំខាន់ៗ ផ្សេងៗទៀតដែលទាក់ទងនឹងនិក្ខេបបទនេះ ។ អ្នកសិក្សានឹងបង្ហាញអំពីទ្រឹស្តីមួយចំនួនទាក់ទងនឹងទ្រឹស្តីនៃជម្រើសផងដែរ។ ជាងនេះទៅទៀត អ្នកសិក្សានឹងបង្ហាញយ៉ាងលម្អិត អំពីពាក្យគន្លឹះមួយចំនួនដូចជា៖ កត្តាខាងក្នុង( កត្តាភេទ,កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន,កត្តាសមត្ថភាព,កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស) និងកត្តាខាងក្រៅ( កត្តាអាណាព្យាបាល កត្តាគ្រូបង្រៀន កត្តាមិត្តភ័ក្តិ កត្តាថ្នាក់រៀន និងសាលារៀន)។ ខាងក្រោមនេះអ្នកសិក្សានឹងបង្ហាញពីនិយមន័យនៃពាក្យគន្លឹះសំខាន់ៗ មួយចំនួនដែលទាក់ទងទៅនឹងប្រធានបទ។

## ២.២ ពាក្យគន្លឹះ

**ឥទ្ធិពល** មានន័យថា ឫទ្ធិ គឺសេចក្តីសម្រេច សេចក្តីចម្រើន ដំណើរកើតការ អានុភាព អំណាចអានុភាពដ៏សក្តិសិទ្ធិឬជាក់ស្តែង អានុភាពក្រៃលែងជាងធម្មតា កម្លាំងនៃឫទ្ធិ ដែលមានឫទ្ធិឬអ្នកមានឫទ្ធិ ( ជួន ណាត,១៩៦៨)។ការសម្រេចនូវឥទ្ធិពលនេះបានគឺជាគុណធម៌ដ៏មានតម្លៃ គឺជាជំហាននៃសេចក្តីសម្រេច សេចក្តីចម្រើនដែលផ្តើមឡើងដោយកត្តា៖**១.ឆន្ទៈ** ឬបំណងក្នុងការដឹកនាំ ការអនុវត្តការងារឆ្ពោះទៅរកភាពត្រឹមត្រូវឬសេចក្តីសម្រេចបែបណាមួយ។ **២.វិរិយៈ**ឬការព្យាយាម៖ការអនុវត្តការងារត្រូវមានសេចក្តីព្យាយាមជាចាំបាច់ទើបទទួលបានផល សេចក្តីចម្រើន ឬឥទ្ធពល។ **៣.មានចិត្តគំនិតរស់រវើក៖** មានមនសិកាក្នុងការអនុវត្តការងារ មានគំនិតច្នៃប្រឌិត មានស្មារតីសុទិដ្ឋិនិយម មានទំនាក់ទំនងល្អ ស្គាល់ពីតម្លៃ កាលៈទេសៈ មានគុណធម៌ និងការព្យាយាម។ **៤.វិមំសា៖** ការពិចារណា ល្បងមើល ពិសោធមើលប្រឡង (ជួន ណាត, ១៩៦៨)។

**កត្តាជះឥទ្ធិពល** គឺជាដំណើរការនៃការទទួលឥទ្ធិពល និងការផ្សាយនូវឥទ្ធិពលនៃការអនុវត្ត គម្រោងធ្វើឱ្យទទួលបានលទ្ធផលបែបណាមួយ។

ឥទ្ធិពលនៃគម្រោងគឺជាកំណើនចំនួនប្រជាជនដែលបានទទួលការអប់រំ និងមានជំនាញកាន់តែប្រសើរឡើងនៅក្នុងគ្រប់មជ្ឈដ្ឋានទាំងអស់នៃប្រជាជនកម្ពុជា ជាពិសេសសិស្សនារី និងសិស្សមកពីតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។ លទ្ធផលរបស់គម្រោង គឺការលើកស្ទួយគុណភាព និងសមធម៌នៃការអប់រំនៅកម្ពុជាជាមួយការអប់រំនៅមធ្យមសិក្សាឱ្យកាន់តែមានប្រសិទ្ធភាព សមត្ថភាពគ្រូបង្រៀនកាន់តែប្រសើរឡើង និងប្រព័ន្ធគ្រប់គ្រងអប់រំកាន់តែរឹងមាំ (គម្រោងលើកកម្ពស់គុណភាពអប់រំ, EEQP Brochure in Khmer)។

**អាកប្បកិរិយា** មានន័យថា ឫកពារ អាការនៃរាងកាយ,ដំណើរ ឬលំនាំនៃរាងកាយ។ ជាទូទៅអាកប្បកិរិយា ស្តែងចេញតាមរយៈ មនុស្សដែលមានឫកពារល្អ ឬអាក្រក់។ ឧទាហរណ៍៖ មនុស្សនោះមានអាកប្បកិរិយារម្យទមល្អណាស់ គួរឲ្យចង់រាប់អាន។ ចំណែកឯមនុស្សនោះវិញ មានអាកប្បកិរិយាមិនសមរម្យទេ ហើយគួរឲ្យស្អប់។ អាកប្បកិរិយា សរសេរជាភាសាអង់គ្លេស និងភាសាបារាំង(Attitude) ដែលមានន័យថា ការកំណត់របៀប ជំហរ ឬការយល់ដឹងនៃគំនិត ឬអារម្មណ៍លើអ្វីមួយ។ ឧទាហរណ៍៖ មនុស្សមានអាកប្បកិរិយាវិជ្ជមានចំពោះភាសាជាតិរបស់ខ្លួន(ក្រុមប្រឹក្សាជាតិភាសាខ្មែរ)។ ចំពោះពាក្យ«ឥរិយាបថ» សម្រាប់បង្ហាញពី ទង្វើ និងសកម្មភាពជាក់ស្តែង ដូចជា ដេក ដើរ ឈរ អង្គុយ ជាដើម។ ឧទាហរណ៍៖ ម្នាក់នោះមានឥរិយាបថមិនសមរម្យសោះ ទាំងកាយវិការ និងនិយាយស្តី (ជួន ណាត, ១៩៦៨)។ ចំណែកក្រុមប្រឹក្សាជាតិភាសាខ្មែរវិញបានពន្យល់ពាក្យ «ឥរិយាបថ» មានន័យដូចនឹងពាក្យ «បែបបទ» សំដៅលើរបៀបដែលអ្នកណាម្នាក់ប្រព្រឹត្តឬប្រតិបត្តិសម្រាប់ខ្លួនឯង និងទៅលើអ្នកដទៃ (ក្រុមប្រឹក្សាជាតិភាសាខ្មែរ)។

អាកប្បកិរិយា គឺជាការប្រមូលផ្តុំនៃព័ត៌មានអំពីវត្ថុ បុគ្គល ស្ថានភាព ឬបទពិសោធន៍ ដែលបង្កើតជាគំនិតរបស់បុគ្គលអំពី ឬទំនោរទៅរកវត្ថុនោះ (Ngogo, 2014)។ ឥរិយាបទជាការវិនិច្ឆ័យវាយតម្លៃទាំងវិជ្ជមាន ឬអវិជ្ជមាន ដែលបុគ្គលមាន និងដឹកនាំឆ្ពោះទៅរកវត្ថុអាកប្បកិរិយាមួយចំនួន ដែលអាចជាអរូបី ឬ

ជាក់ស្តែង (Elias, Smith & Barney, 2012)។ កំណត់អាកប្បកិរិយាជារបៀបដែលមនុស្សម្នាក់គិត និងមានអារម្មណ៍អំពីទង្វើឆ្ពោះទៅរកគោលបំណង និងគំនិត។ វាក៏កំណត់អាកប្បកិរិយាជាអារម្មណ៍វិជ្ជមាន ឬអវិជ្ជមានដែលបុគ្គលមានអំពីវត្ថុ មនុស្ស ឬ គំនិត។ គិតថាអាកប្បកិរិយាវិជ្ជមាន ឬអំណោយផលចំពោះការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជះឥទ្ធិពលជាវិជ្ជមានទៅលើការរៀនសូត្រ និងការអនុវត្តរបស់សិស្សនៃការអប់រំវិជ្ជាជីវៈ។ នេះគឺដោយសារតែការពិតដែលថាបុគ្គលជាធម្មតាមានភាពលំអៀងចំពោះវត្ថុអាកប្បកិរិយាទាំងនោះ ដែលពួកគេវាយតម្លៃជាវិជ្ជមាន និងប្រឆាំងនឹងអ្នកដែលវាយតម្លៃអវិជ្ជមាន (Achieng, 2012)។ ក៏បានកំណត់ចំណាប់អារម្មណ៍សាធារណៈមិនល្អ និងភាពព្រងើយកន្តើយចំពោះការអប់រំវិជ្ជា ជីវៈថាជាបញ្ហាប្រឈមមុខនឹងការអប់រំវិជ្ជាជីវៈក្នុងការសម្រេចបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងប្រទេសនីហ្សេរីយ៉ា (Oguejiofor & Ezeabasili, 2014)។

**ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ** កម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖ គឺសំដៅលើការអប់រំជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដូចជាជំនាញអគ្គិសនី ក្សេត្រសាស្ត្រ បសុវប្បកម្ម អេឡិចត្រូនិច និងមេកានិចជាដើម។ល។ ជាការអប់រំដែលធ្វើឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹងជំនាញ បំណិន ឥរិយាបថ និងគុណតម្លៃក្នុងសង្គម ឬក្លាយជាអ្នកបច្ចេកទេសកម្រិតមធ្យម ការបន្តការសិក្សាពេញមួយជីវិត និងក្លាយជាពលករជំនាញ កម្មករជំនាញ និងមានសេចក្តីថ្លៃថ្នូរ អាចប្រកបរបរគាំទ្រ និងផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃបាន ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអប់រំដែលតម្រង់ទិសរកជំនាញដែលច្បាស់លាស់តាមរយៈកម្មវិធីសិក្សាជំនាញ កម្មវិធីចុះកម្មសិក្សា កម្មវិធីទស្សនកិច្ចសិក្សា កម្មវិធីប្រឹក្សាអាជីព និងកម្មវិធីសហគ្រិនភាព។ល។

**ការអប់រំវិជ្ជាជីវៈ** រួមមានទម្រង់នៃការអប់រំណាមួយដែលមានគោលបំណងដើម្បីទទួលបានគុណវុឌ្ឍិទាក់ទងនឹងវិជ្ជាជីវៈជាក់លាក់មួយ សិល្បៈ ឬការងារ ឬដោយការផ្តល់នូវចំណេះដឹង និងជំនាញបច្ចេកទេសចាំបាច់។ ទាំងពីរនេះមានសារៈសំខាន់សម្រាប់សិស្សានុសិស្សអាចអនុវត្តវិជ្ជាជីវៈ សកម្មភាព ឬសកម្មភាពដោយឯករាជ្យទៅតាមអាយុ និងកម្រិតបណ្តុះបណ្តាលរបស់ពួកគេ ទោះបីជាកម្មវិធីបណ្តុះបណ្តាលក៏មានធាតុផ្សំនៃការអប់រំទូទៅដែរ (Mortaki, 2012)។

ការអប់រំវិជ្ជាជីវៈជាទូទៅរួមមានចំណេះដឹង អាកប្បកិរិយា ជំនាញ តម្លៃដែលនរណាម្នាក់ត្រូវតែមានដែលអាចសម្រេចបានកម្រិតសមហេតុផលនៃសមត្ថភាពក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។គោលបំណងសំខាន់នៃការអប់រំសំដៅលើការផ្តល់ជំនាញ សមត្ថភាពសមស្រប និងសមត្ថភាពផ្លូវចិត្ត និងរាងកាយជាឧបករណ៍ចាំបាច់សម្រាប់បុគ្គលម្នាក់ៗ ក្នុងការរស់នៅប្រកបដោយប្រសិទ្ធភាពក្នុងសង្គម (Okocha, 2010)។

**មធ្យមសិក្សា** ជាកម្រិតសិក្សាបន្តពីបឋមសិក្សាបឋមភូមិដែលមានកម្រិតថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ ហើយមធ្យមសិក្សានេះចែកចេញជាពីរ គឺជាកម្រិតសិក្សាមធ្យមសិក្សាបឋមភូមិដែលរាប់ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ និងមធ្យមសិក្សាទុតិយភូមិចាប់ពីថ្នាក់ទី១០ដល់ថ្នាក់ទី១២។ ការអប់រំមធ្យមសិក្សាត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញដោយពង្រីកវិសាលភាពចំណេះដឹង បំណិន ការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានលក្ខណសម្បត្តិបន្តទៅថ្នាក់បន្ទាប់ ឬបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ឬចូលរួមក្នុងជីវភាពសង្គមបានប្រសើរ (ច្បាប់អប់រំ, ២០១៧)។

តារាងទី២.១៖ របាយមុខវិជ្ជា និងម៉ោងសិក្សាឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ការអប់រំឧត្តមសិក្សា | ចំនួនក្រេឌីតអប្បបរមា |
|---|---|---|---|
| ៩ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | បណ្ឌិត | 54 |
| ៨ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា /ឯកទេស | បរិញ្ញាបត្រជាន់ខ្ពស់ | 45 |
| ៧ | បរិញ្ញាបត្របច្ចេកវិទ្យា /ឯកទេសសញ្ញាបត្រវិស្វករ | បរិញ្ញាបត្រ | 120 |
| ៦ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកវិទ្យា/ឯកទេស | បរិញ្ញាបត្ររង | 60 |
| ៥ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ.៣ | | 30 |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | | 30 |
| ៣ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | | 30 |
| ២ | វិញ្ញាបនបត្រវិជ្ជាជីវៈ | | 30 |
| ១ | បរិញ្ញាបត្ររង | | 30 |

(ក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជា, ២០១៤)

កម្រិតអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមាន៨។ ចំពោះគុណវុឌ្ឍិបួនកម្រិតដំបូងដែលអាចទទួលបានជាវិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១, ២ និង ៣ ត្រូវបានផ្តល់តម្លៃសមមូលទៅនឹងការអប់រំមធ្យមសិក្សា។ ចំណែកឯបួនគុណវុឌ្ឍិបន្តពីនេះត្រូវចាត់ទុកជាគុណវុឌ្ឍិដែលសិក្សាក្រោយមធ្យមសិក្សា។ កម្រិតចូលទៅការអប់រំឧត្តមសិក្សា គឺការបញ្ចប់ដោយជោគជ័យនៅមធ្យមសិក្សាទុតិយភូមិ។ ក្របខ័ណ្ឌអប់រំឧត្តមសិក្សាមាន៤កម្រិតគុណវុឌ្ឍិដែលកម្រិតខ្ពស់បំផុតគឺ សញ្ញាបត្រកម្រិតបណ្ឌិត។

**រូបភាពទី២.១:** ការបង្កើតប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស




(MoEYS, 2015)

ប្រព័ន្ធអប់រំផ្លូវការនៃការអប់រំនៅមធ្យមសិក្សាទុតិយភូមិនឹងត្រូវបង្កើតឡើងស្របតាមស្ថានភាពតម្រូវការរបស់សហគមន៍ រួមមានពីរផ្នែក គឺផ្នែកអប់រំចំណេះទូទៅ និងផ្នែកអប់រំបច្ចេកទេស។ ប្រព័ន្ធអប់រំនេះបាននឹងកំពុងអនុវត្តនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។ ការចូលរៀនមុខវិជ្ជាអប់រំបច្ចេកទេសសិស្សត្រូវតែប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ទើបអាចដាក់ពាក្យចូលរៀនផ្នែកអប់រំបច្ចេកទេសបាន។ ការសិក្សាផ្នែកអប់រំបច្ចេកទេសមានរយៈពេល៣ឆ្នាំ អនុវត្តនៅមធ្យមសិក្សាទុតិយភូមិ គឺ

ថ្នាក់ឆ្នាំទី១ ថ្នាក់ឆ្នាំទី២ និងថ្នាក់ឆ្នាំទី៣។ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស មានគោលដៅអប់រំសិស្សឲ្យមានជំនាញ និងសមត្ថភាព ប្រកបដោយចំណេះដឹងវិជ្ជាជីវៈពិតប្រាកដ និងចំណេះដឹងអាជីពដើម្បីឆ្លើយតបទៅនឹងបម្រែបម្រួលដ៏លឿនក្នុងសង្គម ឧស្សាហកម្មដែលមាននិន្នាការទៅរកព័ត៌មានវិទ្យា(ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ(២០១៥-២០១៩))។

## ២.៣ កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេស

មនុស្សជាច្រើនក្នុងចំណោមសាធារណជនមានការយល់ឃើញមិនល្អចំពោះការអប់រំ និងអាជីពនៅក្នុងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដែលជាហេតុត្រូវតែកែតម្រូវដើម្បីធ្វើឱ្យវាស្របទៅនឹងផែនការអភិវឌ្ឍន៍ឧស្សាហកម្មជាតិរបស់យើង(Awang, 2011)។ ការសិក្សាគឺដើម្បីស៊ើបអង្កេតមតិរបស់សិស្សនៅអនុវិទ្យាល័យ វិទ្យាល័យ និងសិស្សនៃវិទ្យាស្ថានឯកជនលើរូបភាព និងភាពពេញចិត្តរបស់ពួកគេចំពោះការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ លទ្ធផលបានបង្ហាញថាសិស្សដែលរៀននៅក្នុងសាលាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងកូនសិស្សដែលមានជំនាញផ្សេងៗទៀតមិនយល់ស្របនឹងការយល់ឃើញនៃសិស្សសាលាអប់រំចំណេះទូទៅថាសិស្សដែលឆ្លងកាត់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈពេលដែលរៀនចប់គឺពិបាករកការងារធ្វើ ប្រាក់ចំណូលតិច សង្គមមិនសូវឱ្យតម្លៃ ជីវភាពគ្រួសារមិនថ្លៃថ្នូរ និងគ្មានឱកាសក្នុងការបន្តការសិក្សានៅថ្នាក់កម្រិតឧត្តមសិក្សានោះឡើយ។ សិក្ខាកាមមានការយល់ឃើញថាការជ្រើសរើសជំនាញនេះមានសារៈសំខាន់ក្នុងការសិក្សានៅសាលាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ បើប្រៀបធៀបទៅនឹងសិស្សវិទ្យាល័យដែលរៀននៅសាលាដទៃទៀត។

### ២.៣.១ កត្តាខាងក្នុង

#### ២.៣.១.១ កត្តាភេទ

មានការសិក្សាមួយចំនួនដែលបានសិក្សាថា កត្តាភេទ ជាកត្តាដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការសម្រេចចិត្ត ក្នុងការជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សានុសិស្ស។ បើយោងតាមការសិក្សារបស់ Huruma (2015) បានសិក្សាទៅលើកត្តាភេទ ពិតជាមានឥទ្ធិពលខ្លាំងក្នុងការជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្ស។ ការសិក្សាមួយទៀត បានអះអាងថា ការជ្រើសរើសមុខវិជ្ជារបស់សិស្ស គឺមានភាពខុសគ្នាទៅតាម

ភេទក្នុងការជ្រើសរើសនោះ(Calkins & Welki, 2006)។ ការសិក្សានេះ ក៏បានរកឃើញថា សិស្សស្រីជ្រើសរើសមុខវិជ្ជា គឺទៅតាមមុខវិជ្ជាជាក់លាក់ដែលគេកំពុងធ្វើការសិក្សានៅក្នុងថ្នាក់ ស្របពេលដែលសិស្សប្រុសវិញជ្រើសរើសមុខវិជ្ជាអាស្រ័យលើមុខរបរដែលស្របទៅតាមតម្រូវការទីផ្សារ ដែលទាក់ទងនឹងមុខវិជ្ជាដែលពួកគេកំពុងសិក្សា។ ការសិក្សាមួយទៀតរបស់ Dickson (2010) ក៏បានអះអាងដែលថា កត្តាភេទមានឥទ្ធិពលយ៉ាងខ្លាំង ចំពោះសិស្សានុសិស្សក្នុងការជ្រើសរើសមុខវិជ្ជាសិក្សា នៅតាមមហាវិទ្យាល័យផងដែរ។ បើតាម ការសិក្សារបស់ Miller, Slawinski, Blessing & Schwartz (2006) បានសិក្សារកឃើញថាសិស្សប្រុសនៅកម្រិតវិទ្យាល័យចូលចិត្តមុខវិជ្ជាអប់រំបច្ចេកទេសជាងសិស្សស្រី ហើយជាងនេះទៅទៀតពួកគេជ្រើសរើសមុខវិជ្ជា ដើម្បីបន្តការសិក្សានៅ ថ្នាក់ឧត្តមសិក្សា។ ស្រដៀងគ្នានេះដែរការសិក្សារបស់ Wiswall & Zafar (2011) ក៏បានរកឃើញពីភាពខុសគ្នាយ៉ាងខ្លាំងរបស់សិស្សប្រុស និងសិស្សស្រី ក្នុងការជ្រើសរើសមុខវិជ្ជាផងដែរ។

ផ្នែកខាងក្រោមបន្ទាប់នេះ គឺជាកត្តាសំខាន់មួយទៀតដែលមានឥទ្ធិពលដល់ ការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សានុសិស្ស គឺ កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស។

**២.៣.១.២ កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន**

មានការសិក្សាជាច្រើនបានរកឃើញថា កត្តាចំណាប់អារម្មណ៍របស់សិស្សផ្ទាល់ គឺជាកត្តានៃការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សារបស់ពួកគេ។ បើតាមការសិក្សារបស់ Calkins & AWelki (2006) បានរកឃើញថា កត្តាដែលមានឥទ្ធិពលបំផុតសម្រាប់ជ្រើសរើសមុខវិជ្ជាក្នុងការសិក្សារបស់សិស្ស គឺកត្តាចំណាប់អារម្មណ៍របស់សិស្សផ្ទាល់ទៅលើការជ្រើសរើសមុខវិជ្ជានោះ។ ក្នុងការសិក្សាស្រាវជ្រាវរបស់ពួកគាត់បានលើកឡើងថា ៩៣% នៃការជ្រើសរើសមុខវិជ្ជាសម្រាប់សិក្សាគឺ ផ្អែកទៅលើចំណាប់អារម្មណ៍ទៅលើមុខវិជ្ជា។ មានការសិក្សាស្រដៀងគ្នាមួយដែរ គឺសិស្សប្រុស ៩៣% ក៏ជ្រើសរើសមុខវិជ្ជាសិក្សាផ្អែកលើចំណាប់អារម្មណ៍របស់ពួកគេ (Huruna , 2015)។ មានការសិក្សាស្របគ្នាមួយទៀត គឺការសិក្សានៅប្រទេសហ្វាំងឡង់ និង ប្រទេសប៉ទុយកាល់ កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និង ភាពចូលចិត្ត ជាកត្តានៃការជ្រើសមុខវិជ្ជាសិក្សារបស់សិស្សផងដែរ ( James, 2007)។ បើតាម Wally-Dima (2013) បានសិក្សារកឃើញថា

សិស្សនៅកម្រិតថ្នាក់វិទ្យាល័យ គឺមានចំណាប់អារម្មណ៍ខ្ពស់លើមុខវិជ្ជា។

**២.៣.១.៣ កត្តាសមត្ថភាព**

កត្តាសមត្ថភាពក៏ជាកត្តាមួយសំខាន់ដែលសិស្សានុសិស្សសម្រេចចិត្តជ្រើសរើសមុខវិជ្ជា ឬជំនាញសិក្សាផងដែរ។ បើតាមការសិក្សាមួយរបស់ Huruma (2015) បានសិក្សារកឃើញថា កត្តាសមត្ថភាពរបស់សិស្ស ជាកត្តាមួយដែលមានឥទ្ធិពលក្នុងការជ្រើសរើសមុខវិជ្ជាសិក្សានៅកម្រិតវិទ្យាល័យ។ ការសិក្សាផ្សេងទៀតបានសិក្សាដូចគ្នាដែរថា កត្តាសមត្ថភាព គឺជាកត្តាសំខាន់ ក្នុងការជ្រើសរើសមុខវិជ្ជាតាមមហាវិទ្យាល័យ (Beggs, Bamtham & Taylor, 2008)។

ក្រៅពីកត្តាភេទ កត្តាសមត្ថភាព កត្តាចំណាប់អារម្មណ៍របស់សិស្សផ្ទាល់ គឺនៅមានកត្តាតម្រូវការសិក្សា និងការអប់រំបច្ចេកទេស ដែលមានឥទ្ធិពលក្នុងការជ្រើសរើសមុខវិជ្ជាសម្រាប់សិក្សា។ ខាងក្រោមនេះជាកត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស ដែលជាកត្តាមួយមានឥទ្ធិពលក្នុងការជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សផងដែរ។

**២.៣.១.៤ កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស**

ក្នុងការសិក្សាជាច្រើនបានរកឃើញថា កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស គឺជាកត្តាសំខាន់ដែលសិស្សានុសិស្សម្នាក់ៗបានធ្វើការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាជាក់លាក់ ដើម្បីឱ្យ សមស្របតាមលទ្ធភាពដែលខ្លួន និងគ្រួសារមាន ជាពិសេសដើម្បីឱ្យត្រូវទៅតាមតម្រូវការរបស់សង្គមពេលបច្ចុប្បន្ន និងពេលអនាគត។ បើតាម Tripney, Newman, Bangpan, Niza, MacKintosh & Sinclai (2010) បានបង្ហាញថា កត្តាតម្រូវការការសិក្សានៅមហាវិទ្យាល័យ និងការអប់រំរបស់ពួកគេគឺជាកត្តានៃការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សា។ នៅក្នុងបរិបទប្រទេសកម្ពុជា ការសិក្សាមួយដែលធ្វើដោយ UNDP[1] (2011) បានបង្ហាញថា ដោយសារតែចំណេះដឹងខាងផ្នែកសេដ្ឋកិច្ចច្រើន ទើបបានជាមានការបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។ ការសិក្សារបស់ Sof (2016) សិស្សានុសិស្សនៅកម្រិតអនុវិទ្យាល័យក្នុងប្រទេសឥណ្ឌាបានជ្រើសមុខវិជ្ជា ឬជំនាញ ដោយពួកគេគិតទៅលើតម្រូវការការងារ នៅពេលពួកគេបញ្ចប់ការសិក្សា។

---

[1] UNDP=The United Nations Development Programme

## ២.៣.២ កត្តាខាងក្រៅ

### ២.៣.២.១ កត្តាអាណាព្យាបាល

ឪពុកម្តាយមានតួនាទីសំខាន់ណាស់ក្នុងការកំណត់អនាគតកូនៗរបស់ខ្លួន តាមរយៈការណែនាំ បង្ហាញផ្លូវ និងជម្រុញកូនៗឱ្យទទួលការអប់រំ ឬការបណ្តុះបណ្តាលដែលត្រូវតាមតម្រូវការទីផ្សារ ដើម្បី សម្រេចបាននូវបច្ចេកទេស និងវិជ្ជាជីវៈនៃជំនាញរបស់កូន។ ឪពុកម្តាយតែងតែសង្ឃឹមថាកូនៗរបស់ពួក គេមានការងារធ្វើ ត្រឹមត្រូវ ប្រាក់ចំណូលខ្ពស់ អនាគតល្អ និងជោគជ័យក្នុងជីវិត។ គោលដៅរបស់ឪពុក ម្តាយក្នុងការអប់រំកូនរបស់ពួកគេគឺមានសារៈសំខាន់ណាស់ ដោយសារឪពុកម្តាយភាគច្រើនមានទស្សនៈ ថាកេរ្តិ៍ឈ្មោះក្នុងការសិក្សាបានខ្ពង់ខ្ពស់ មានជំនាញច្បាស់លាស់ និងអាចនាំទៅរកការងារកាន់តែប្រសើរ។ ការស្រាវជ្រាវដោយ Ayub (2017) បានរកឃើញថា សាវតារបស់ឪពុកម្តាយមានឥទ្ធិពលគួរឱ្យកត់សម្គាល់ លើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ ភាគច្រើននៃឪពុកម្តាយរបស់សិស្ស ឆ្លើយសំណួរនៅក្នុងការសិក្សានេះមានប្រវត្តិសេដ្ឋកិច្ច ការអប់រំ និងការងារមិនសូវល្អនៅក្នុងសង្គម។ វាអាច ត្រូវបានសន្និដ្ឋានថាឪពុកម្តាយដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាបនៅក្នុងសង្គមបានលើកទឹកចិត្តកូន របស់ពួកគេឱ្យបន្តការសិក្សានៅសាលាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។

មានការសិក្សាជាច្រើនបានបង្ហាញថា ឪពុកម្តាយ ឬអាណាព្យាបាលរបស់សិស្ស បានរួមចំណែក ក្នុងការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សានុសិស្ស នៅកម្រិតអនុវិទ្យាល័យផងដែរ។ ការ សិក្សារបស់ Ahmed & Maryam (2016) បានរកឃើញថាសិស្សភាគច្រើន មានគំនិតអវិជ្ជមាន ចំពោះមុខ វិជ្ជាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដោយសារពួកគេទទួលរងឥទ្ធិពលពីក្រុមគ្រួសាររបស់ពួកគេ។ ឪពុកម្តាយ របស់សិស្សបានលើកទឹកចិត្តដល់កូនៗរបស់ពួកគេ ឱ្យជ្រើសរើសមុខវិជ្ជាណា ដែលទទួលបានឱកាស ការងារដែលមានប្រាក់បៀវត្ស ខ្ពស់នៅក្នុងសង្គម ដូចជា គ្រូពេទ្យ វិស្វករជាដើម ។ ដូចនេះ ការសម្រេចចិត្ត ជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សានុសិស្សពិតជាមានការរួមចំណែកពីអាណាព្យាបាល។ ការសម្រេច ចិត្តបានល្អពិតជាអាចជួយឱ្យ កូនៗរបស់ពួកគាត់ទទួលបានភាពជោគជ័យ នៅក្នុងជីវិតសិក្សារបស់ពួកគេ។

កម្រិតការសិក្សា និងកត្តាសេដ្ឋកិច្ចរបស់អាណាព្យាបាលសិស្ស បានជះឥទ្ធិពលដល់ការសម្រេច

ចិត្តរបស់សិស្សានុសិស្សផងដែរ។ បើតាមការសិក្សារបស់ Boudarbat & Montmaquette (2006) បានបង្ហាញថា កម្រិតសិក្សារបស់អាណាព្យាបាលសិស្ស គឺមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការជ្រើសរើសមុខវិជ្ជាសិក្សារបស់កូនៗ។ បើទោះបីជាការជ្រើសរើសមានទាំងកត្តាឪពុកម្តាយ និងកត្តាភេទរបស់កូនៗក៏ដោយ ក៏កម្រិតការសិក្សារបស់ម្តាយ មានឥទ្ធិពលចំពោះកូនស្រី និងកម្រិតការសិក្សារបស់ឪពុក មានឥទ្ធិពលលើការជ្រើសរើសរបស់កូនប្រុស។ ដូចគ្នានឹងការសិក្សារបស់ Goyette & Mullen (2006) បានរកឃើញថា កម្រិតអប់រំរបស់អាណាព្យាបាល គឺមានឥទ្ធិពលយ៉ាងខ្លាំង ចំពោះការសម្រេចចិត្តលើការសិក្សារបស់កូនៗរបស់ពួកគេទៅលើមុខវិជ្ជាសម្រាប់មកសិក្សា។

នៅក្នុងបរិបទប្រទេសកម្ពុជា ការសិក្សារបស់ YEP[2] (2008) បានរកឃើញថា១១% នៃការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្ស ដែលបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា គឺដោយសារកត្តាតម្រូវការទីផ្សារការងារ ហើយ៥៩% ដោយសារកត្តាឪពុកម្តាយរបស់ពួកគេ។ ដូចនេះហើយ នៅក្នុងសង្គមកម្ពុជាឪពុកម្តាយពិតជាមានឥទ្ធិពលលើការសម្រេចចិត្តរបស់កូនៗសម្រាប់សិក្សានៅថ្នាក់ឧត្តមសិក្សា។ មានការសិក្សាមួយទៀតបានបង្ហាញថា ប្រាក់ចំណូលរបស់ឪពុកម្តាយ អាចមានឥទ្ធិពលដល់ការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សារបស់កូនៗ។ ការសិក្សារបស់ Akarsu & Kariper (2013) បង្ហាញថា កម្រិតយល់ដឹងរបស់ឪពុកម្តាយ និងស្ថានភាពសេដ្ឋកិច្ចគ្រួសារ ជាកត្តាមួយក្នុងចំណោមកត្តាផ្សេងៗទៀតដែលបានរួមចំណែកដល់ការសម្រេចចិត្តចំពោះមុខនៃការជ្រើសរើស។

សរុបសេចក្តីមកឥទ្ធិពលឪពុកម្តាយ ឬអាណាព្យាបាលសិស្ស ពិតជាបានរួមចំណែកយ៉ាងសំខាន់ទាក់ទងនឹងការសម្រេចចិត្តរបស់សិស្សក្នុងការជ្រើសរើសមុខវិជ្ជាមកសិក្សាសម្រាប់អនាគត។

### ២.៣.២.២ កត្តាគ្រូបង្រៀន

គ្រូបង្រៀនមានតួនាទីយ៉ាងសំខាន់ព្រោះគ្រូបង្រៀនតែងតែនៅក្បែរសិស្ស និងជួបសិស្សញឹកញាប់ជាងគេ។ ដូចនេះគ្រូបង្រៀនមានតួនាទីក្នុងការផ្តល់ប្រឹក្សា តម្រង់ទិស និងណែនាំដល់សិស្សពីការជ្រើសរើសរើសមុខវិជ្ជាសម្រាប់រៀនសូត្រ។ បើតាមការសិក្សារបស់ Athanasou & Petoumenos (1998) បានបង្ហាញ

---

YEP[2]= " Youth Employment and Social Dialogue" Project

ថា គ្រូបង្រៀនអាចមានឥទ្ធិពល ក្នុងការលើកទឹកចិត្តសិស្សតាមរយៈទិដ្ឋភាពជាក់លាក់ នៃការបង្រៀនរបស់ពួកគាត់ ប៉ុន្តែរឿងដែលសំខាន់ គឺតាមរយៈការតម្រង់ទិសរបស់ពួកគាត់។ បើតាមការសិក្សារបស់ Khaled (2013) បានបង្ហាញថា សេចក្តីសាទរ និងការចូលរួមរបស់គ្រូបង្រៀន បានធ្វើឱ្យមានរូបភាពជាវិជ្ជមាន ចំពោះការសិក្សាផ្នែកជំនាញវិជ្ជាជីវៈរបស់សិស្សានុសិស្សនៅវិទ្យាល័យ។

- **បុគ្គលិកលក្ខណៈរបស់គ្រូបង្រៀន**

បើតាមការសិក្សារបស់ Fontana (1988) & Moore (1993) បានបង្ហាញថាបុគ្គលិកលក្ខណៈ និងអាកប្បកិរិយារបស់គ្រូមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើតអាកប្បកិរិយារបស់សិស្សអន្តរកម្មរវាងគ្រូ និងសិស្សពាក់ព័ន្ធនឹងបញ្ហាជាច្រើនដែលទាក់ទងនឹងបុគ្គលិកលក្ខណៈ និងវិធីសាស្រ្តនៃការណែនាំ និងផ្តល់ដំបូន្មាន។ ម្យ៉ាងវិញទៀតគ្រូបង្រៀនត្រូវមានតួនាទីជាគ្រូបង្វឹកដើរតួជាអ្នកណែនាំ ជំនួយ និងអ្នកសហការដែលប្រកបដោយការយល់ចិត្ត មេត្តា ភាពសប្បាយរីករាយ។ តួនាទីរបស់គ្រូបង្រៀនត្រូវបានសន្មត់ថាជាតំណភ្ជាប់ដ៏សំខាន់នៅក្នុងទំនាក់ទំនងរវាងតួនាទីរបស់គ្រូ និងអាកប្បកិរិយារបស់សិស្ស។ មុខងាររបស់គ្រូរួមមាន ការធ្វើរោគវិនិច្ឆ័យ និងការសម្របសម្រួលដល់សិស្ស មានន័យថា គ្រូត្រូវធ្វើរោគវិនិច្ឆ័យចំណេះដឹង និងសមត្ថភាពសិស្សជាមុនសិន មុននឹងផ្ទេរចំណេះដឹងថ្មីដល់ពួកគេ។ ក្នុងនាមជាអ្នកសម្របសម្រួល គ្រូត្រូវរៀបចំផែនការរៀនសូត្រតាមរបៀបដែលផ្តល់ចំណេះ ជំនាញ និងបទពិសោធន៍សិក្សាល្អៗដែលត្រូវផ្ទេរបន្ត។

- **វិធីសាស្រ្តបង្រៀន និងរៀន**

គ្រូបង្រៀនមិនត្រឹមតែជាអ្នកវាយតម្លៃលើលក្ខណៈផ្ទាល់ខ្លួនរបស់បុគ្គលប៉ុណ្ណោះទេប៉ុន្តែថែមទាំងពិចារណាលើទស្សនវិជ្ជានៃការអប់រំ និងបញ្ហាផ្សេងទៀតដែលទាក់ទងនឹងចិត្តវិទ្យាអប់រំ និងគោលការណ៍សិក្សាផងដែរ។គ្រូបង្រៀនជាទូទៅជាអ្នកកំណត់គោលដៅរយៈពេលខ្លី និងវែងនៃលទ្ធផលដែលត្រូវសម្រេចបាននៅក្នុងថ្នាក់រៀនរបស់ពួកគេ។ គោលដៅទាំងនេះរួមមានទាំងគោលបំណងយល់ដឹង និងផលប៉ះពាល់ផ្សេងៗ។ ដើម្បីសម្រេចបានការបណ្តុះបណ្តាលដែលនឹងជួយសិស្សគឺសំខាន់គ្រូត្រូវមានការពេញចិត្ត និងចេះប្រើវិធីសាស្រ្តបង្រៀនថ្មីៗបន្ថែមទៀត (Anderson, 1991)។

### ២.៣.២.៣ កត្តាមិត្តភក្តិ

ការសិក្សាមួយបានពន្យល់ពីកត្តានៃការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សានុសិស្សនៅថ្នាក់មហាវិទ្យាល័យ។ បើតាមការសិក្សារបស់ Walmsley, Wilson & Morga (2010) បានរកឃើញថា មិត្តភក្តិ គឺជាកត្តាដែលមានឥទ្ធិពលខ្លាំងបំផុត ចំពោះសិស្សក្នុងការជ្រើសរើសមុខវិជ្ជាសិក្សា។ ជាងនេះទៅទៀត ការសិក្សាមួយទៀតបានពិនិត្យលើទៅលើ ឥទ្ធិពលនៃកត្តាផ្ទាល់ខ្លួន និងកត្តាមុខរបរពេលអនាគតលើជម្រើសមុខវិជ្ជា លើមុខជំនួញបានបង្ហាញថា កត្តាមិត្តភក្តិត្រូវបានគេចាត់ទុកថាគឺជាកត្តាដែលមានឥទ្ធិពលលើការជ្រើសរើសមុខវិជ្ជា (Al-Rfou, 2013)។ ប៉ុន្តែការសិក្សាមួយជាមួយសិស្សកម្ពុជា បានបង្ហាញថាកត្តាមិត្តភក្តិ មានឥទ្ធិពលតិចបំផុតលើការជ្រើសរើសមុខវិជ្ជាសិក្សា គឺមានតែ១% បើប្រៀបធៀបទៅនឹងកត្តាផ្សេងៗទៀត (YEP, 2008)។

ផ្អែកលើការសិក្សាពីមុនបង្ហាញថា មិត្តភ័ក្តិមានឥទ្ធិពលយ៉ាងខ្លាំងលើអ្នកសិក្សាដែលមានវ័យប្រហាក់ប្រហែលគ្នាក្នុងកាជ្រើសរើស និងការសម្រេចចិត្តណាមួយរបស់ពួកគេ រួមទាំងការជ្រើសរើសជំនាញក្នុងការសិក្សាអប់រំផងដែរ។ ការសិក្សាស្រាវជ្រាវបានបង្ហាញថាសិស្សភាគច្រើនបានជ្រើសរើសមុខវិជ្ជាសម្រាប់សិក្សាតាម និងដូចគ្នាជាមួយមិត្តជិតស្និទ្ធរបស់ពួកគេ (Alnaqbi, 2015)។ នៅក្នុងការសិក្សាស្រាវជ្រាវមួយផ្សេងទៀតបានបង្ហាញដែរថា អំណាចនៃមិត្តភក្តិមានឥទ្ធិពលយ៉ាងខ្លាំង ដែលអាចរួមចំណែកដល់ 50% នៃការសម្រេចចិត្តរបស់មនុស្សវ័យក្មេងដូចគ្នាក្នុងការជ្រើសរើសជំនាញ ឬអាជីព។

### ២.៣.២.៤ កត្តាថ្នាក់រៀន និងសាលារៀន

ជាទូទៅ បរិយាកាសសិក្សាក្នុងថ្នាក់ សំដៅលើលំហ ឬជាកន្លែងដែលអ្នកសិក្សា/សិស្ស និងគ្រូមានអន្តរកម្មជាមួយគ្នា ហើយប្រើប្រាស់ឧបករណ៍ និងធនធានព័ត៌មានផ្សេងៗក្នុងការបន្តការសិក្សា (Wilson, 1996)។ ធម្មជាតិនៃបរិយាកាសក្នុងថ្នាក់រៀន និងអន្តរកម្មសង្គមអាចធ្វើឱ្យមានភាពខុសគ្នានៅក្នុងរបៀបដែលសិស្សរៀន និងសម្រេចបាននូវគោលដៅរបស់ពួកគេ។ វាត្រូវបានបង្ហាញថា លទ្ធផលសិក្សា និងអាកប្បកិរិយារបស់សិស្សចំពោះការរៀនសូត្រត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងបរិយាកាសក្នុងថ្នាក់រៀន (Entwistle and entwistle 1991, 2003)។ ការសិក្សាផ្សេងទៀត Fraser, Rentoul (1980) &

Fraser, Fisher (1983) ត្រូវបានធ្វើឡើងដើម្បីកំណត់ពីកម្រិតនៃសារៈសំខាន់នៃបរិយាកាសថ្នាក់រៀន នៅក្នុងដំណើរការបង្រៀន និងរៀន។ ពួកគេបានស្នើថាសមិទ្ធផលត្រូវបានធ្វើឱ្យប្រសើរឡើងដោយធ្វើការ នៅក្នុងបរិយាកាសថ្នាក់រៀនដែលពេញចិត្ត។ ពួកគេក៏បានអះអាងដែរថា ដោយសារបរិយាកាសមួយមាន វិមាត្ររាងកាយ សង្គម និងផ្លូវចិត្ត របៀបដែលមនុស្សទាក់ទងគ្នាទៅវិញទៅមក គឺជាដំណាក់កាលដំបូង ដើម្បីកែលម្អគ្នាទៅវិញទៅមក។

អ្នកស្រាវជ្រាវ Eklund (1995) & Entwistle (1992) ក៏បានរាយការណ៍ថា ថ្នាក់រៀនដើរតួនាទី យ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ការយល់ដឹង និងកត្តាដែលជះឥទ្ធិពលដល់ការសិក្សាផងដែរ។ម្យ៉ាងវិញ ទៀត អ្នកផ្សេងទៀតបានអះអាងថា អាកប្បកិរិយារបស់មនុស្សត្រូវបានកំណត់ដោយអន្តរកម្មដ៏ស្មុគស្មាញ របស់បុគ្គលម្នាក់ និងបរិយាកាសរបស់គាត់(Moos, 1979)។ ដកស្រង់ដោយ Back & Choi (2002) បានអះអាងថាបរិយាកាសសង្គមក៏ដូចជាមនុស្សអាចមានលក្ខណៈដូចជាភាពកក់ក្ដៅ និងការពេញចិត្ត ឬ ភាពរឹងមាំ និងការបម្រុងប្រយ័ត្ន។ ឧបករណ៍មួយចំនួនសម្រាប់សិក្សាបរិយាកាសក្នុងថ្នាក់រៀនត្រូវបាន បង្កើតឡើងក្នុងរយៈពេលជាច្រើនឆ្នាំ។ កម្រងសំណួរសម្រាប់សាលារៀនគ្រប់កម្រិត និងបរិបទក្នុងថ្នាក់ រៀនបាននាំមកនូវវិធីសាស្ត្រជាច្រើនលើការយល់ឃើញ ការវាយតម្លៃ និងការស៊ើបអង្កេតលើការយល់ ឃើញរបស់សិស្ស និងគ្រូលើទិដ្ឋភាពផ្សេងៗនៃបរិយាកាសក្នុងថ្នាក់រៀន ។ ការសិក្សាអំពីបរិយាកាសក្នុង ថ្នាក់បានបង្ហាញថា បរិយាកាសក្នុងថ្នាក់អាចជួយទស្សន៍ទាយលទ្ធផលសិក្សារបស់សិស្សបាន (Fraser, 1998 & Fraser, Walberg, 1991)។ ជាឧទាហរណ៍ Haertel, Walberg & Haertel (1981) បានរកឃើញថា សមិទ្ធផលរបស់សិស្សមានភាពប្រសើរឡើងនៅក្នុងថ្នាក់ទាំងនោះ ដែលសិស្សមាន អារម្មណ៍ថាមានភាពស្និទស្នាល ការពេញចិត្ត និងទិសដៅ គោលដៅកាន់តែច្រើន ។

### ២.៣.២.៥ កត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត

Stanislav (2019) បានសិក្សាស្រាវជ្រាវឃើញថា ការងារបច្ចុប្បន្ន និងការងារនាពេលអនាគត មានឥទ្ធិពលលើជម្រើសរបស់សិស្ស។ សិស្សជ្រើសរើសទិសដៅនៃផ្លូវអាជីពដែលស័ក្តិសមបំផុតដើម្បីចូល វគ្គសិក្សាបន្ទាប់ពីអនុវិទ្យាល័យរបស់ពួកគេ។ សិស្សត្រូវតែមានវិធីសាស្ត្រលើកទឹកចិត្ត និងការគិតវិជ្ជមាន

ដើម្បីបន្តអាជីពរបស់ពួកគេ។ ការងារក្នុងក្តីស្រមៃកំពុងឈានទៅដល់គោលដៅនៅពេលដែលជំហានចាំបាច់ដែលដើរតាមផ្លូវត្រឹមត្រូវដែលបង្កើតជំនាញ និងសមត្ថភាពច្បាស់លាស់សម្រាប់អាជីពផ្ទាល់ខ្លួន និងសង្គមនាពេលអនាគត។

## ២.៤ បញ្ហាប្រឈម នៃការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្ស

តាមរយៈកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមរបស់ដៃគូអភិវឌ្ឍ បានធ្វើឲ្យការអភិវឌ្ឍជំនាញក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស មានការរីកចម្រើនគួរឲ្យកត់សម្គាល់ ប៉ុន្តែទោះជាយ៉ាងណាក៏វិស័យនេះនៅតែបន្តជួបប្រទះនូវបញ្ហាមួយចំនួនក្នុងស្ថានភាពមានកម្រិតដូចខាងក្រោម៖

### ២.៤.១ គុណភាពនៃការអប់រំបច្ចេកទេស មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ

ការនេះបណ្តាលមកពីកង្វះនូវប្រព័ន្ធធានាគុណភាព វិធីសាស្ត្របណ្តុះបណ្តាលនៅមានកម្រិតកង្វះខាត បទពិសោធជាក់ស្តែងរបស់គ្រូបច្ចេកទេសជាមួយវិស័យឧស្សាហកម្ម កង្វះហេដ្ឋារចនាសម្ព័ន្ធជម្រើសនៃសម្ភារៈបណ្តុះបណ្តាល បទប្បញ្ញត្តិដែលពាក់ព័ន្ធនៅមិនទាន់មានគ្រប់គ្រាន់ កង្វះប្រព័ន្ធវាយតម្លៃសមត្ថភាព គ្រូបច្ចេកទេស និងសិស្ស ព្រមទាំងជំនាញរបស់ពលករមុន និងក្រោយពេលចំណាកស្រុកដោយមានការទទួលស្គាល់ពីវិស័យឧស្សាហកម្មពាក់ព័ន្ធ (គោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

### ២.៤.២ ការមិនសូវឲ្យតម្លៃទៅលើការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ប្រជាជនមួយចំនួនឲ្យតម្លៃតែលើការអប់រំកម្រិតឧត្តមសិក្សា(សាកលវិទ្យាល័យ) ជាហេតុធ្វើឲ្យការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនៅមានកម្រិតទាប។ កន្លងមកគ្រឹះស្ថានសិក្សាភាគច្រើន មិនទាន់បានអនុវត្តយន្តការផ្តល់ការណែនាំឲ្យបានទូលំទូលាយដល់សិស្សឲ្យមានជម្រើសផ្សេងៗ រួមទាំងការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស ទស្សនៈអវិជ្ជមានដែលមានលក្ខណៈទូទៅសម្រាប់បណ្តាប្រទេសមួយចំនួនក្នុងអាស៊ាន ត្រូវបានចាត់ទុកថាការអប់រំបណ្តុះបណ្តាលបច្ចេកទេស ជា"ឱកាសទីពីរ និងចំណាត់ថ្នាក់ទីពីរ សម្រាប់តែជនក្រីក្រ ជនងាយរងគ្រោះ និងជន

បោះបង់ការសិក្សាពីប្រព័ន្ធអប់រំចំណេះទូទៅ។ ទាំងនេះក៏ជាឧបសគ្គដ៏ធំសម្រាប់ការចុះឈ្មោះចូលរៀនក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស ដែលធ្វើការបណ្តុះបណ្តាលកម្លាំងពលកម្មសម្រាប់វិស័យឧស្សាហកម្មដែលមានស្រាប់ និងកំពុងកើតមានថ្មីៗ(គោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

**២.៤.៣ ថវិកាមានកម្រិតសម្រាប់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**

ថវិការបស់រាជរដ្ឋាភិបាលសម្រាប់វិស័យនេះពុំទាន់បានគ្រប់គ្រាន់នៅឡើយ ដោយសារការបណ្តុះបណ្តាលអប់រំបច្ចេកទេសជាពិសេស ត្រូវការចំណាយយ៉ាងច្រើនក្នុងការធ្វើឲ្យកម្លាំងពលកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងជំនាញច្បាស់លាស់ ដើម្បីបំពេញតម្រូវការរបស់វិស័យឧស្សាហកម្មចំពោះមុខ និងការអភិវឌ្ឍសេដ្ឋកិច្ចយូរអង្វែង កម្លាំងពលកម្មទាំងនេះមានលទ្ធភាពអាចចូលរួមប្រកួតប្រជែងជាមួយកម្លាំងពលកម្មផ្សេងទៀតក្នុងតំបន់។ ការចូលរួមហិរញ្ញវត្ថុពីវិស័យឯកជនឬភាគីពាក់ព័ន្ធ គឺជាការចាំបាច់បំផុត ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យអប់រំបច្ចេកទេសឲ្យមានស្ថិរភាព(គោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

**២.៤.៤ ការទទួលស្គាល់ពុំទាន់ទូលំទូលាយចំពោះកម្មវិធីអប់រំបច្ចេកទេសឆ្លងប្រព័ន្ធ**

ទោះបីជាក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជាត្រូវបានអនុម័តរួចហើយ ក៏វានៅមានបញ្ហាមួយចំនួនរួមមាន ៖ ក-ការផ្សារភ្ជាប់រវាងកម្មវិធីសិក្សាចំណេះទូទៅ និងកម្មវិធីសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងនៅមានកម្រិត ខ-កង្វះការខិតខំប្រឹងប្រែងរួមគ្នានៅក្នុងការបណ្តុះបណ្តាលគ្រូបច្ចេកទេសនិងការចែករំលែកសម្ភារៈសិក្សាក្នុងចំណោម ក្រសួងពាក់ព័ន្ធ គ-កម្មវិធីស្ពានចម្លងបន្តជំនាញ ព្រមទាំងការផ្តល់វិញ្ញាបនបត្រឆ្លងក្រសួង ដែលពាក់ព័ន្ធនៅមិនទាន់អនុវត្តបានទូលំទូលាយ ឃ-កង្វះខាតលំហូរព័ត៌មានទីផ្សារការងារនិងព័ត៌មានអំពីការ អប់រំបណ្តុះបណ្តាលបច្ចេកទេសរវាងភាគីពាក់ព័ន្ធ(គោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

**២.៤.៥ ជំនាញមូលដ្ឋាន និងជំនាញទន់នៅមានកម្រិត**

ការរៀបចំខ្លួនសម្រាប់អ្នកស្វែងរកការងារលើកដំបូងត្រូវបានចាត់ទុកថា នៅមានកម្រិតដោយសារ

តែពួកគេ ខ្វះខាតបទពិសោធមូលដ្ឋានក្នុងជីវិត និងភាពចាស់ទុំក្នុងការធ្វើការងារ កង្វះជំនាញបច្ចេកទេស ឬជំនាញសម្រាប់ធ្វើការងារ រួមទាំងមានអាកប្បកិរិយាមិនល្អ ឬកង្វះការតាំងចិត្ត។ ជាញឹកញាប់ សិស្ស ដែលបានបញ្ចប់ការសិក្សានៅផ្ទះ ជំនាញជាមូលដ្ឋានដូចជាការអាន ការសរសេរ ការគិតលេខ កុំព្យូទ័រ ការ ប្រាស្រ័យទាក់ទងគ្នា ការធ្វើការងារជាក្រុមទាំងជំនាញដោះស្រាយបញ្ហា (គោលនយោបាយជាតិស្តីពីការ បណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

### ២.៤.៦ កម្រិតនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ

ទាំងនេះធ្វើឲ្យប៉ះពាល់ដល់គុណភាព ប្រសិទ្ធភាពនៃការចំណាយ និងភាពឆ្លើយតបរបស់វិស័យ អប់រំបណ្តុះបណ្តាលបច្ចេកទេស ជាហេតុនាំឲ្យវិស័យនេះបន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន រួមមានបទ ពិសោធជាក់ស្តែង ជាមួយឧស្សាហកម្មរបស់គ្រូបច្ចេកទេសនៅមានកម្រិត កម្មវិធីកម្មសិក្សា មិនទាន់មាន គ្រប់គ្រាន់សម្រាប់សិស្ស ហើយការអនុវត្តតាមស្តង់ដាជំនាញក៏នៅមិនទាន់បានគ្រប់ជ្រុងជ្រោយដែលជា ហេតុនាំឲ្យកម្មវិធីបណ្តុះបណ្តាលមិនទាន់ឆ្លើយតបទៅតាមតម្រូវការទីផ្សារការងារ(គោលនយោបាយជាតិ ស្តីពីការបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

### ២.៤.៧ កង្វះខាតការគាំទ្រទាំងសម្ភារៈសិក្សានិងធនធានថវិកាសម្រាប់សិក្ខាកាម/សិស្ស

នាពេលបច្ចុប្បន្ន បញ្ហាប្រឈមធំៗរបស់យុវជនកំពុងជួបប្រទះក្នុងការសិក្សា រួមមានកង្វះការគាំទ្រ ជាថវិកា ការធ្វើសេចក្តីសម្រេចការគាំទ្រគំនិត និងកង្វះការណែនាំអំពីមុខរបរ។ លើសពីនេះ យុវជនក៏បាន លើកឡើងនូវតម្រូវការ ដែលជាចំណុចអាទិភាពមួយចំនួន ដើម្បីពួកគេអាចបន្តការអប់រំបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ ដូចជាការផ្តល់ កន្លែងស្នាក់នៅ ការជួយឧបត្ថម្ភ ប្រាក់សម្រាប់អាហារ ព្រមទាំងការ ជួយរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា (គោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

### ២.៤.៨ កង្វះខាតការគាំទ្រទាំងសម្ភារៈសិក្សា និងធនធានថវិកាសម្រាប់សិស្ស

នាពេលបច្ចុប្បន្ន បញ្ហាប្រឈមធំៗរបស់សិស្សកំពុងជួបប្រទះក្នុងការសិក្សា រួមមានកង្វះការគាំទ្រ ជាថវិកា ការធ្វើសេចក្តីសម្រេចការគាំទ្រគំនិត និងកង្វះការណែនាំអំពីមុខរបរ។ លើសពីនេះ យុវជនក៏បាន

លើកឡើងនូវតម្រូវការ ដែលជាចំណុចអាទិភាពមួយចំនួន ដើម្បីពួកគេអាចបន្តការអប់រំបណ្តុះបណ្តាលបច្ចេកទេស ដូចជាការផ្តល់កន្លែងស្នាក់នៅ ការជួយឧបត្ថម្ភ ប្រាក់សម្រាប់អាហារ ព្រមទាំងការជួយរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា(គោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥))។

## ២.៥ ក្របខណ្ឌគំនិតនៃការស្រាវជ្រាវ

រូបភាពទី២.២៖ កត្តាជះឥទ្ធិពលលើអាកប្បកិរិយាសិស្ស៖




កត្តាជះឥទ្ធិពលលើអាកប្បកិរិយាសិស្សមានកត្តាពីរ គឺកត្តាខាងក្នុង(កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន កត្តាភេទ កត្តាអាយុ កត្តាសមត្ថភាព កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស) និងកត្តាខាងក្រៅ(កត្តាអាណាព្យាបាល កត្តាមិត្តភ័ក្ត កត្តាគ្រូបង្រៀន កត្តាថ្នាក់រៀន និងសាលារៀន និងកត្តាអាជីព និងសក្តានុពលការងារពេលអនាគត)។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១- គម្រោងវិភាគ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវខាងលើ និងសម្រេចតាមគោលបំណងនៃការសិក្សាស្រាវជ្រាវ ការសិក្សាស្រាវជ្រាវនេះបានប្រើវិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័។ បែបបរិមាណវិស័យបានប្រើប្រាស់កម្រងសំណួរទម្រង់បិទ បែបជ្រើសរើសតាមលំដាប់លំដោយ និងកម្រងសំណួរទម្រង់បើកដើម្បីចង់ដឹងពីបញ្ហាប្រឈម និងដំណោះស្រាយនៃការជ្រើសរើសការអប់រំបច្ចេកទេសនេះ។ មូលហេតុនៃការជ្រើសរើស និងប្រើប្រាស់បែបបរិមាណវិស័យនេះ ដើម្បីរកឱ្យឃើញនូវលទ្ធផលជាក់លាក់ អាចគិតជាភាគរយនៃក្រុមនីមួយៗ ប្រៀបធៀបនឹងចំនួនកំណត់ជាក់លាក់មួយ (Gray, 2009)។ វិធីសាស្ត្រនេះត្រូវមានសូចនាករជាក់លាក់ និងស្តង់ដា ដោយគោរពនូវដំណើរការជាក់លាក់ក្នុងការប្រមូលទិន្នន័យ (Bamberger, 2012)។ បើយោងតាម Merriam (1998) ការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យ អ្នកសិក្សាតែងចាប់អារម្មណ៍ និងមានការយល់ដឹង និងចេះវិភាគទិន្នន័យ។

នៅក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាបានកំណត់ជ្រើសរើសយកវិទ្យាល័យតែមួយ(ក្នុងខេត្តស្វាយរៀងមានវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសតែមួយគត់)គឺ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសបាវិត ដែលស្ថិតនៅភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវនៅក្នុងជំពូកទី១។ ចំពោះកម្រងសំណួរ ត្រូវបានរៀបចំសម្រាប់សួរទៅសិស្សានុសិស្ស ថ្នាក់ឆ្នាំទី១ ឆ្នាំទី២ ឆ្នាំទី៣ នៃការអប់រំបច្ចេកទេសក្នុងឆ្នាំសិក្សា២០២២-២០២៣ លោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀននៅវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស ព្រមទាំងគណៈនាយកសាលា។ អ្នកស្រាវជ្រាវបានបែងចែក កម្រងសំណួរជា០៣ប្រភេទផ្សេងៗគ្នា គឺសម្រាប់សិស្ស សម្រាប់លោកគ្រូ អ្នកគ្រូ និងសម្រាប់គណៈគ្រប់គ្រងសាលា។ កម្រងសំណួរសម្រាប់សិស្ស និងសម្រាប់លោកគ្រូ អ្នកគ្រូ និងសម្រាប់គណៈគ្រប់គ្រងសាលា មានលក្ខណៈជាសំណួរទម្រង់បិទ និងលក្ខណៈជាទម្រង់បើក។

## ៣.២- ការជ្រើសរើសសំណាក

តារាងទី៣.១ ៖ ចំនួនសំណាកត្រូវចុះប្រមូលទិន្នន័យ

| ល.រ | អ្នកផ្តល់ព័ត៌មាន | សរុប | ស្រី | ភាគរយស្រី |
|---|---|---|---|---|
| ១ | គណៈគ្រប់គ្រង | 03 | 00 | 00% |
| ២ | គ្រូបង្រៀនឯកទេស | 20 | 05 | 25% |
| ៣ | សិស្ស | 134 | 50 | 37% |
| សរុបភាគសំណាក | | 157 | 55 | 35% |

ដើម្បីឆ្លើយតបទៅនឹងទំហំនៃការសិក្សា អ្នកសិក្សាបានកំណត់ជ្រើសរើសការសិក្សាស្រាវជ្រាវនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបាវិត ក្នុងខេត្តស្វាយរៀង។ ចំពោះការជ្រើសរើសសំណាក អ្នកសិក្សាជ្រើសរើសគណៈគ្រប់គ្រងចំនួន០៣នាក់ ស្រី០០នាក់ គ្រូបង្រៀនជំនាញអប់រំបច្ចេកទេសសរុប២០នាក់ ស្រី០៥នាក់ និងសិស្សរៀនផ្នែកអប់រំបច្ចេកទេស ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣ សរុបចំនួន១៣៤នាក់ ស្រី៥០នាក់។

## ៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

តាមរយៈលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា លិខិតសុំការអនុញ្ញាតចុះប្រមូលព័ត៌មានពីវិទ្យាស្ថានជាតិអប់រំ និងដោយមានលិខិតអនុញ្ញាតពីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង អ្នកសិក្សាបានចុះទៅសិក្សា និងប្រមូលព័ត៌មាននៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបាវិត ក្នុងខេត្តស្វាយរៀង។ ខណៈពេលដែលខ្ញុំបាទបានចុះទៅដល់សាលា គឺមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ ខ្ញុំបានជួបសិស្សតាមថ្នាក់នីមួយៗ និងជួបពួកគាត់នៅកន្លែងប្រតិបត្តិ និងកសិដ្ឋានជាដើម។ តាមថ្នាក់នីមួយៗ ខ្ញុំបានប្រាប់ទៅសិស្សយ៉ាងច្បាស់ពីគោលបំណងនៃការប្រមូលទិន្នន័យ និងបានសុំការសហការពីពួកគាត់ដោយមិនមានការបង្ខិតបង្ខំ។ បន្ទាប់មកខ្ញុំបានចែកជូនកម្រងសំណួរទៅពួកគាត់ និងទុកពេលវេលាឱ្យពួកគាត់បំពេញយ៉ាងគ្រប់គ្រាន់ និងបានពិនិត្យត្រឹមត្រូវនូវគ្រប់សំណួរ និងការសាកសួរបន្ថែមខណៈដែលមិនទាន់យល់លើសំណួរណាមួយ។

### ៣.៣.១ កម្រងសំណួរសម្រាប់សិស្ស

ចំពោះកម្រងសំណួរ ដែលបានសួរទៅសិស្សានុសិស្សដែលកំពុងរៀនផ្នែកជំនាញអប់រំបច្ចេកទេស ថ្នាក់ឆ្នាំទី១ ឆ្នាំទី២ ឆ្នាំទី៣ ដែលបានចែកចេញជា ០៣ផ្នែកធំៗ និងមានសំណួរទម្រង់បិទចំនួន៥៧ និងទម្រង់បើក០២សំណួរ ៖

**ផ្នែកទី១** ព័ត៌មានផ្ទាល់ខ្លួន៖ ក្នុងផ្នែកនេះមាន០៨សំណួរ ហើយអ្នកស្រាវជ្រាវចង់ដឹងពីភេទរបស់សិស្សអាយុសិស្ស កម្រិតវប្បធម៌ឪពុកម្តាយ ប្រាក់ចំណូលឪពុកម្តាយ កម្រិតជីវភាពឪពុកម្តាយ ជំនាញដែលសិស្សកំពុងសិក្សា និងថ្នាក់ឆ្នាំសិក្សារបស់សិស្ស។

**ផ្នែកទី២** កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសមានដូចជា ៖

កត្តាខាងក្នុង៖ ផ្នែកនេះមាន២៧សំណួរ ហើយអ្នកសិក្សាចង់ដឹងពី កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន កត្តាភេទ កត្តាអាយុ កត្តាសមត្ថភាព កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស។

កត្តាខាងក្រៅ ៖ ផ្នែកនេះមាន៣០សំណួរ ហើយអ្នកសិក្សាចង់ដឹងពីការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សា របស់សិស្សានុសិស្សមានការចូលរួមចំណែកពី កត្តាអាណាព្យាបាល កត្តាមិត្តភក្តិ កត្តាគ្រូបង្រៀន កត្តាថ្នាក់រៀន និងសាលារៀន អាជីព និងសក្តានុពលការងារនាពេលអនាគត់។

**ផ្នែកទី៣** បញ្ហាប្រឈមនៃការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្ស ជាកម្រងសំណួរបើក៖ ផ្នែកនេះមាន០២សំណួរ ហើយសំណួរទាំងនោះគឺទាក់ទងនឹងបញ្ហាប្រឈមនៃការសម្រេចចិត្តរបស់សិស្សចំពោះការជ្រើសរើសមុខវិជ្ជាសិក្សា ការជួបបញ្ហាប្រឈមរបស់សិស្សពេលកំពុងសិក្សា និងការយល់ឃើញពីដំណោះស្រាយលើបញ្ហាប្រឈម។

### ៣.៣.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន

ចំពោះកម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ ត្រូវបានចែកចេញជា០៣ផ្នែកធំៗ ដែលមានសំណួរទម្រង់បិទចំនួន៥៧ និងទម្រង់បើក ០២សំណួរ ៖

ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន៖ នៅក្នុងផ្នែកនេះមានសំណួរចំនួន០៦ ហើយអ្នកស្រាវជ្រាវចង់ដឹងពីភេទ កម្រិតវប្បធម៌ កម្រិតបណ្តុះបណ្តាល ព្រមទាំងកម្រិតថ្នាក់ និងមុខជំនាញបង្រៀនរបស់ពួកគាត់។

ផ្នែកទី២ កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសមានដូចជា ៖

កត្តាខាងក្នុង ៖ ផ្នែកនេះមាន២៧សំណួរ ហើយអ្នកសិក្សាចង់ដឹងពី កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស កត្តាភេទ កត្តាអាយុ កត្តាសមត្ថភាព កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេសរបស់សិស្ស។

កត្តាខាងក្រៅ ៖ ផ្នែកនេះមាន៣០សំណួរ ហើយអ្នកសិក្សាចង់ដឹងពីការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សានុសិស្សមានការចូលរួមចំណែកពី កត្តាអាណាព្យាបាល កត្តាមិត្តភក្តិ កត្តាគ្រូបង្រៀន កត្តាថ្នាក់រៀន និងសាលារៀន កត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត។

ផ្នែកទី៣ បញ្ហាប្រឈមនៃការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្ស ជាកម្រងសំណួរបើក ៖ នៅក្នុងផ្នែកនេះ ចង់ដឹងពីការយល់ឃើញរបស់លោកគ្រូ អ្នកគ្រូ ចំពោះភាពលំបាករបស់សិស្សក្នុងការជ្រើសរើសមុខវិជ្ជាមកសិក្សា ការយល់ឃើញពីលោកគ្រូ អ្នកគ្រូ ចំពោះបញ្ហាប្រឈមរបស់សាលានៃការប្រមូលសិស្សចូលរៀនការអប់រំបច្ចេកទេស និងដំណោះស្រាយ។

### ៣.៣.៣ កម្រងសំណួរសម្រាប់នាយក

ចំពោះកម្រងសំណួរសម្រាប់លោកនាយក/លោកនាយករង ត្រូវបានចែកចេញជា០៣ផ្នែកធំៗដែលមានសំណួរទម្រង់បិទចំនួន៥៧ និងទម្រង់បើកសំណួរ០២ ៖

ផ្នែកទី២ កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសមានដូចជា ៖

កត្តាខាងក្នុង ៖ ផ្នែកនេះមាន២៧សំណួរ ហើយអ្នកសិក្សាចង់ដឹងពី កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស កត្តាភេទ កត្តាអាយុ កត្តាសមត្ថភាព កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេសរបស់សិស្ស។

កត្តាខាងក្រៅ ៖ ផ្នែកនេះមាន៣០សំណួរ ហើយអ្នកសិក្សាចង់ដឹងពីការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្សានុសិស្សមានការចូលរួមចំណែកពី កត្តាអាណាព្យាបាល កត្តាមិត្តភក្តិ កត្តាគ្រូបង្រៀន កត្តាថ្នាក់រៀន និងសាលារៀន អាជីព និងសក្តានុពលការងារនាពេលអនាគត។

ផ្នែកទី៣ បញ្ហាប្រឈមនៃការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្ស ជាកម្រងសំណួរបើក ៖

នៅក្នុងផ្នែកនេះ អ្នកសិក្សាចង់ដឹងអំពីចំនួនសិស្សគ្រប់តាមចំនួនផែនការដែរឬទេ វិធីសាស្ត្រក្នុងការទាក់ទាញសិស្សមកចាប់អារម្មណ៍ការអប់រំបច្ចេកទេសឱ្យបានច្រើន សារៈប្រយោជន៍នៃសិស្សដែលទទួលបានពីការចូលរៀនការអប់រំបច្ចេកទស កម្មវិធីតម្រង់ទិសសិស្សក្នុងការជ្រើសរើសមុខជំនាញអប់រំបច្ចេកទេសរបស់សាលារៀន ការផ្សព្វផ្សាយពីកម្មវិធីប្រមូលសិស្សចូលរៀន បញ្ហាប្រឈមនៃការប្រមូលសិស្សចូលរៀន

និងដំណោះស្រាយនៃបញ្ហាប្រឈម។

### ៣.៣.៤ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញ គឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញអាចបំពេញដោយគូសផ្ទាល់នៅលើកម្រងសំណួរ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត។

ការវាយតម្លៃទៅលើកត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិ គឺប្រើការបកស្រាយអត្ថន័យតម្លៃជាភាគរយលើកម្រិតចង្អុលបង្ហាញ៖ ១.មិនយល់ស្របទាល់តែសោះ, ២.មិនយល់ស្រប, ៣.យល់ស្របខ្លះ មិនយល់ស្របខ្លះ, ៤.យល់ស្រប, ៥.យល់ស្របទាំងស្រុង។

## ៣.៤ ដំណើរការនៃការប្រមូលទិន្នន័យ

ក្រោយពីកម្រងសំណួរត្រូវបានបង្កើតរួចរាល់ហើយ និងបានត្រួតពិនិត្យពីសាស្ត្រាចារ្យណែនាំរួចស្របពេលដែលអ្នកស្រាវជ្រាវទទួលបានលិខិតចុះប្រមូលទិន្នន័យពីវិទ្យាស្ថានជាតិអប់រំ ដើម្បីចុះទៅប្រមូលប្រមូលទិន្នន័យនៅតាមសាលារៀនគោលដៅដែលបានកំណត់។

ក្រោយពីទទួលបានលិខិតពីវិទ្យាស្ថានជាតិអប់រំ ដំបូងអ្នកស្រាវជ្រាវបានទៅជួបថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដើម្បីសុំការសហការលើការងារដែលពាក់ព័ន្ធនឹងការស្រាវជ្រាវនេះ។ បន្ទាប់ពីបានទៅសុំការសហការពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងរួចហើយ អ្នកស្រាវជ្រាវបានចុះទៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសតាមគោលដៅដែលបានកំណត់។ ពេលទៅដល់សាលា អ្នក

ស្រាវជ្រាវបានទៅសុំការសហការពីគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ។ ហើយក្រោយពីមានការយល់ព្រមពីគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ រួចមក អ្នកស្រាវជ្រាវបានចែកកម្រងសំណួរទៅដល់សិស្សានុសិស្សផ្ទាល់។ ចំពោះកម្រងសំណួរ របស់លោកគ្រូ អ្នកគ្រូ និងនាយកសាលា អ្នកសិក្សាចែកជូនឱ្យបំពេញដោយផ្ទាល់ ។ ក្រោយពីការបំពេញ ចម្លើយរបស់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និង គណៈគ្របគ្រងសាលា តាមរយៈការបំពេញដោយផ្ទាល់បានគ្រប់ចំនួនរួចរាល់ហើយ អ្នកស្រាវជ្រាវក៏បានយកទិន្នន័យទាំងនេះមកធ្វើការវិភាគ ។

ការប្រមូលទិន្នន័យនេះនឹងអាចជួយឱ្យអ្នកស្រាវជ្រាវប្រមូលបាននូវព័ត៌មានដ៏មានសារៈប្រយោជន៍សម្រាប់ប្រធានបទ **«កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង»**។

## ៣.៥ ការវិភាគទិន្នន័យ

ទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ តាមរយៈការបំពេញដោយផ្ទាល់ ត្រូវបានអ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធី Microsoft Excel សម្រាប់វិភាគទិន្នន័យ ព្រមទាំងប្រើប្រាស់កម្មវិធីនេះ សម្រាប់ការបង្កើតតារាងផងដែរ។ រាល់ទិន្នន័យដែលប្រមូលបានទាំងអស់នឹងត្រូវបានយកមកធ្វើការវិភាគ និងបកស្រាយជាភាគរយ(%) និងពន្យល់ដោយមានការប្រៀបធៀបពីកត្តានៃការជ្រើសរើសមុខជំនាញសិក្សារបស់សិស្សានុសិស្សលើការអប់រំបច្ចេកទេស។ ការវិភាគនេះផ្អែកទៅលើសូចនាករដែលបានកំណត់ពីកត្តាដែលបានរួមចំណែកចំពោះការសម្រេចចិត្តជ្រើសរើសជំនាញអប់រំបច្ចេកទេសរបស់សិស្ស។ ការសិក្សាចំពោះឧបករណ៍ទាំងបីនេះ ក្នុងគោលបំណងរកឱ្យឃើញពីកត្តាជះឥទ្ធិពលនៃការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្ស។ បន្ទាប់មកទៀតអ្នកសិក្សានឹងធ្វើសេចក្ដីសន្និដ្ឋានជារួមមួយថាតើមានកត្តាអ្វីខ្លះដែលជាកត្តាមានឥទ្ធិពលលើការជ្រើសរើសការអប់រំបច្ចេកទេសរបស់សិស្សានុសិស្សយ៉ាងពិតប្រាកដ។ ជាពិសេសការបង្ហាញពីបញ្ហាប្រឈម និងដំណោះស្រាយដែលបានរកឃើញតាមរយៈការប្រើប្រាស់កម្រងសំណួរផ្ទាល់។

តារាងទី៣.២ ៖ ចំនួនអ្នកបានចូលរួមផ្ដល់ព័ត៌មាន

| ល.រ | អ្នកបានផ្ដល់ព័ត៌មាន | សរុប | ភាគរយ | សរុបស្រី | ភាគរយស្រី |
|---|---|---|---|---|---|
| ១ | សិស្ស | 134 | 86% | 50 | 91% |
| ២ | គ្រូបង្រៀន | 20 | 100% | 05 | 100% |
| ៣ | នាយកសាលា | 3 | 100% | 00 | 0% |
| **សរុប** | | **157** | **89%** | **55** | **91%** |

ចំពោះការចុះប្រមូលទិន្នន័យ គឺស្ថិតនៅក្នុងវិទ្យាល័យចំណោះទូទៅ និងអប់រំបច្ចេកទេសបារិត ក្នុងខេត្តស្វាយរៀង។ ទិន្នន័យនេះមាន សិស្សបានចូលរួមចំនួន១៣៤នាក់ ត្រូវជា៨៦% ស្រី៥០នាក់ ត្រូវជា៩១%។ គ្រូបង្រៀនបានចូលរួមចំនួន២០នាក់ ត្រូវជា១០០% ស្រី០៥នាក់ ត្រូវជា១០០%។ គណៈគ្រប់គ្រងសាលាបានចូលរួមចំនួន០៣នាក់ ត្រូវជា១០០% ស្រី០០នាក់ ត្រូវជា០% ។ ដូចនេះអ្នកបានចូលរួមផ្ដល់ព័ត៌មានសរុបចំនួន១៥៧នាក់ ត្រូវជា៨៩% ស្រី៥៥នាក់ ត្រូវជា៩១%។

តារាងទី៣.៣ ៖ កម្រិតវប្បធម៌ម្ដាយ និងឪពុករបស់សិស្ស

| ល.រ | កម្រិតវប្បធម៌ | ម្ដាយ | ភាគរយ | ឪពុក | ភាគរយ |
|---|---|---|---|---|---|
| ១ | បឋមសិក្សា | 72 | 54% | 39 | 29% |
| ២ | មធ្យមសិក្សាបឋមភូមិ | 39 | 29% | 51 | 38% |
| ៣ | មធ្យមសិក្សាទុតិយភូមិ | 19 | 14% | 39 | 29% |
| ៤ | ឧត្ដមសិក្សា | 4 | 3% | 5 | 4% |

តាមរយៈទិន្នន័យដែលបានបង្ហាញក្នុងតារាងខាងលើ បានបង្ហាញថា ម្ដាយរបស់សិស្សបានសិក្សាត្រឹមកម្រិតបឋមសិក្សា មានចំនួន៧២នាក់ដែលត្រូវជា៥៤% ដែលជាទិន្នន័យខ្ពស់ជាងគេ និងត្រឹមកម្រិតឧត្ដមសិក្សាមាន០៤នាក់ ត្រូវជា៣% ជាទិន្នន័យដែលទាបជាងគេ។ ចំណែកកម្រិតសិក្សារបស់ឪពុករបស់សិស្សវិញ គឺគាត់បានសិក្សាត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ មានចំនួន៥១នាក់ ត្រូវជា៣៨% ជាទិន្នន័យខ្ពស់ជាងគេ និងទិន្នន័យទាបជាងគេគឺសិក្សានៅកម្រិតឧត្ដមមានចំនួន០៥នាក់ ដែលត្រូវជា៤%។

សរុបសេចក្ដីមក ឪពុកម្ដាយរបស់សិស្សភាគច្រើនបានទទួលបានការសិក្សាត្រឹមកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ គឺឪពុករបស់សិស្សភាគច្រើនបានសិក្សាត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ និង

ម្តាយរបស់សិស្សភាគច្រើនបានសិក្សាត្រឹមកម្រិតបឋមសិក្សា។

តារាងទី៣.៤ ៖ ប្រាក់ចំណូលជាមធ្យមរបស់ឪពុកម្តាយសិស្ស

| ល.រ | ប្រាក់ចំណូលជាមធ្យមរបស់ឪពុកម្តាយសិស្ស | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | មិនមានប្រាក់ចំណូល | 6 | 4% |
| ២ | ក្រោម ២០០ដុល្លា | 54 | 40% |
| ៣ | ២០០ដុល្លា ដល់ ៤០០ដុល្លា | 47 | 35% |
| ៤ | ច្រើនជាង៤០០ដុល្លា | 27 | 20% |

តាមរយៈ តារាងខាងលើ បានបង្ហាញថា កម្រិតជីវភាពរបស់គ្រួសារសិស្សនៅមានកម្រិតទាប គឺមិនមានប្រាក់ចំណូលជាមធ្យម មាន០៦នាក់ ត្រូវនឹង៤% ប្រាក់ចំណូលក្រោម២០០ដុល្លាមានចំនួន៥៤នាក់ ត្រូវជា៤០% និងមានប្រាក់ចំណូលចន្លោះពី២០០ដុល្លាដល់៤០០ដុល្លា មានចំនួន៤៧នាក់ ត្រូវជា៣៥%។ នេះមានន័យថា ឪពុកម្តាយរបស់សិស្សនៅមានប្រាក់ចំណូលទាបនៅឡើយ។

តារាងទី៣.៥ ៖ អាយុរបស់គ្រូបង្រៀន និងនាយកសាលា

| ល.រ | អាយុ | គ្រូបង្រៀន | ភាគរយ | នាយកសាលា | ភាគរយ |
|---|---|---|---|---|---|
| ១ | 20-30ឆ្នាំ | 10 | 48% | 0 | 00% |
| ២ | 31-40ឆ្នាំ | 8 | 38% | 0 | 00% |
| ៣ | 41-50ឆ្នាំ | 2 | 10% | 1 | 33% |
| ៤ | 51ឆ្នាំឡើងទៅ | 1 | 5% | 2 | 67% |
| សរុប | | 21 | 100% | 3 | 100% |

តាមរយៈតារាងខាងលើ បានបង្ហាញពីអាយុរបស់លោកគ្រូ អ្នកគ្រូ និងគណៈនាយកសាលា។ គ្រូបង្រៀនមានអាយុចន្លោះពី ២០-៣០ឆ្នាំ មានចំនួន១០នាក់ ត្រូវជា៤៨% ដែលជាចំនួនច្រើនជាងគេ។ និងលោកគ្រូ អ្នកគ្រូ មានអាយុ៥១ឆ្នាំឡើងទៅមានចំនួន០១នាក់ ដែលត្រូវជា៥% ដែលជាចំនួនតិចជាងគេ។ នាយកសាលាមានអាយុ៤១-៥០ឆ្នាំមានចំនួន០១នាក់ ត្រូវជា៣៣% និងអាយុ៥១ឆ្នាំឡើងទៅមានចំនួន០២នាក់ ត្រូវជា៦៧%។ ខាងក្រោមនេះអ្នកស្រាវជ្រាវនឹងសិក្សាពីកម្រិតវប្បធម៌របស់លោកគ្រូ អ្នកគ្រូ និងនាយកសាលា។

តារាងទី៣.៦ ៖ កម្រិតវប្បធម៌គ្រូបង្រៀន និងនាយកសាលា

| ល.រ | កម្រិតវប្បធម៌ | គ្រូបង្រៀន | ភាគរយ | នាយកសាលា | ភាគរយ |
|---|---|---|---|---|---|
| ១ | មធ្យមសិក្សាទុតិយភូមិ | 0 | 00% | 1 | 33% |
| ២ | បរិញ្ញាបត្រ | 19 | 95% | 1 | 33% |
| ៣ | បរិញ្ញាបត្រជាន់ខ្ពស់ | 1 | 5% | 1 | 34% |
| ៤ | បណ្ឌិត | 0 | 00% | 0 | 00% |
| **សរុប** | | **20** | **100%** | **3** | **100%** |

តាមរយៈតារាងខាងលើ បានបង្ហាញថា ក្នុងចំណោមគ្រូបង្រៀនចំនួន២០នាក់ មានគ្រូចំនួន១៩នាក់ត្រូវជា៩៥% បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន០១នាក់ត្រូវជា៥%។ ចំណែកម្រិតវប្បធម៌របស់នាយកសាលាវិញ បានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិមានចំនួន០១នាក់ បានបញ្ចប់ការសិក្សាត្រឹមថ្នាក់បរិញ្ញាបត្រមានចំនួន០១នាក់ និងបានបញ្ចប់ការសិក្សាត្រឹមបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន០១នាក់។ នៅចំណុចបន្ទាប់ខាងក្រោមនេះ អ្នកស្រាវជ្រាវ នឹងសិក្សាពីកម្រិតបណ្ដុះបណ្ដាលវិជ្ជាជីវៈ របស់លោកគ្រូ អ្នកគ្រូ និងនាយកសាលា។ នៅក្នុងតារាងខាងក្រោមនឹងបង្ហាញពីកម្រិតនៃការបណ្ដុះបណ្ដាលរបស់លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលា។

តារាងទី៣.៧៖ កម្រិតបណ្ដុះបណ្ដាលរបស់លោកគ្រូ អ្នកគ្រូ និងនាយកសាលា

| ល.រ | កម្រិតវប្បធម៌ | គ្រូបង្រៀន | ភាគរយ | នាយកសាលា | ភាគរយ |
|---|---|---|---|---|---|
| ១ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | 3 | 15% | 2 | 67% |
| ២ | គ្រូបង្រៀនកម្រិតឧត្ដម | 17 | 85% | 1 | 33% |
| **សរុប** | | **20** | **100%** | **3** | **100%** |

តាមរយៈតារាងខាងលើ គ្រូបង្រៀនសរុប២០នាក់ មាន១៧នាក់ ត្រូវជា៨៥%ជាគ្រូបង្រៀនកម្រិតឧត្ដម និងលោកគ្រូ អ្នកគ្រូ០៣នាក់ ដែលត្រូវជា១៥% ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន។ ចំណែកនាយកសាលាវិញ មានចំនួន០២នាក់ ត្រូវនឹង៦៧% ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងមាន០១នាក់ ត្រូវនឹង៣៣% ជាគ្រូបង្រៀនកម្រិតឧត្ដម។ ខាងក្រោមនេះអ្នកស្រាវជ្រាវ នឹងបង្ហាញពីកម្រិតថ្នាក់ដែលលោកគ្រូអ្នកគ្រូកំពុងបង្រៀន។

តារាងទី៣.៨ ៖ កម្រិតថ្នាក់ដែលលោកគ្រូ អ្នកគ្រូកំពុងបង្រៀន

| ល.រ | បង្រៀនតាមកម្រិតថ្នាក់ | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | ថ្នាក់ឆ្នាំទី១ | 1 | 5% |
| ២ | ថ្នាក់ឆ្នាំទី២ | 1 | 5% |
| ៣ | ថ្នាក់ឆ្នាំទី៣ | 5 | 25% |
| ៤ | ថ្នាក់ឆ្នាំទី១ និងទី២ | 1 | 5% |
| ៥ | ទាំងបីកម្រិតថ្នាក់ | 12 | 60% |
| **សរុប** | | **20** | **100%** |

តាមរយៈតារាងខាងលើ បានបង្ហាញថា ក្នុងចំណោមគ្រូ២០នាក់ មានលោកគ្រូ អ្នកគ្រូ១២នាក់ ត្រូវជា៦០% បង្រៀនទាំងបីកម្រិតថ្នាក់ ជាចំនួនច្រើនជាងគេ។ និងលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ឆ្នាំទី១ មានចំនួន០១នាក់ ថ្នាក់ឆ្នាំទី២មានចំនួន០១នាក់ និងថ្នាក់ឆ្នាំទី១ និងទី២មានចំនួន០១នាក់ ដែលត្រូវនឹង៥%មានចំនួនតិចជាងគេ។ នៅក្នុងតារាងខាងក្រោមនេះនឹងបង្ហាញពីមុខវិជ្ជាដែលលោកគ្រូ អ្នកគ្រូបានបង្រៀន មានចំនួន០៥មុខវិជ្ជា ដែលនឹងបង្ហាញទិន្នន័យដូចខាងក្រោម ៖

តារាងទី៣.៩៖ មុខវិជ្ជាបង្រៀនរបស់លោកគ្រូអ្នកគ្រូ

| ល.រ | មុខវិជ្ជាបង្រៀន | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | ក្សេត្រសាស្ត្រ | 5 | 25% |
| ២ | កែច្នៃអាហារ | 9 | 45% |
| ៣ | អគ្គិសនី | 4 | 20% |
| ៤ | មេកានិច | 1 | 5% |
| ៥ | ICT | 1 | 5% |
| **សរុប** | | **20** | **100%** |

ក្នុងចំណោមគ្រូបង្រៀន២០នាក់ មានគ្រូបង្រៀនចំនួន៥នាក់ដែលត្រូវជា២៥% បង្រៀនមុខវិជ្ជាក្សេត្រសាស្ត្រ។ គ្រូបង្រៀនចំនួន០៩នាក់ ត្រូវជា៤៥% បង្រៀនមុខវិជ្ជាកែច្នៃម្ហូបអាហារ។ គ្រូបង្រៀនចំនួន០៤នាក់ ត្រូវជា២០% បង្រៀនមុខវិជ្ជាអគ្គិសនី។ គ្រូបង្រៀនចំនួន០១នាក់ ត្រូវជា៥% បង្រៀនមុខវិជ្ជាមេកានិច។ គ្រូបង្រៀនចំនួន០១នាក់ ត្រូវជា៥% បង្រៀនមុខវិជ្ជាICT។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

## ៤.១ លទ្ធផល

ក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យតាមរយៈការវិភាគទិន្នន័យ និងការបកស្រាយ ដែលបានរកឃើញតាមរយៈកម្រងសំណួរ ទៅលើក្រុមគោលដៅដែលពាក់ព័ន្ធ រួមមាន សិស្សានុសិស្ស គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា។ លទ្ធផលដែលទទួលបាននឹងត្រូវបានយកមកពិភាក្សាលើចំណុចសំខាន់នានាដែលផ្តោតលើអាកប្បកិរិយារបស់សិស្សក្នុងការជ្រើសរើសជំនាញអប់រំបច្ចេកទេសនៅក្នុងខេត្តស្វាយរៀង។ ការសិក្សានេះក៏បានធ្វើការសិក្សាពីអថេរមួយចំនួនរបស់សិស្ស គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា រួចធ្វើការប្រៀបធៀបលទ្ធផលរវាងសិស្ស គ្រូបង្រៀន ទៅនឹងលទ្ធផលរបស់គណៈគ្រប់គ្រងសាលា។

**សំណួរស្រាវជ្រាវទី១៖ កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេស**

### ៤.១.១ កត្តាខាងក្នុង

ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាយ៉ាងលម្អិតអំពីកត្តាខាងក្នុង ចំពោះអាកប្បកិរិយារបស់សិស្សលើការជ្រើសរើសជំនាញអប់រំបច្ចេកទេសមកសិក្សា រួចធ្វើការប្រៀបធៀបលទ្ធផលរវាងសិស្ស គ្រូបង្រៀន និងនាយកសាលា ថាតើលទ្ធផលមានលក្ខណៈដូចម្តេច។

ក្នុងការសិក្សាស្រាវជ្រាវនេះ មានការចូលរួមពីសិស្សសរុបចំនួន១៣៤នាក់ ស្រី៥០នាក់ គ្រូបង្រៀនសរុប២០នាក់ ស្រី០៥នាក់ និងគណៈគ្រប់គ្រងសាលាចំនួន០៣នាក់ ស្រី០០នាក់ ដែលត្រូវបានយកមកសិក្សាលើប្រធានបទនេះ។ កត្តាខាងក្នុង មានកត្តាតូចៗចំនួន០៥ មាន៖ កត្តាចំណាប់អារម្មណ៍, កត្តាភេទ, កត្តាអាយុ, កត្តាសមត្ថភាព, កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស ត្រូវបានយកមកសិក្សាស្រាវជ្រាវលើប្រធានបទនេះ។ ខាងក្រោមនេះនឹងបង្ហាញពីលទ្ធផលនៃកត្តាតូចៗទាំង០៥ ដែលមានដូចខាងក្រោម៖

### ៤.១.១.១ កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស

#### ក.ការយល់ឃើញរបស់សិស្សចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ សិក្សាពីការយល់ឃើញរបស់សិស្សចំពោះចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ដែលមានសូចនាករនីមួយៗដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.១៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន

| ល.រ | សូចនាករ | មិនយល់ស្រប ទាល់តែសោះ | មិនយល់ ស្រប | យល់ស្របខ្លះ មិនយល់ស្របខ្លះ | យល់ ស្រប | យល់ស្រប ទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | ចំណង់ចំណូលចិត្ត និងការពេញចិត្ត | 1% | 1% | 10% | 57% | 30% |
| ២ | ឆាប់ចប់ មានជំនាញច្បាស់លាស់ | 0% | 9% | 37% | 40% | 14% |
| ៣ | មានការងារល្អ ប្រាក់ខែខ្ពស់ | 2% | 7% | 44% | 37% | 10% |
| មធ្យមភាគ | | 1% | 6% | 30% | 45% | 18% |

សូចនាករទី១ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៥៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣០% ដែលជាចំណង់ចំណូលចិត្ត និងការពេញចិត្តរបស់ពួកគេ។ សូចនាករទី២ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៤០% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៤% ដែលពួកគេយល់ថារៀនដើម្បីមានជំនាញច្បាស់លាស់សម្រាប់អនាគត។ សូចនាករទី៣ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៣៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០% ដែលពួកគេយល់ថារៀនដើម្បីមានការងារល្អ និងចង់បានប្រាក់ខែខ្ពស់។

#### ខ.ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ សិក្សាពីការយល់ឃើញរបស់គ្រូបង្រៀន ចំពោះចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស ដែលមានសូចនាករនីមួយៗដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.២៖ ការយល់ឃើញរបស់គ្រូបង្រៀន ចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស

| ល.រ | សូចនាករ | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះ: មិនយល់ស្របខ្លះ: | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | ចំណង់ចំណូលចិត្ត និងការពេញចិត្ត | 0% | 5% | 35% | 45% | 15% |
| ២ | ឆាប់ចប់ មានជំនាញច្បាស់លាស់ | 0% | 0% | 30% | 65% | 5% |
| ៣ | មានការងារល្អ ប្រាក់ខែខ្ពស់ | 0% | 0% | 40% | 50% | 10% |
| មធ្យមភាគ | | 0% | 2% | 35% | 53% | 10% |

សូចនាករទី១ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៤៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៥% ដែលពួកគាត់យល់ថាជាចំណង់ចំណូលចិត្ត និងការពេញចិត្តរបស់សិស្ស។ សូចនាករទី២ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៦៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប៥% ដែលពួកគាត់យល់ថាសិស្សរៀនដើម្បីមានជំនាញច្បាស់លាស់សម្រាប់អនាគត។ សូចនាករទី៣ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៣៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០% ដែលពួកគាត់យល់ថាសិស្សរៀនដើម្បីមានការងារល្អ និងចង់បានប្រាក់ខែខ្ពស់។

**គ.ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស**

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ សិក្សាពីការយល់ឃើញរបស់គណៈនាយកសាលា ចំពោះចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស ដែលមានសូចនាករនីមួយៗដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៣ ៖ ការយល់ឃើញរបស់នាយកសាលា ចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស

| ល.រ | សូចនាករ | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះ: មិនយល់ស្របខ្លះ: | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | ចំណង់ចំណូលចិត្ត និងការពេញចិត្ត | 0% | 0% | 33% | 67% | 0% |
| ២ | ឆាប់ចប់ មានជំនាញច្បាស់លាស់ | 0% | 0% | 0% | 67% | 33% |
| ៣ | មានការងារល្អប្រាក់ខែខ្ពស់ | 0% | 0% | 0% | 100% | 0% |
| មធ្យមភាគ | | 0% | 0% | 11% | 78% | 11% |

សូចនាករទី១ គណៈនាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% ដែលពួកគាត់យល់ថាជាចំណង់ចំណូលចិត្ត និងការពេញចិត្តរបស់សិស្ស។ សូចនាករទី២ គណៈនាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣៧% ដែលពួកគាត់យល់ថាសិស្សរៀនដើម្បីមានជំនាញច្បាស់លាស់សម្រាប់អនាគត។ សូចនាករទី៣ គណៈនាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប១០០% ដែលគណៈនាយកសាលាយល់ថាសិស្សរៀនដើម្បីមានការងារល្អ និងចង់បានប្រាក់ខែខ្ពស់។

**ឃ.លទ្ធផលរួមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន**

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវសិក្សាពីការយល់ឃើញរវាងសិស្ស គ្រូបង្រៀន និងគណៈនាយកសាលា ចំពោះកត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស ដែលមានលទ្ធផលដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៤ ៖ លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះកត្តាចំណាប់អារម្មណ៍សិស្ស

| ល.រ | កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួន | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះមិនយល់ស្របខ្លះ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | សិស្ស | 1% | 6% | 30% | 45% | 18% |
| ២ | គ្រូបង្រៀន | 0% | 2% | 35% | 53% | 10% |
| ៣ | នាយកសាលា | 0% | 0% | 11% | 78% | 11% |
| **មធ្យមភាគ** | | **0%** | **3%** | **25%** | **59%** | **13%** |

|---|---|---|---|---|---|---|
| ១ | តាមរយៈការបិទផ្សាយសេចក្តីជូនដំណឹងរបស់សាលា | 4% | 14% | 36% | 41% | 4% |
| ២ | តាមរយៈការផ្សព្វផ្សាយស្តីពីកម្មវិធីតម្រង់ទិសសិស្សរបស់សាលា | 7% | 16% | 50% | 24% | 4% |
| ៣ | តាមរយៈការផ្សព្វផ្សាយសេចក្តីជូនដំណឹងតាមបណ្តាញសង្គម ( Facebook,Page )របស់សាលា | 12% | 27% | 40% | 20% | 1% |
| ៤ | តាមរយៈការផ្សព្វផ្សាយរបស់អាជ្ញាធរដែនដី សហការជាមួយនឹងសាលារៀន | 28% | 52% | 12% | 7% | 1% |
| ៥ | មិនមែនដោយសារមិនអាចចូលរៀននៅសាលាចំណេះទូទៅទេ | 1% | 0% | 7% | 55% | 37% |
| ៦ | មិនមែនដោយសារសាលាចំណេះទូទៅលុបឈ្មោះចេញទេ | 1% | 3% | 7% | 55% | 34% |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | បោះបង់ការសិក្សានៅសាលាចំណេះទូទៅ | 3% | 10% | 46% | 34% | 6% |
| ៨ | ថ្នាក់ និងសាលារៀនមានរចនាសម្ព័ន្ធ,បរិស្ថានស្អាត និងមានសម្ភារៈគ្រប់គ្រាន់ | 1% | 5% | 40% | 51% | 4% |
| ៩ | សាលាមានសម្ភារឧបទេសគ្រប់គ្រាន់សម្រាប់ការបង្រៀននិងរៀន | 1% | 4% | 39% | 43% | 13% |
| ១០ | សិស្សចូលចិត្តការអនុវត្តផ្ទាល់ជាងរៀនទ្រឹស្តី | 1% | 3% | 41% | 49% | 6% |
| ១១ | បរិយាកាសថ្នាក់ និងសាលារៀននេះមានលក្ខណៈសមស្របក្នុងការរៀនជំនាញបច្ចេកទេស | 1% | 5% | 31% | 46% | 17% |
| ១២ | សាលាមានឧបករណ៍បរិក្ខារគ្រប់គ្រាន់នៅក្នុងបន្ទប់ពិសោធន៍ ឬរោងជាង | 4% | 14% | 36% | 41% | 4% |
| មធ្យមភាគ | | 5% | 13% | 32% | 39% | 11% |

សូចនាករទី១ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៤១% និងយល់ស្របទាំងស្រុងមានចំនួនសរុប៤% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការបិទផ្សាយសេចក្តីជូនដំណឹងរបស់សាលា។ សូចនាករទី២ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប២៤% និងយល់ស្របទាំងស្រុងមានចំនួនសរុប៤% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការផ្សព្វផ្សាយស្តីពីកម្មវិធីតម្រង់ទិសសិស្សរបស់សាលា។ សូចនាករទី៣ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប២០% និងយល់ស្របទាំងស្រុងមានចំនួនសរុប១% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការផ្សព្វផ្សាយសេចក្តីជូនដំណឹងតាមបណ្តាញសង្គមរបស់សាលា។ សូចនាករទី៤ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប១% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការផ្សព្វផ្សាយរបស់អាជ្ញាធរដែនដី សហការជាមួយនឹងសាលារៀន។ សូចនាករទី៥ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៥៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣៧% ដែលពួកគាត់យល់ថាមិនមែនដោយសារសិស្សមិនអាចចូលរៀននៅសាលាចំណេះទូទៅទេ។ សូចនាករទី៦

សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៥៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣៤% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះមិនមែនដោយសារសាលាចំណេះទូទៅលុបឈ្មោះចេញទេ។ សូចនាករទី៧ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៣៤% និងយល់ស្របទាំងស្រុងមានចំនួនសរុប៦% ដែលពួកគាត់យល់ថាដោយសារសិស្សបោះបង់ការសិក្សានៅសាលាចំណេះទូទៅ។ សូចនាករទី៨ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៥១% និងយល់ស្របទាំងស្រុងមានចំនួនសរុប៤% ដែលពួកគាត់យល់ថាដោយសារថ្នាក់ និងសាលារៀនមានរចនាសម្ព័ន្ធ,បរិស្ថានស្អាត និងមានសម្ភារៈគ្រប់គ្រាន់។ សូចនាករទី៩ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៤៣% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៣% ដែលពួកគាត់យល់ថាដោយសារសាលាមានសម្ភារឧបទេសគ្រប់គ្រាន់សម្រាប់ការបង្រៀននិងរៀន។ សូចនាករទី១០ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៤៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប៦% ដែលពួកគាត់យល់ថាសិស្សចូលចិត្តការអនុវត្តផ្ទាល់ជាងរៀនទ្រឹស្តី។ សូចនាករទី១១ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៤៦% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៧% ដែលពួកគាត់យល់ថាបរិយាកាសថ្នាក់ និងសាលារៀននេះមានលក្ខណៈសមស្របក្នុងការរៀនជំនាញបច្ចេកទេស។ សូចនាករទី១២ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៤១% និងយល់ស្របទាំងស្រុងមានចំនួនសរុប៤% ដែលពួកគាត់យល់ថាសាលាមានឧបករណ៍បរិក្ខារគ្រប់គ្រាន់នៅក្នុងបន្ទប់ពិសោធន៍ ឬរោងជាង។

**ខ.ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាថ្នាក់រៀន និងសាលារៀន**

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ សិក្សាពីការយល់ឃើញរបស់គ្រូបង្រៀន ចំពោះកត្តាថ្នាក់រៀន និងសាលារៀន ដែលមានសូចនាករនីមួយៗដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៣៤៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាថ្នាក់រៀន និងសាលារៀន

| ល.រ | សូចនាករ | មិនយល់ស្រប ទាល់តែសោះ | មិនយល់ ស្រប | យល់ស្របខ្លះមិន យល់ស្របខ្លះ | យល់ ស្រប | យល់ស្រប ទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | តាមរយៈការបិទផ្សាយសេចក្តីជូនដំណឹងរបស់សាលា | 0% | 0% | 20% | 70% | 10% |
| ២ | តាមរយៈការផ្សព្វផ្សាយស្តីពីកម្មវិធីតម្រង់ទិសសិស្សរបស់សាលា | 5% | 0% | 20% | 65% | 10% |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | តាមរយៈការផ្សព្វផ្សាយសេចក្តីជូនដំណឹងតាមបណ្តាញសង្គម (Facebook,Page)របស់សាលា | 5% | 0% | 25% | 55% | 15% |
| ៤ | តាមរយៈការផ្សព្វផ្សាយរបស់អាជ្ញាធរដែនដី សហការជាមួយនឹងសាលារៀន | 15% | 15% | 35% | 30% | 5% |
| ៥ | មិនមែនដោយសារមិនអាចចូលរៀននៅសាលាចំណេះទូទៅទេ | 0% | 5% | 20% | 50% | 25% |
| ៦ | មិនមែនដោយសារសាលាចំណេះទូទៅលុបឈ្មោះចេញទេ | 0% | 5% | 5% | 50% | 40% |
| ៧ | បោះបង់ការសិក្សានៅសាលាចំណេះទូទៅ | 40% | 40% | 15% | 5% | 0% |
| ៨ | ថ្នាក់ និងសាលារៀនមានរចនាសម្ព័ន្ធ,បរិស្ថានស្អាត និងមានសម្ភារៈគ្រប់គ្រាន់ | 0% | 10% | 50% | 40% | 0% |
| ៩ | សាលាមានសម្ភារឧបទេសគ្រប់គ្រាន់សម្រាប់ការបង្រៀននិងរៀន | 0% | 5% | 45% | 50% | 0% |
| ១០ | សិស្សចូលចិត្តការអនុវត្តផ្ទាល់ជាងរៀនទ្រឹស្តី | 0% | 0% | 30% | 70% | 0% |
| ១១ | បរិយាកាសថ្នាក់ និងសាលារៀននេះមានលក្ខណៈសមស្របក្នុងការរៀនជំនាញបច្ចេកទេស | 0% | 0% | 40% | 60% | 0% |
| ១២ | សាលាមានឧបករណ៍បរិក្ខារគ្រប់គ្រាន់នៅក្នុងបន្ទប់ពិសោធន៍ ឬរោងជាង | 0% | 5% | 45% | 40% | 10% |
| មធ្យមភាគ | | 5% | 7% | 29% | 49% | 10% |

សូចនាករទី១ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៧០% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការបិទផ្សាយសេចក្តីជូនដំណឹងរបស់សាលា។ សូចនាករទី២ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៦៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០%ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការផ្សព្វផ្សាយ

ស្ដីពីកម្មវិធីតម្រង់ទិសសិស្សរបស់សាលា។ សូចនាករទី៣ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប ៥៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៥% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះ តាមរយៈការផ្សព្វផ្សាយសេចក្ដីជូនដំណឹងតាមបណ្ដាញសង្គមរបស់សាលា។ សូចនាករទី៤ គ្រូបង្រៀន ឆ្លើយថា យល់ស្របមានចំនួនសរុប៣០% និងយល់ស្របទាំងស្រុងមានចំនួនសរុប៥% ដែលពួកគាត់ យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការផ្សព្វផ្សាយរបស់អាជ្ញាធរដែនដី សហការជាមួយនឹង សាលារៀន។ សូចនាករទី៥ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៥០% និងយល់ស្របទាំងស្រុង មានចំនួនសរុប២៥% ដែលពួកគាត់យល់ថាមិនមែនដោយសារសិស្សមិនអាចចូលរៀននៅសាលាចំណេះ ទូទៅទេ។ សូចនាករទី៦ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៥០% និងយល់ស្របទាំងស្រុង មានចំនួនសរុប៤០% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះមិនមែនដោយសារសាលា ចំណេះទូទៅលុបឈ្មោះទេ។ សូចនាករទី៧ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៥% និងយល់ ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាដោយសារសិស្សបោះបង់ការសិក្សានៅសាលា ចំណេះទូទៅ។ សូចនាករទី៨ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៤០% និងយល់ស្រប ទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាដោយសារថ្នាក់ និងសាលារៀនមានរចនាសម្ព័ន្ធ, បរិស្ថានស្អាត និងមានសម្ភារៈគ្រប់គ្រាន់។ សូចនាករទី៩ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប ៥០% និងយល់ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាដោយសារសាលាមានសម្ភារៈ ឧបទេសគ្រប់គ្រាន់សម្រាប់ការបង្រៀននិងរៀន។ សូចនាករទី១០ គ្រូបង្រៀនឆ្លើយថា យល់ស្របមាន ចំនួនសរុប៧០% និងយល់ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាសិស្សចូលចិត្តការ អនុវត្តផ្ទាល់ជាងរៀនទ្រឹស្ដី។ សូចនាករទី១១ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៦០% និង យល់ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាបរិយាកាសថ្នាក់ និងសាលារៀននេះមាន លក្ខណៈសមស្របក្នុងការរៀនជំនាញបច្ចេកទេស។ សូចនាករទី១២ គ្រូបង្រៀនឆ្លើយថា យល់ស្របមាន ចំនួនសរុប៤០% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០% ដែលពួកគាត់យល់ថាសាលាមាន ឧបករណ៍បរិក្ខារគ្រប់គ្រាន់នៅក្នុងបន្ទប់ពិសោធន៍ ឬរោងជាង។

### គ.ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាថ្នាក់រៀន និងសាលារៀន

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ សិក្សាពីការយល់ឃើញរបស់នាយកសាលា ចំពោះកត្តាថ្នាក់រៀន និងសាលារៀន ដែលមានសូចនាករនីមួយៗដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៣៥៖ ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាថ្នាក់រៀន និងសាលារៀន

| ល.រ | សូចនាករ | មិនយល់ស្រប ទាល់តែសោះ | មិនយល់ ស្រប | យល់ស្របខ្លះ មិនយល់ស្រប ខ្លះ | យល់ ស្រប | យល់ស្រប ទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | តាមរយៈការបិទផ្សាយសេចក្តីជូនដំណឹងរបស់សាលា | 0% | 0% | 33% | 67% | 0% |
| ២ | តាមរយៈការផ្សព្វផ្សាយស្តីពីកម្មវិធីតម្រង់ទិសសិស្សរបស់សាលា | 0% | 0% | 0% | 100% | 0% |
| ៣ | តាមរយៈការផ្សព្វផ្សាយសេចក្តីជូនដំណឹងតាមបណ្តាញសង្គម (Facebook,Page)របស់សាលា | 0% | 0% | 33% | 67% | 0% |
| ៤ | តាមរយៈការផ្សព្វផ្សាយរបស់អាជ្ញាធរដែនដី សហការជាមួយនឹងសាលារៀន | 33% | 0% | 0% | 67% | 0% |
| ៥ | មិនមែនដោយសារមិនអាចចូលរៀននៅសាលាចំណេះទូទៅទេ | 0% | 0% | 0% | 67% | 33% |
| ៦ | មិនមែនដោយសារសាលាចំណេះទូទៅលុបឈ្មោះចេញទេ | 0% | 0% | 0% | 67% | 33% |
| ៧ | បោះបង់ការសិក្សានៅសាលាចំណេះទូទៅ | 33% | 0% | 0% | 67% | 0% |
| ៨ | ថ្នាក់ និងសាលារៀនមានរចនាសម្ព័ន្ធ,បរិស្ថានស្អាត និងមានសម្ភារៈគ្រប់គ្រាន់ | 0% | 0% | 33% | 67% | 0% |
| ៩ | សាលាមានសម្ភារឧបទេសគ្រប់គ្រាន់សម្រាប់ការបង្រៀននិងរៀន | 0% | 0% | 0% | 100% | 0% |
| ១០ | សិស្សចូលចិត្តការអនុវត្តផ្ទាល់ជាងរៀនទ្រឹស្តី | 0% | 0% | 67% | 33% | 0% |

| | | | | | | |
|---|---|---|---|---|---|---|
| ១១ | បរិយាកាសថ្នាក់ និងសាលារៀននេះមានលក្ខណៈសមស្របក្នុងការរៀនជំនាញបច្ចេកទេស | 0% | 0% | 0% | 100% | 0% |
| ១២ | សាលាមានឧបករណ៍បរិក្ខារគ្រប់គ្រាន់នៅក្នុងបន្ទប់ពិសោធន៍ ឬរោងជាង | 0% | 0% | 0% | 100% | 0% |
| មធ្យមភាគ | | 6% | 0% | 14% | 75% | 6% |

សូចនាករទី១ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប0% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការបិទផ្សាយសេចក្តីជូនដំណឹងរបស់សាលា។ សូចនាករទី២ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប១០០% និងយល់ស្របទាំងស្រុងមានចំនួនសរុប0% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការផ្សព្វផ្សាយស្តីពីកម្មវិធីតម្រង់ទិសសិស្សរបស់សាលា។ សូចនាករទី៣ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប0% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការផ្សព្វផ្សាយសេចក្តីជូនដំណឹងតាមបណ្តាញសង្គមរបស់សាលា។ សូចនាករទី៤ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប0% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះតាមរយៈការផ្សព្វផ្សាយរបស់អាជ្ញាធរដែនដី សហការជាមួយនឹងសាលារៀន។ សូចនាករទី៥ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣៣% ដែលពួកគាត់យល់ថាមិនមែនដោយសារសិស្សមិនអាចចូលរៀននៅសាលាចំណេះទូទៅទេ។ សូចនាករទី៦ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣៣% ដែលពួកគាត់យល់ថាសិស្សជ្រើសរើសជំនាញនេះមិនមែនដោយសារសាលាចំណេះទូទៅលុបឈ្មោះទេ។ សូចនាករទី៧ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប0% ដែលពួកគាត់យល់ថាដោយសារសិស្សបោះបង់ការសិក្សានៅសាលាចំណេះទូទៅ។ សូចនាករទី៨ នាយកសាលាឆ្លើយថា យល់ស្របមានចំនួន

សរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាដោយសារថ្នាក់ និងសាលារៀនមានរចនាសម្ព័ន្ធ,បរិស្ថានស្អាត និងមានសម្ភារៈគ្រប់គ្រាន់។ សូចនាករទី៩ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប១០០% និងយល់ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាដោយសារសាលាមានសម្ភារឧបទេសគ្រប់គ្រាន់សម្រាប់ការបង្រៀននិងរៀន។ សូចនាករទី១០ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៣៣% និងយល់ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាសិស្សចូលចិត្តការអនុវត្តផ្ទាល់ជាងរៀនទ្រឹស្តី។ សូចនាករទី១១ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប១០០% និងយល់ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាបរិយាកាសថ្នាក់ និងសាលារៀននេះមានលក្ខណៈសមស្របក្នុងការរៀនជំនាញបច្ចេកទេស។ សូចនាករទី១២ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប១០០% និងយល់ស្របទាំងស្រុងមានចំនួនសរុប០% ដែលពួកគាត់យល់ថាសាលាមានឧបករណ៍បរិក្ខារគ្រប់គ្រាន់នៅក្នុងបន្ទប់ពិសោធន៍ ឬរោងជាង។

**ឃ.លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកសាលា ចំពោះកត្តាថ្នាក់រៀន និងសាលារៀន**

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវសិក្សាពីការយល់ឃើញរវាងសិស្ស គ្រូបង្រៀន និងគណៈនាយកសាលា គិតជាមធ្យមចំពោះកត្តាថ្នាក់រៀន និងសាលារៀន ដែលមានលទ្ធផលដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៣៦៖ លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកចំពោះកត្តាថ្នាក់រៀន និងសាលារៀន

| ល.រ | កត្តាថ្នាក់រៀន និងសាលារៀន | មិនយល់ស្រប ទាល់តែសោះ | មិនយល់ ស្រប | យល់ស្របខ្លះ មិនយល់ស្របខ្លះ | យល់ ស្រប | យល់ស្រប ទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | សិស្ស | 5% | 13% | 32% | 39% | 11% |
| ២ | គ្រូបង្រៀន | 5% | 7% | 29% | 49% | 10% |
| ៣ | នាយកសាលា | 6% | 0% | 14% | 75% | 6% |
| មធ្យមភាគ | | 5% | 7% | 25% | 54% | 9% |

លទ្ធផលរួមនៃការយល់ឃើញរវាងសិស្ស គ្រូបង្រៀន និងនាយកសាលា ចំពោះកត្តាថ្នាក់រៀន និងសាលារៀន បានបង្ហាញថា៖ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៣៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១១%។ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៤៩% និងយល់ស្របទាំងស្រុង

មានចំនួនសរុប១០%។ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៧៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប៦%។

### ៤.១.២.៥ កត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត

#### ក.ការយល់ឃើញរបស់សិស្សចំពោះកត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ សិក្សាពីការយល់ឃើញរបស់សិស្សចំពោះកត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត ដែលមានសូចនាករនីមួយៗដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៣៧៖ ការយល់ឃើញរបស់សិស្សចំពោះកត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត

| ល.រ | សូចនាករ | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះមិនយល់ស្របខ្លះ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | បានផ្តល់ការប្រឹក្សាអាជីព និងតម្រង់ទិសសិស្សពីសាលារៀន | 1% | 7% | 33% | 49% | 10% |
| ២ | បានទទួលការប្រឹក្សាអាជីពពីលោកគ្រូ អ្នកគ្រូ | 2% | 7% | 31% | 54% | 6% |
| ៣ | សាលាបានផ្សព្វផ្សាយណែនាំស្តីពីកម្មវិធីជ្រើសរើសជំនាញដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តម | 1% | 7% | 33% | 49% | 10% |
| មធ្យមភាគ | | 1% | 7% | 32% | 51% | 9% |

សូចនាករទី១ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៤៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០% ដែលពួកគាត់យល់ថាសិស្សបានទទួលការផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្សពីសាលារៀន។ សូចនាករទី២ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៥៤% និងយល់ស្របទាំងស្រុងមានចំនួនសរុប៦% ដែលពួកគាត់យល់ថាសិស្សបានទទួលការប្រឹក្សាអាជីព និងតម្រង់ទិសពីលោកគ្រូ អ្នកគ្រូ។ សូចនាករទី៣ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៤៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០% ដែលពួកគាត់យល់ថាសិស្សបានទទួលការផ្សព្វផ្សាយណែនាំស្តីពីកម្មវិធីជ្រើសរើសជំនាញដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តមពីសាលារៀន។

#### ខ.ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ សិក្សាពីការយល់ឃើញរបស់គ្រូបង្រៀន ចំពោះកត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត ដែលមានសូចនាករនីមួយៗដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៣៨៖ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះកត្តាអាជីព និងសក្តានុពលការងារពេលអនាគត

| ល.រ | សូចនាករ | មិនយល់ស្រប ទាល់តែសោះ | មិនយល់ ស្រប | យល់ស្របខ្លះមិន យល់ស្របខ្លះ | យល់ ស្រប | យល់ស្រប ទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | បានផ្តល់ការប្រឹក្សាអាជីព និងតម្រង់ទិសសិស្សពីសាលារៀន | 0% | 15% | 20% | 50% | 15% |
| ២ | បានទទួលការប្រឹក្សាអាជីពពីលោកគ្រូ អ្នកគ្រូ | 0% | 5% | 20% | 65% | 10% |
| ៣ | សាលាបានផ្សព្វផ្សាយណែនាំស្តីពីកម្មវិធីជ្រើសរើសជំនាញដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តម | 0% | 15% | 20% | 50% | 15% |
| មធ្យមភាគ | | 0% | 12% | 20% | 55% | 13% |

សូចនាករទី១ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៥០% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៥% ដែលពួកគាត់យល់ថាសិស្សបានទទួលការផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្សពីសាលារៀន។ សូចនាករទី២ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុ៦៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០% ដែលពួកគាត់យល់ថាសិស្សបានទទួលការប្រឹក្សាអាជីព និងតម្រង់ទិសពីលោកគ្រូ អ្នកគ្រូ។ សូចនាករទី៣ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៥០% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៥% ដែលពួកគាត់យល់ថាសិស្សបានទទួលការផ្សព្វផ្សាយណែនាំស្តីពីកម្មវិធីជ្រើសរើសជំនាញដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តមពីសាលារៀន។

**គ.ការយល់ឃើញរបស់នាយកសាលាចំពោះកត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត**

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវ សិក្សាពីការយល់ឃើញរបស់នាយកសាលា ចំពោះកត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត ដែលមានសូចនាករនីមួយៗដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៣៩៖ ការយល់ឃើញរបស់នាយកចំពោះកត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត

| ល.រ | សូចនាករ | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះមិនយល់ស្របខ្លះ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | បានផ្ដល់ការប្រឹក្សាអាជីព និងតម្រង់ទិសសិស្សពីសាលារៀន | 0% | 0% | 0% | 100% | 0% |
| ២ | បានទទួលការប្រឹក្សាអាជីពពីលោកគ្រូ អ្នកគ្រូ | 33% | 0% | 0% | 67% | 0% |
| ៣ | សាលាបានផ្សព្វផ្សាយណែនាំស្ដីពីកម្មវិធីជ្រើសរើសជំនាញដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តម | 0% | 0% | 0% | 100% | 0% |
| មធ្យមភាគ | | 11% | 0% | 0% | 89% | 0% |

សូចនាករទី១ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប១០០% និងយល់ស្របទាំងស្រុងមានចំនួនសរុប0% ដែលពួកគាត់យល់ថាសិស្សបានទទួលការផ្ដល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្សពីសាលារៀន។ សូចនាករទី២ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៦៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប0% ដែលពួកគាត់យល់ថាសិស្សបានទទួលការប្រឹក្សាអាជីព និងតម្រង់ទិសពីលោកគ្រូអ្នកគ្រូ។ សូចនាករទី៣ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប១០០% និងយល់ស្របទាំងស្រុងមានចំនួនសរុប0% ដែលពួកគាត់យល់ថាសិស្សបានទទួលការផ្សព្វផ្សាយណែនាំស្ដីពីកម្មវិធីជ្រើសរើសជំនាញដើម្បីបន្តការសិក្សានៅថ្នាក់ឧត្តមពីសាលារៀន។

**ឃ.លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយក ចំពោះកត្តាអាជីព និងសក្ដានុពលការងារពេលអនាគត**

នៅក្នុងផ្នែកនេះអ្នកស្រាវជ្រាវសិក្សាពីការយល់ឃើញរវាងសិស្ស គ្រូបង្រៀន និងគណៈនាយកសាលាចំពោះកត្តាអាជីព និងសក្ដានុពលការងារពេលអនាគត ដែលមានលទ្ធផលដូចក្នុងតារាងខាងក្រោម៖

តារាងទី៤.៤០៖ លទ្ធផលរួមរវាងសិស្ស គ្រូ និងនាយកចំពោះកត្តាអាជីព និងសក្ដានុពលការងារពេលអនាគត

| ល.រ | កត្តាអាជីព និងសក្ដានុពលការងារពេលអនាគត | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះ មិនយល់ស្របខ្លះ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | សិស្ស | 1% | 7% | 32% | 51% | 9% |
| ២ | គ្រូបង្រៀន | 0% | 12% | 20% | 55% | 13% |
| ៣ | នាយកសាលា | 11% | 0% | 0% | 89% | 0% |
| **មធ្យមភាគ** | | **4%** | **6%** | **17%** | **65%** | **7%** |

លទ្ធផលរួមនៃការយល់ឃើញរវាងសិស្ស គ្រូបង្រៀន និងនាយកសាលា ចំពោះកត្តាអាជីព និងសក្តានុពលការងារពេលអនាគត បានបង្ហាញថា៖ សិស្សឆ្លើយថា យល់ស្របមានចំនួនសរុប៥១% និងយល់ស្របទាំងស្រុងមានចំនួនសរុប៩%។ គ្រូបង្រៀនឆ្លើយថា យល់ស្របមានចំនួនសរុប៥៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៣%។ នាយកសាលាឆ្លើយថា យល់ស្របមានចំនួនសរុប៨៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប០%។

### ៤.១.៣ លទ្ធផលរួមកត្តាខាងក្នុង

តារាងទី៤.៤១៖ លទ្ធផលរួមកត្តាខាងក្នុងនៃការយល់ឃើញរវាងសិស្ស គ្រូបង្រៀន និងនាយកសាលា

| ល.រ | កត្តាខាងក្នុង | មិនយល់ស្របទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះមិនយល់ស្របខ្លះ | យល់ស្រប | យល់ស្របទាំងស្រុង | លំដាប់ |
|---|---|---|---|---|---|---|---|
| ១ | កត្តាអាយុ | 0% | 6% | 12% | 47% | 35% | 1 |
| ២ | កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស | 1% | 8% | 19% | 38% | 35% | 2 |
| ៣ | កត្តាអារម្មណ៍ផ្ទាល់ខ្លួន | 0% | 3% | 25% | 59% | 13% | 3 |
| ៤ | កត្តាសមត្ថភាព | 4% | 12% | 31% | 39% | 15% | 4 |
| ៥ | កត្តាភេទ | 10% | 13% | 50% | 22% | 6% | 5 |
| **មធ្យមភាគ** | | **3%** | **8%** | **27%** | **41%** | **21%** | |

កត្តាអាយុសិស្ស មានកម្រិតយល់ស្របចំនួនសរុប៤៧% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣៥%។ កត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេស មានកម្រិតយល់ស្របចំនួនសរុប៣៨% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣៥%។ កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស មានកម្រិតយល់ស្របចំនួនសរុប៥៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៣%។ កត្តាសមត្ថភាពសិស្ស មានកម្រិតយល់ស្របចំនួនសរុប៣៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៥%។ កត្តាភេទសិស្ស មានកម្រិតយល់ស្របចំនួនសរុប២២% និងយល់ស្របទាំងស្រុងមានចំនួនសរុប៦%។

### ៤.១.៤ លទ្ធផលរួមកត្តាខាងក្រៅ

តារាងទី៤.៤២៖ លទ្ធផលរួមកត្តាខាងក្រៅនៃការយល់ឃើញរវាងសិស្ស គ្រូបង្រៀន និងនាយកសាលា

| ល.រ | កត្តាខាងក្រៅ | មិនយល់ស្រប ទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះ:មិន យល់ស្របខ្លះ | យល់ស្រប | យល់ស្រប ទាំងស្រុង | លំដាប់ |
|---|---|---|---|---|---|---|---|
| ១ | កត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត | 4% | 6% | 17% | 65% | 7% | 1 |
| ២ | កត្តាគ្រូបង្រៀន | 2% | 4% | 30% | 54% | 10% | 2 |
| ៣ | កត្តាថ្នាក់រៀន និងសាលារៀន | 6% | 9% | 25% | 53% | 8% | 3 |
| ៤ | កត្តាអាណាព្យាបាល | 2% | 12% | 36% | 39% | 12% | 4 |
| ៥ | កត្តាមិត្តភ័ក្ត | 7% | 15% | 52% | 24% | 2% | 5 |
| **មធ្យមភាគ** | | **4%** | **9%** | **32%** | **47%** | **8%** | |

កត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត មានកម្រិតយល់ស្របចំនួនសរុប៦៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប៧%។ កត្តាគ្រូបង្រៀន មានកម្រិតយល់ស្របចំនួនសរុប៥៤% និងយល់ស្របទាំងស្រុងមានចំនួនសរុប១០%។ កត្តាថ្នាក់រៀន និងសាលារៀន មានកម្រិតយល់ស្របចំនួនសរុប៥៣% និងយល់ស្របទាំងស្រុងមានចំនួនសរុប៨%។ កត្តាអាណាព្យាបាលសិស្ស មានកម្រិតយល់ស្របចំនួនសរុប៣៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១២%។ កត្តាមិត្តភ័ក្តរបស់សិស្ស មានកម្រិតយល់ស្របចំនួនសរុប២៤% និងយល់ស្របទាំងស្រុងមានចំនួនសរុប២%។

### ៤.១.៥ លទ្ធផលរួមរវាងកត្តាខាងក្នុង និងកត្តាខាងក្រៅ

តារាងទី៤.៤៣៖ លទ្ធផលរួមរវាងកត្តាខាងក្នុង និងកត្តាខាងក្រៅ

| ល.រ | កត្តា | មិនយល់ស្រប ទាល់តែសោះ | មិនយល់ស្រប | យល់ស្របខ្លះ: មិន យល់ស្របខ្លះ | យល់ស្រប | យល់ស្រប ទាំងស្រុង | លំដាប់ |
|---|---|---|---|---|---|---|---|
| ១ | កត្តាខាងក្នុង | 3% | 8% | 27% | 41% | 21% | 1 |
| ២ | កត្តាខាងក្រៅ | 4% | 9% | 32% | 47% | 8% | 2 |

លទ្ធផលរួម បានបង្ហាញថា ៖ កត្តាខាងក្នុង មានកម្រិតយល់ស្របចំនួនសរុប៤១% និងយល់ស្របទាំងស្រុងមានចំនួនសរុប ២១%។ កត្តាខាងក្រៅ មានកម្រិតយល់ស្របចំនួនសរុប៤៧% និងយល់ស្រប

ទាំងស្រុងមានចំនួនសរុប ៨%។

ដូចនេះលទ្ធផលបានបង្ហាញថាកត្តាខាងក្នុងទទួលរងឥទ្ធិពលវិជ្ជមានខ្ពស់ជាងកត្តាខាងក្រៅ និងកត្តាខាងក្រៅទទួលរងឥទ្ធិពលអវិជ្ជមានខ្លាំងជាងកត្តាខាងក្នុង។

**សំណួរស្រាវជ្រាវទី២៖ បញ្ហាប្រឈម និងដំណោះស្រាយ ចំពោះអាកប្បកិរិយាសិស្សនៃការជ្រើសរើសការអប់រំបច្ចេកទេស**

ក្នុងផ្នែកនេះ អ្នកសិក្សានឹងធ្វើការសិក្សាយ៉ាងលម្អិតអំពីបញ្ហាប្រឈម និងដំណោះស្រាយ ចំពោះអាកប្បកិរិយាសិស្សនៃការជ្រើសរើសការអប់រំបច្ចេកទេសទៅលើលទ្ធផលនៃការស្រាវជ្រាវនេះ រួចធ្វើការប្រៀបធៀបលទ្ធផលរវាង សិស្ស គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា ថាតើមានលក្ខណៈដូចម្តេចដែរ។

ក្នុងការសិក្សាស្រាវជ្រាវនេះ មានការចូលរួមពីសិស្សសរុបចំនួន១៣៤នាក់ ស្រីចំនួន៥០នាក់ គ្រូបង្រៀនសរុបចំនួន២០នាក់ ស្រីចំនួន០៥នាក់ នាយកសាលាសរុបចំនួន ០៣នាក់ ស្រីចំនួន០០នាក់ ដែលត្រូវបានយកមកសិក្សាលើប្រធានបទនេះ។

## ៤.២ បញ្ហាប្រឈម

ក្នុងផ្នែកនេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបូកសរុបលទ្ធផលសំខាន់ៗរួមគ្នារវាងសិស្ស គ្រូបង្រៀន និងនាយកសាលា ដែលមានគោលគំនិត្យលើបញ្ហាប្រឈមសំខាន់ៗចំនួន០៧ គឺ ១-ប្រព័ន្ធផ្សព្វផ្សាយរបស់សាលារៀន, ២-ឥទ្ធិពលគ្រូបង្រៀន, ៣-ធនធានហិរញ្ញវត្ថុរបស់សាលា, ៤-កត្តាសេដ្ឋកិច្ចគ្រួសារ, ៥-ឥទ្ធិពលអាណាព្យាបាលសិស្ស, ៦-ការរើសអើងពីមជ្ឈដ្ឋានជុំវិញ, ៧-ឥទ្ធិពលការងារពេលអនាគត។

### ៤.២.១. ប្រព័ន្ធផ្សព្វផ្សាយរបស់សាលា

តារាងទី៤.៤៤ ៖ បញ្ហាប្រឈមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាលើប្រព័ន្ធផ្សព្វផ្សាយរបស់សាលា

| ល.រ | ប្រព័ន្ធផ្សព្វផ្សាយរបស់សាលា | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | ខ្វះកម្មវិធីតម្រង់ទិសដល់អ្នកសិក្សា | 20% | 20% | 0% |
| ២ | ខ្វះការផ្សព្វផ្សាយតាមបណ្តាញសង្គម (ហ្វេសប៊ុក,ផេក...) | 13% | 0% | 0% |
| ៣ | ខ្វះការប្រឹក្សាអាជីពដល់អ្នកសិក្សា | 18% | 15% | 0% |

| | | | | |
|---|---|---|---|---|
| ៤ | មិនដឹងព័ត៌មានពីការជ្រើសរើសសិស្សអប់រំបច្ចេកទេស | 14% | 10% | 0% |
| ៥ | ពិបាកសម្រេចចិត្តជ្រើសរើសជំនាញឱ្យត្រូវនឹងទីផ្សារការងារ | 13% | 15% | 0% |
| | **មធ្យមភាគ** | **16%** | **12%** | **0%** |

សិស្សមានចំនួនសរុប២០% គ្រូបង្រៀនមានចំនួនសរុប២០% ដែលបានលើកឡើងថាសាលាខ្វះកម្មវិធីតម្រង់ទិសដល់អ្នកសិក្សា។ សិស្សមានចំនួនសរុប១៣% ដែលបានលើកឡើងថាសាលាមិនបានធ្វើការផ្សព្វផ្សាយតាមបណ្តាញសង្គម។ សិស្សមានចំនួនសរុប១៨% គ្រូបង្រៀនមានចំនួនសរុប១៥% ដែលបានលើកឡើងថាសាលាខ្វះការប្រឹក្សាអាជីពដល់អ្នកសិក្សា។ សិស្សមានចំនួនសរុប១៤% ដែលបានលើកឡើងថាមិនដឹងព័ត៌មានពីការជ្រើសរើសសិស្សអប់រំបច្ចេកទេស។ សិស្សមានចំនួនសរុប១៣% គ្រូបង្រៀនមានចំនួនសរុប១៥% ដែលបានលើកឡើងថាសិស្សពិបាកសម្រេចចិត្តជ្រើសរើសជំនាញឱ្យត្រូវនឹងទីផ្សារការងារ។

### ៤.២.២ ឥទ្ធិពលគ្រូបង្រៀន

តារាងទី៤.៤៥៖ បញ្ហាប្រឈមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាចំពោះឥទ្ធិពលគ្រូបង្រៀន

| ល.រ | **កត្តាគ្រូបង្រៀន** | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | មានការរារាំងពីគ្រូបង្រៀននៅតាមសាលាគោលដៅមួយចំនួន | 19% | 25% | 67% |
| ២ | សិស្សមិនពេញចិត្តគ្រូបង្រៀនអប់រំបច្ចេកទេស | 5% | 0% | 0% |
| ៣ | គ្រូបង្រៀនមិនបានចូលរួមផ្សព្វផ្សាយពីការសិក្សាជំនាញអប់រំបច្ចេកទេស | 8% | 0% | 0% |
| ៤ | ចំណេះដឹងគ្រូបង្រៀនអប់រំបច្ចេកទេសនៅមានកម្រិត | 2% | 0% | 0% |
| ៥ | មានការផ្លាស់ប្តូរគ្រូអប់រំបច្ចេកទេសញឹកញាប់ | 6% | 10% | 67% |
| **មធ្យមភាគ** | | **8%** | **7%** | **27%** |

សិស្សមានចំនួនសរុប១៩% គ្រូបង្រៀនមានចំនួនសរុប២៥% និងនាយកសាលាមានចំនួនសរុប ៦៧% ដែលបានលើកឡើងថាសិស្សមិនមករៀនជំនាញអប់រំបច្ចេកទេសដោយសារមានការរារាំងពីគ្រូបង្រៀននៅតាមសាលាគោលដៅមួយចំនួន។ សិស្សមានចំនួនសរុប៥% ដែលបានលើកឡើងថាសិស្ស

មិនពេញចិត្តគ្រូបង្រៀនអប់រំបច្ចេកទេស។ សិស្សមានចំនួនសរុប៨% ដែលបានលើកឡើងថាគ្រូបង្រៀនមិនបានចូលរួមផ្សព្វផ្សាយពីការសិក្សាជំនាញអប់រំបច្ចេកទេស។ សិស្សមានចំនួនសរុប៦% គ្រូបង្រៀនមានចំនួនសរុប១០% និងនាយកសាលាមានចំនួនសរុប៦៧% ដែលបានលើកឡើងថាមានការផ្លាស់ប្តូរគ្រូអប់រំបច្ចេកទេសញឹកញ៉ាប់។

### ៤.២.៣ ធនធានហិរញ្ញវត្ថុរបស់សាលា

តារាងទី៤.៤៦៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះធនធានហិរញ្ញវត្ថុរបស់សាលា

| ល.រ | ធនធានហិរញ្ញវត្ថុសាលារៀន | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | សាលាមិនមានការផ្តល់អាហារូបករណ៍ដល់សិស្ស | 19% | 10% | 0% |
| ២ | ខ្វះសម្ភារៈបរិក្ខា,សៀវភៅសិក្សាគោល,ឯកសារ | 28% | 40% | 67% |
| ៣ | សាលាខ្វះថវិកាសម្រាប់ចុះផ្សព្វផ្សាយការអប់រំបច្ចេកទេស | 2% | 20% | 100% |
| ៤ | សាលាមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ផ្សព្វផ្សាយតាមមូលដ្ឋាន និងតំបន់ឆ្ងាយៗ | 1% | 20% | 100% |
| **មធ្យមភាគ** | | **13%** | **23%** | **67%** |

សិស្សមានចំនួនសរុប១៩% គ្រូបង្រៀនមានចំនួនសរុប១០% ដែលបានលើកឡើងថាសាលាមិនមានការផ្តល់អាហារូបករណ៍ដល់សិស្ស។ សិស្សមានចំនួនសរុប២៨% គ្រូបង្រៀនមានចំនួនសរុប៤០% និងនាយកសាលាមានចំនួនសរុប៦៧% ដែលបានលើកឡើងថាសាលារៀនខ្វះសម្ភារបរិក្ខា,សៀវភៅសិក្សាគោល,ឯកសារសម្រាប់សិក្សា។ សិស្សមានចំនួនសរុប២% គ្រូបង្រៀនមានចំនួនសរុប២០% និងនាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថាសាលាខ្វះថវិកាសម្រាប់ចុះផ្សព្វផ្សាយពីជំនាញអប់រំបច្ចេកទេស។ សិស្សមានចំនួនសរុប១% គ្រូបង្រៀនមានចំនួនសរុប២០% និងនាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថាសាលាមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ផ្សព្វផ្សាយតាមមូលដ្ឋាន និងតំបន់ឆ្ងាយៗ។

### ៤.២.៤ កត្តាសេដ្ឋកិច្ចគ្រួសារ

តារាងទី៤.៤៧៖ បញ្ហាប្រឈមរវាងសិស្ស គ្រូបង្រៀន និងនាយកសាលាចំពោះកត្តាសេដ្ឋកិច្ចគ្រួសារ

| ល.រ | សេដ្ឋកិច្ចគ្រួសារ | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | ផ្ទះឆ្ងាយពីសាលាពិបាកធ្វើដំណើរ និងចំណាយច្រើន | 20% | 17% | 33% |
| ២ | ជីវភាពខ្វះខាត(មិនមានថវិកាសម្រាប់សិក្សា) | 17% | 20% | 67% |
| ៣ | ផ្ទះឆ្ងាយត្រូវមកស្នាក់នៅសាលារៀន (ចំណាយថវិកាសម្រាប់ម្ហូបអាហារ) | 24% | 30% | 33% |
| **មធ្យមភាគ** | | **20%** | **22%** | **44%** |

សិស្សមានចំនួនសរុប២០% គ្រូបង្រៀនមានចំនួនសរុប១៧% និងនាយកសាលាមានចំនួនសរុប៣៣% ដែលបានលើកឡើងថាសិស្សផ្ទះឆ្ងាយពីសាលារៀនពិបាកធ្វើដំណើរ និងចំណាយច្រើន។ សិស្សមានចំនួនសរុប១៧% គ្រូបង្រៀនមានចំនួនសរុប២០% និងនាយកសាលាមានចំនួនសរុប៦៧% ដែលបានលើកឡើងថាសិស្សមានជីវភាពខ្វះខាត(មិនមានថវិកាសម្រាប់សិក្សា)។ សិស្សមានចំនួនសរុប២៤% គ្រូបង្រៀនមានចំនួនសរុប៣០% និងនាយកសាលាមានចំនួនសរុប៣៣% ដែលបានលើកឡើងថាសិស្សមានផ្ទះឆ្ងាយត្រូវមកស្នាក់នៅសាលារៀន(ចំណាយថវិកាសម្រាប់ម្ហូបអាហារ)។

### ៤.២.៥ ឥទ្ធិពលអាណាព្យាបាលសិស្ស

តារាងទី៤.៤៨៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះឥទ្ធិពលអាណាព្យាបាលសិស្ស

| ល.រ | ឥទ្ធិពលអាណាព្យាបាល | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | ឪពុកម្តាយជំទាស់មិនឱ្យរៀនជំនាញអប់រំបច្ចេកទេស | 16% | 45% | 100% |
| ២ | អាណាព្យាបាលសិស្សខ្វះការយល់ដឹងពីការអប់រំជំនាញបច្ចេកទេស | 11% | 35% | 100% |
| ៣ | ឪពុកម្តាយយល់ថារៀនជំនាញអប់រំបច្ចេកទេសគឺសម្រាប់តែសិស្សរៀនខ្សោយប៉ុណ្ណោះ | 7% | 10% | 0% |
| ៤ | ឪពុកម្តាយមិនទុកចិត្តឱ្យកូនមកស្នាក់នៅសាលា | 10% | 35% | 67% |
| ៥ | ពួកគាត់យល់ថារៀនជំនាញអប់រំបច្ចេកទេសពិបាករកការងារធ្វើ | 13% | 25% | 33% |
| **មធ្យមភាគ** | | **11%** | **30%** | **60%** |

សិស្សមានចំនួនសរុប១៦% គ្រូបង្រៀនមានចំនួនសរុប៤៥% និងនាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថាឪពុកម្តាយជំទាស់មិនឱ្យរៀនជំនាញអប់រំបច្ចេកទេស។ សិស្សមានចំនួន

សរុប១១% គ្រូបង្រៀនមានចំនួនសរុប៣៥% និងនាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថាអាណាព្យាបាលសិស្សខ្វះការយល់ដឹងពីការអប់រំជំនាញបច្ចេកទេស។ សិស្សមានចំនួនសរុប៧% គ្រូបង្រៀនមានចំនួនសរុប១០% ដែលបានលើកឡើងថាអាណាព្យាបាលសិស្សយល់ថារៀនជំនាញអប់រំបច្ចេកទេសគឺសម្រាប់តែសិស្សរៀនខ្សោយប៉ុណ្ណោះ។ សិស្សមានចំនួនសរុប១០% គ្រូបង្រៀនមានចំនួនសរុប៣៥% និងនាយកសាលាមានចំនួនសរុប៦៧% ដែលបានលើកឡើងថាឪពុកម្តាយមិនទុកចិត្តឱ្យកូនមកស្នាក់នៅសាលារៀន។ សិស្សមានចំនួនសរុប១៣% គ្រូបង្រៀនមានចំនួនសរុប២៥% និងនាយកសាលាមានចំនួនសរុប៣៣% ដែលបានលើកឡើងថា អាណាព្យាបាលសិស្សយល់ថារៀនជំនាញអប់រំបច្ចេកទេសពិបាករកការងារធ្វើ។

### ៤.២.៦ ការរើសអើងពីមជ្ឈដ្ឋានជុំវិញ

តារាងទី៤.៤៩ ៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះការរើសអើងពីមជ្ឈដ្ឋានជុំវិញ

| ល.រ | ឥទ្ធិពលនៃការរើសអើងពីមជ្ឈដ្ឋានជុំវិញ | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | មិត្តភ័ក្តសើចចំអកថាខ្លួនជាស្ត្រីមិនសមមករៀនជំនាញអប់រំបច្ចេកទេសទេ | 16% | 18% | 33% |
| ២ | មិត្តភ័ក្តរើសអើងថាខ្លួនជាស្ត្រីមិនមានសមត្ថភាពគ្រប់គ្រាន់សម្រាប់រៀនជំនាញនេះទេ | 11% | 10% | 0% |
| ៣ | អ្នកដទៃយល់ថារៀនជំនាញនេះមានបញ្ហា និងគ្រោះថ្នាក់ច្រើន | 7% | 0% | 0% |
| ៤ | មានការរិះគន់ និងមិនពេញចិត្តពីអ្នកជិតខាងពេលជ្រើសរើសរៀនជំនាញនេះ | 9% | 10% | 67% |
| **មធ្យមភាគ** | | **11%** | **10%** | **25%** |

សិស្សមានចំនួនសរុប១៦% គ្រូបង្រៀនមានចំនួនសរុប១៨% និងនាយកសាលាមានចំនួនសរុប៣៣% ដែលបានលើកឡើងថាមិត្តភ័ក្តសើចចំអកថាខ្លួនជាស្ត្រីមិនសមមករៀនជំនាញអប់រំបច្ចេកទេសទេ។ សិស្សមានចំនួនសរុប១១% គ្រូបង្រៀនមានចំនួនសរុប១០% ដែលបានលើកឡើងថាមិត្តភ័ក្តរើសអើងថាខ្លួនជាស្ត្រីមិនមានសមត្ថភាពគ្រប់គ្រាន់សម្រាប់រៀនជំនាញអប់រំបច្ចេកទេសទេ។ សិស្សមានចំនួនសរុប៧% ដែលបានលើកឡើងថាអ្នកផ្សេងយល់ថារៀនជំនាញនេះមានបញ្ហា និងមានគ្រោះថ្នាក់

ច្រើន។ សិស្សមានចំនួនសរុប៩% គ្រូបង្រៀនមានចំនួនសរុប១០% និងនាយកសាលាមានចំនួនសរុប ៦៧% ដែលបានលើកឡើងថា សិស្សរៀនជំនាញអប់រំបច្ចេកទេសមានការរិះគន់ និងមានការមិនពេញចិត្តពីអ្នកជិតខាងពេលជ្រើសរើសរៀនជំនាញនេះ។

### ៤.២.៧ ឥទ្ធិពលការងារពេលអនាគត

តារាងទី៤.៥០៖ បញ្ហាប្រឈមរវាងសិស្ស គ្រូ និងនាយកសាលាចំពោះឥទ្ធិពលការងារពេលអនាគត

| ល.រ | ឥទ្ធិពលនៃការងារពេលអនាគត | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | សង្គមមិនសូវឱ្យតម្លៃទៅលើសញ្ញាបត្រអប់រំបច្ចេកទេស | 41% | 35% | 100% |
| ២ | ពិបាករកការងារធ្វើពេលរៀនចប់ | 34% | 10% | 0% |
| ៣ | តម្រូវការការងារនៅតាមសហគ្រាស រោងចក្រ និងក្រុមហ៊ុននានានៅមានកម្រិត | 13% | 30% | 33% |
| **មធ្យមភាគ** | | **29%** | **25%** | **44%** |

សិស្សមានចំនួនសរុប៤១% គ្រូបង្រៀនមានចំនួនសរុប៣៥% និងនាយកសាលាមានចំនួនសរុប ១០០% ដែលបានលើកឡើងថាសង្គមមិនសូវឱ្យតម្លៃទៅលើសញ្ញាបត្រអប់រំបច្ចេកទេសទេ។ សិស្សមានចំនួនសរុប៣៤% គ្រូបង្រៀនមានចំនួនសរុប១០% ដែលបានលើកឡើងថា សិស្សពិបាករកការងារធ្វើពេលរៀនចប់។ សិស្សមានចំនួនសរុប១៣% គ្រូបង្រៀនមានចំនួនសរុប៣០% និងនាយកសាលាមានចំនួនសរុប៣៣% ដែលបានលើកឡើងថា តម្រូវការការងារនៅតាមសហគ្រាស រោងចក្រ និងក្រុមហ៊ុននានានៅមានកម្រិត។

### ៤.២.៨ លទ្ធផលរួមនៃគោលគំនិតលើបញ្ហាប្រឈម

តារាងទី៤.៥១៖ លទ្ធផលរួមនៃគោលគំនិតលើបញ្ហាប្រឈម

| ល.រ | បញ្ហាប្រឈម | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | ប្រព័ន្ធផ្សព្វផ្សាយរបស់សាលា | 16% | 12% | 0% |
| ២ | ឥទ្ធិពលគ្រូបង្រៀន | 8% | 7% | 27% |
| ៣ | ធនធានហិរញ្ញវត្ថុរបស់សាលា | 13% | 23% | 67% |
| ៤ | សេដ្ឋកិច្ចគ្រួសារ | 20% | 22% | 44% |

| | | | | |
|---|---|---|---|---|
| ៥ | ឥទ្ធិពលអាណាព្យាបាលសិស្ស | 11% | 30% | 60% |
| ៦ | ការរើសអើងពីមជ្ឈដ្ឋានជុំវិញ | 11% | 10% | 25% |
| ៧ | ឥទ្ធិពលការងារពេលអនាគត | 29% | 25% | 44% |
| **មធ្យមភាគ** | | **15%** | **18%** | **38%** |

លទ្ធផលជារួមនៃគោលគំនិត្យលើបញ្ហាប្រឈមបានបង្ហាញថា៖ សិស្សមានចំនួនសរុប១៦% គ្រូបង្រៀនមានចំនួនសរុប១២% ដែលបានលើកឡើងថាសាលារៀនមិនទាន់បានផ្សព្វផ្សាយពីការជ្រើសរើសសិស្សឱ្យចូលរៀនជំនាញការអប់រំបច្ចេកទេសឱ្យបានទូលំទូលាយនៅឡើយទេ។ សិស្សមានចំនួនសរុប៨% គ្រូបង្រៀនមានចំនួនសរុប៧% និងនាយកសាលាមានចំនួនសរុប២៧% ដែលបានលើកឡើងថា គ្រូបង្រៀនក៏ជាផ្នែកមួយនៃការរាំរាំងសិស្សមិនឱ្យជ្រើសរើសជំនាញអប់រំបច្ចេកទេស។ សិស្សមានចំនួនសរុប១៣% គ្រូបង្រៀនមានចំនួនសរុប២៣% និងនាយកសាលាមានចំនួនសរុប៦៧% ដែលបានលើកឡើងថា សាលាមិនមានថវិកាគ្រប់គ្រាន់សម្រាប់ធ្វើការផ្សព្វផ្សាយ គាំទ្រ និងទាក់ទាញអ្នកសិក្សាមកចាប់អារម្មណ៍ជ្រើសរើសរៀនជំនាញអប់រំបច្ចេកទេសនៅឡើយទេ។ សិស្សមានចំនួនសរុប២០% គ្រូបង្រៀនមានចំនួនសរុប២២% និងនាយកសាលាមានចំនួនសរុប៤៤% ដែលបានលើកឡើងថាសេដ្ឋកិច្ចគ្រួសារសិស្សក៏ជាឧបសគ្គមួយចំណែកផងដែរដែលថាសិស្សចង់មករៀនជំនាញអប់រំបច្ចេកទេសនេះដែរតែដោយសារជីវភាពគ្រួសាររបស់ពួកគេមានការខ្វះខាត និងមានការលំបាកក្នុងការចំណាយលើការសិក្សារៀនសូត្រនេះ។ សិស្សមានចំនួនសរុប១១% គ្រូបង្រៀនមានចំនួនសរុប៣០% និងនាយកសាលាមានចំនួនសរុប៦០% ដែលបានលើកឡើងថាអាណាព្យាបាលសិស្សក៏ជាផ្នែកមួយដែលមានឥទ្ធិពលយ៉ាងសំខាន់ផងដែរក្នុងការសម្រេចចិត្តរបស់កូនៗរបស់ពួកគាត់នៃការជ្រើសរើសការអប់រំបច្ចេកទេសនេះ។ សិស្សមានចំនួនសរុប១១% គ្រូបង្រៀនមានចំនួនសរុប១០% និងនាយកសាលាមានចំនួនសរុប២៥% ដែលបានលើកឡើងថាសិស្សដែលជ្រើសរើសរៀនជំនាញអប់រំបច្ចេកទេសគឺមានការរិះគន់ រើសអើង និងបំបាក់ទឹកចិត្តពួកគេលែងចង់រៀនជំនាញនេះទៀត។ សិស្សមានចំនួនសរុប២៩% គ្រូបង្រៀនមានចំនួនសរុប២៥% និងនាយកសាលាមានចំនួនសរុប៤៤% ដែលបានលើកឡើងថាពេលរៀនចប់ពិបាករកការងារធ្វើ សង្គម មិនសូវឱ្យតម្លៃទៅលើសញ្ញាបត្រអប់រំបច្ចេកទេស និងមិនសូវមានតម្រូវការការងារច្រើននៅតាមសហគ្រាស

រោងចក្រ និងក្រុមហ៊ុននានា។

សរុបជារួមមក បញ្ហាប្រឈមនៃការជ្រើសរើសការអប់រំបច្ចេកទេសនេះបានបង្ហាញថាការលើកឡើងរបស់សិស្សានុសិស្សមានចំនួនសរុបចំនួន១៥% គ្រូបង្រៀនមានចំនួនសរុប១៨% និងនាយកសាលាមានចំនួនសរុប៣៨%។

## ៤.៣ ដំណោះស្រាយនៃបញ្ហាប្រឈម

ក្នុងផ្នែកនេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបូកសរុបលទ្ធផលរួមគ្នារវាងសិស្ស គ្រូបង្រៀន និងនាយកសាលា ដែលមានគោលគំនិត្យលើដំណោះស្រាយសំខាន់ៗចំនួន០៣ គឺ ១-រៀបចំផែនការចុះផ្សព្វផ្សាយ, ២-ផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា, ៣-ប្រឹក្សាអាជីព និងតម្រង់ទិសសិស្ស។

### ៤.៣.១ រៀបចំផែនការចុះផ្សព្វផ្សាយ

តារាងទី៤.៥២ ៖ ដំណោះស្រាយរវាងសិស្ស គ្រូ និងនាយកសាលាក្នុងការរៀបចំផែនការចុះផ្សព្វផ្សាយ

| ល.រ | រៀបចំផែនការចុះផ្សព្វផ្សាយ | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់អ្នកសិក្សា | 75% | 90% | 100% |
| ២ | ផ្សព្វផ្សាយដល់អាណាព្យាបាលសិស្សនិងសហគមន៍ | 37% | 85% | 100% |
| ៣ | ផ្សព្វផ្សាយតាមអនុវិទ្យាល័យ និងវិទ្យាល័យនានាទូទាំងខេត្ត | 17% | 95% | 100% |
| ៤ | ធ្វើសំណើសុំការសហការពីភាគីពាក់ព័ន្ធនានាដើម្បីជួយផ្សព្វផ្សាយបន្ត និងលើកទឹកចិត្តអ្នកសិក្សាមករៀនជំនាញអប់រំបច្ចេកទេស | 0% | 90% | 100% |
| **មធ្យមភាគ** | | **32%** | **90%** | **100%** |

សិស្សមានចំនួនសរុប៧៥% គ្រូបង្រៀនមានចំនួនសរុប៩០% និងនាយកសាលាមានចំនួនសរុប ១០០% ដែលបានលើកឡើងថាសាលាត្រូវចំផែនការចុះផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់អ្នកសិក្សា។ សិស្សមានចំនួនសរុប៣៧% គ្រូបង្រៀនមានចំនួនសរុប៨៥% និងនាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថាសាលាត្រូវធ្វើយ៉ាងណាចុះផ្សព្វផ្សាយដល់អាណាព្យាបាលសិស្ស និងសហគមន៍ ដើម្បីឱ្យពួកគាត់យល់ឱ្យបានច្បាស់ពីសារប្រយោជន៍ និងគុណសម្បត្តិនៃការជ្រើសរើសជំនាញបច្ចេកទេស

នេះ។ សិស្សមានចំនួនសរុប១៧% គ្រូបង្រៀនមានចំនួនសរុប៩៥% និងនាយកសាលាមានចំនួនសរុប ១០០% ដែលបានលើកឡើងថាសាលាត្រូវរៀបចំផែនការចុះផ្សព្វផ្សាយតាមអនុវិទ្យាល័យ និងវិទ្យាល័យ នានាទូទាំងខេត្តឱ្យបានគ្រប់តាមផែនការដែលបានគ្រោងទុក។ គ្រូបង្រៀនមានចំនួនសរុប៩០% និង នាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថាសាលាត្រូវធ្វើសំណើសុំការសហការពីភាគី ពាក់ព័ន្ធនានាដើម្បីជួយផ្សព្វផ្សាយបន្ត និងលើកទឹកចិត្តដល់អ្នកសិក្សាមកចាប់អារម្មណ៍ជំនាញអប់រំ បច្ចេកទេសនេះ។

### ៤.៣.២ ផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា

តារាងទី៤.៥៣៖ ដំណោះស្រាយក្នុងការផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា

| ល.រ | ផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | អាហារូបករណ៍ | 37% | 75% | 100% |
| ២ | កន្លែងស្នាក់នៅ | 34% | 85% | 100% |
| ៣ | ទស្សនកិច្ចសិក្សា | 71% | 100% | 100% |
| ៤ | ចំណេះដឹង និងជំនាញច្បាស់លាស់ | 54% | 90% | 100% |
| ៥ | ផ្តល់ការងារដល់អ្នកសិក្សា | 19% | 75% | 67% |
| **មធ្យមភាគ** | | **43%** | **85%** | **93%** |

សិស្សមានចំនួនសរុប៣៧% គ្រូបង្រៀនមានចំនួនសរុប៧៥% និងនាយកសាលាមានចំនួនសរុប ១០០% ដែលបានលើកឡើងថាសាលាត្រូវផ្តល់អាហារូបករណ៍ដល់អ្នកសិក្សាឱ្យបានកាន់តែច្រើន។ សិស្សមានចំនួនសរុប៣៤% គ្រូបង្រៀនមានចំនួនសរុប៨៥% និងនាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថា សាលាមានកន្លែងឱ្យសិស្សស្នាក់នៅសម្រាប់សិក្សារៀនសូត្រដោយមិនមានការ រើសអើង។ សិស្សមានចំនួនសរុប៧១% គ្រូបង្រៀនមានចំនួនសរុប១០០% និងនាយកសាលាមានចំនួន សរុប១០០% ដែលបានលើកឡើងថាសាលាត្រូវមានផែនការឱ្យសិស្សធ្វើទស្សនកិច្ចសិក្សាឱ្យបានកាន់តែ ច្រើន និងគ្រប់កម្រិតថ្នាក់ថែមទៀត។ សិស្សមានចំនួនសរុប៥៤% គ្រូបង្រៀនមានចំនួនសរុប៩០% និង

នាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថាសាលាត្រូវតែផ្ទេរ ផ្តល់នូវចំណេះ និង ជំនាញយ៉ាងច្បាស់លាស់ដល់អ្នកសិក្សា។ សិស្សមានចំនួនសរុប១៩% គ្រូបង្រៀនមានចំនួនសរុប៧៥% និងនាយកសាលាមានចំនួនសរុប៦៧% ដែលបានលើកឡើងថាសាលាត្រូវមានដំណោះស្រាយសហការ ជាមួយដៃគូរនានាដើម្បីស្វែងរកការងារឱ្យសិស្សឱ្យបានច្រើន។

### ៤.៣.៣ ផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្ស

តារាងទី៤.៥៤ ៖ ដំណោះស្រាយក្នុងការផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្ស

| ល.រ | ផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្ស | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | រៀបចំសេវាប្រឹក្សាអាជីពដល់អ្នកសិក្សា | 34% | 85% | 100% |
| ២ | ផ្តល់ការណែនាំដល់អ្នកសិក្សា | 28% | 90% | 100% |
| ៣ | ចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក | 22% | 65% | 100% |
| ៤ | ផ្តល់ព័ត៌មានតម្រូវការការងារ | 41% | 75% | 100% |
| **មធ្យមភាគ** | | **31%** | **79%** | **100%** |

សិស្សមានចំនួនសរុប៣៤% គ្រូបង្រៀនមានចំនួនសរុប៨៥% និងនាយកសាលាមានចំនួនសរុប ១០០% ដែលបានលើកឡើងថាសាលាត្រូវរៀបចំសេវាប្រឹក្សាអាជីពដល់អ្នកសិក្សា។ សិស្សមានចំនួន សរុប២៨% គ្រូបង្រៀនមានចំនួនសរុប៩០% និងនាយកសាលាមានចំនួនសរុប១០០%ដែលបានលើក ឡើងថា សាលាត្រូវរៀបចំការផ្តល់ការណែនាំដល់អ្នកសិក្សានៃការជ្រើសរើសជំនាញអប់រំបច្ចេកទេស។ សិស្សមានចំនួនសរុប២២% គ្រូបង្រៀនមានចំនួនសរុប៦៥% និងនាយកសាលាមានចំនួនសរុប១០០% ដែលបានលើកឡើងថាសាលាត្រូវរៀបចំកម្មវិធីចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក រវាងអ្នកសិក្សា នឹងអ្នកសិក្សាដូចគ្នា។ សិស្សមានចំនួនសរុប៤១% គ្រូបង្រៀនមានចំនួនសរុប៧៥% និងនាយកសាលា មានចំនួនសរុប១០០% ដែលបានលើកឡើងថាសាលាត្រូវរៀបចំសេវាផ្តល់ព័ត៌មានអំពីតម្រូវការការងារ តាមជំនាញនីមួយៗយ៉ាងច្បាស់លាស់។

## ៤.៣.៤ លទ្ធផលរួមនៃដំណោះស្រាយលើបញ្ហាប្រឈម

តារាងទី៤.៥៥ ៖ លទ្ធផលរួមនៃដំណោះស្រាយលើបញ្ហាប្រឈម

| ល.រ | ដំណោះស្រាយ | សិស្ស | គ្រូបង្រៀន | នាយកសាលា |
|---|---|---|---|---|
| ១ | សាលារៀបចំផែនការចុះផ្សព្វផ្សាយ | 32% | 90% | 100% |
| ២ | ផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សា | 43% | 85% | 93% |
| ៣ | ផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្ស | 31% | 79% | 100% |
| **មធ្យមភាគ** | | **35%** | **85%** | **98%** |

លទ្ធផលជារួមនៃគោលគំនិត្យលើដំណោះស្រាយបានបង្ហាញថា៖ សិស្សមានចំនួនសរុប៣២% គ្រូបង្រៀនមានចំនួនសរុប៩០% និងនាយកសាលាមានចំនួនសរុប១០០% បានលើកឡើងថាសាលាត្រូវរៀបចំផែនការចុះផ្សព្វផ្សាយតាមគ្រប់រូបភាពដើម្បីឱ្យអ្នកសិក្សាបានទទួលព័ត៌មានពីការសិក្សាជំនាញអប់រំបច្ចេកទេសនេះ។ សិស្សមានចំនួនសរុប៤៣% គ្រូបង្រៀនមានចំនួនសរុប៨៥% និងនាយកសាលាមានចំនួនសរុប៩៣% បានលើកឡើងថាសាលាត្រូវរៀនបានផ្តល់អត្ថប្រយោជន៍តាមសកម្មភាពផ្សេងៗដល់អ្នកសិក្សាដើម្បីទាក់ទាញអ្នកសិក្សាមកជ្រើសរើសជំនាញនេះ។ សិស្សមានចំនួនសរុប៣១% គ្រូបង្រៀនមានចំនួនសរុប៧៩% និងនាយកសាលាមានចំនួនសរុប១០០% បានលើកឡើងថាសាលារៀនត្រូវរៀបចំផ្តល់ប្រឹក្សាអាជីព និងតម្រង់ទិសសិស្សដល់អ្នកសិក្សាដែលចង់មកទទួលសេវានេះ។

សរុបជារួមមក ដំណោះស្រាយដើម្បីទាក់ទាញសិស្សឱ្យមកចាប់អារម្មណ៍ការជ្រើសរើសជំនាញអប់រំបច្ចេកទេសនេះបានលើកឡើងរបស់សិស្សានុសិស្សមានចំនួនសរុបចំនួន៣៥% គ្រូបង្រៀនមានចំនួនសរុប៨៥% និងនាយកសាលាមានចំនួនសរុប៩៨%។

## ៤.៤ ការពិភាក្សា

ឆ្លងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ និងយោងតាមទ្រឹស្តីដែលបានលើកឡើងនៅក្នុងជំពូកទី២ បានបង្ហាញថា កត្តាដែលជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សដោយគិតទៅលើ កត្តាខាងក្នុង( ឥទ្ធិពលចំណាប់អារម្មណ៍, ឥទ្ធិពលភេទ, ឥទ្ធិពលអាយុ, ឥទ្ធិពលសមត្ថភាព, ឥទ្ធិពលតម្រូវការការសិក្សា និងការអប់រមបច្ចេកទេស) និងកត្តាខាងក្រៅ( ឥទ្ធិពលអាណាព្យាបាលសិស្ស, ឥទ្ធិពលមិត្តភ័ក្ត, ឥទ្ធិពលគ្រូ

បង្រៀន, ឥទ្ធិពលថ្នាក់រៀន និងសាលារៀន, ឥទ្ធិពលអាជីព និងសក្តានុពលការងារនាពេលអនាគត។ កត្តាទាំងពីរនេះ ជាកត្តាដែលមានឥទ្ធិពលដល់ការសម្រេចចិត្តជ្រើសរើសជំនាញអប់រំបច្ចេកទេសរបស់សិស្ស។

### ៤.៣.១ កត្តាដែលមានឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេស

#### ៤.៣.១.១ សំណួរស្រាវជ្រាវទី១

#### ក.កត្តាខាងក្នុង

កត្តាចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស មានកម្រិតយល់ស្របចំនួនសរុប៥៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៣% នេះបញ្ជាក់ឱ្យឃើញថាសិស្សដែលបានចូលរៀនជំនាញអប់រំ បច្ចេកទេសភាគច្រើនជាការការសម្រេចចិត្ត និងជ្រើសរើសរៀនដោយខ្លួនឯងផ្ទាល់។ បើតាមការសិក្សារបស់ Calkins & AWelki ( 2006 ) បានរកឃើញថា កត្តាដែលមានឥទ្ធិពលបំផុតសម្រាប់ជ្រើសរើសមុខវិជ្ជាក្នុងការសិក្សារបស់សិស្ស គឺកត្តាចំណាប់អារម្មណ៍របស់សិស្សផ្ទាល់ទៅលើការជ្រើសរើសមុខវិជ្ជានោះ។ បើតាម Wally-Dima (2013) បានសិក្សារកឃើញថាសិស្សនៅកម្រិតថ្នាក់វិទ្យាល័យ គឺមានចំណាប់អារម្មណ៍ខ្ពស់លើមុខវិជ្ជា។

កត្តាភេទសិស្ស មានកម្រិតយល់ស្របចំនួនសរុប២២% និងយល់ស្របទាំងស្រុងមានចំនួនសរុប៦% លទ្ធផលនេះអាចបញ្ជាក់បានថាការរើសអើងភេទ គឺជាបញ្ហាប្រឈមមួយដែលធ្វើឱ្យសិស្សពិបាកសម្រេចចិត្តជ្រើសរើសជំនាញអប់រំបច្ចេកទេសសម្រាប់សិក្សារៀនសូត្រ។ យោងតាមការសិក្សារបស់ Huruma (2015) បានសិក្សាទៅលើកត្តាភេទ ពិតជាមានឥទ្ធិពលខ្លាំងក្នុងការជ្រើសរើសមុខវិជ្ជាសិក្សារបស់សិស្ស។ ការសិក្សានេះ ក៏បានរកឃើញថា សិស្សស្រីជ្រើសរើសមុខវិជ្ជា គឺទៅតាមមុខវិជ្ជាជាក់លាក់ដែលគេកំពុងធ្វើការសិក្សានៅក្នុងថ្នាក់ ស្របពេលដែលសិស្សប្រុសវិញជ្រើសរើសមុខវិជ្ជាអាស្រ័យលើមុខរបរដែលស្របទៅតាមតម្រូវការទីផ្សារ ដែលទាក់ទងនឹងមុខវិជ្ជាដែលពួកគេកំពុងសិក្សា។

កត្តាសមត្ថភាពសិស្ស មានកម្រិតយល់ស្របចំនួនសរុប៣៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១៥% លទ្ធផលនេះអាចបញ្ជាក់បានថាឥទ្ធិពលនៃសមត្ថភាពក៏ជាចំណែកមួយក្នុងការសម្រេចចិត្តជ្រើសរើសមុខវិជ្ជា ឬជំនាញផងដែរ។ បើតាមការសិក្សាមួយរបស់ Huruma (2015 ) បានសិក្សារកឃើញ

ថាកត្តាសមត្ថភាពរបស់សិស្ស ជាកត្តានៃការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សានៅកម្រិតវិទ្យាល័យ។ ការសិក្សាផ្សេងទៀតបានសិក្សាដូចគ្នាដែរថា កត្តាសមត្ថភាព និងកត្តាចំណាប់អារម្មណ៍របស់សិស្ស គឺជាកត្តាសំខាន់ ក្នុងការជ្រើសរើសមុខវិជ្ជាតាមមហាវិទ្យាល័យ (Beggs, Bamtham & Taylor, 2008)។

កត្តាតម្រូវការការសិក្សា និងការងារ មានកម្រិតយល់ស្របចំនួនសរុប៣៨% និងយល់ស្របទាំងស្រុងមានចំនួនសរុប៣៥% លទ្ធផលនេះអាចបញ្ជាក់បានថាសិស្សជ្រើសរើសរៀនជំនាញអប់រំបច្ចេកទេសដោយសារសាលាបានផ្តល់ផលប្រយោជន៍ និងផ្តល់ឱកាសការងារដល់ពួកគាត់។ ការសិក្សារបស់ Sof (2016) សិស្សានុសិស្សនៅកម្រិតអនុវិទ្យាល័យក្នុងប្រទេសឥណ្ឌា បានជ្រើសមុខវិជ្ជា ឬជំនាញដោយពួកគេគិតទៅលើ កត្តាការងារ នៅពេលពួកគេបញ្ចប់ការសិក្សារបស់ពួកគេ។

**ខ.កត្តាខាងក្រៅ**

កត្តាអាណាព្យាបាលសិស្ស មានកម្រិតយល់ស្របចំនួនសរុប៣៩% និងយល់ស្របទាំងស្រុងមានចំនួនសរុប១២% លទ្ធផលនេះអាចបញ្ជាក់បានថាឪពុកម្តាយដែលចង់ឱ្យកូនរៀនជំនាញអប់រំបច្ចេកទេសនៅមានកម្រិតទាប។ ការសិក្សារបស់ Ahmed & Maryam (2016) បានរកឃើញថាសិស្សភាគច្រើនមានគំនិតអវិជ្ជមាន ចំពោះមុខវិជ្ជាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដោយសារពួកគេទទួលរងឥទ្ធិពលពីក្រុមគ្រួសាររបស់ពួកគេ។ ដូចគ្នានឹងការសិក្សារបស់ Goyette & Mullen (2006) បានរកឃើញថា កម្រិតអប់រំរបស់អាណាព្យាបាល គឺមានឥទ្ធិពលយ៉ាងខ្លាំង ចំពោះការសម្រេចចិត្តលើការសិក្សារបស់កូនៗរបស់ពួកគេទៅលើមុខវិជ្ជាសម្រាប់មកសិក្សា។

កត្តាមិត្តភ័ក្តសិស្ស មានកម្រិតយល់ស្របចំនួនសរុប២៤% និងយល់ស្របទាំងស្រុងមានចំនួនសរុប២% លទ្ធផលនេះអាចបញ្ជាក់បានថាសិស្សដែលជ្រើសរើសរៀនជំនាញអប់រំបច្ចេកទេសតាមមិត្តភ័ក្តមានតែ២៦%ប៉ុណ្ណោះ។ ការសិក្សាមួយជាមួយសិស្សកម្ពុជា បានបង្ហាញថាកត្តាមិត្តភក្តិ មានឥទ្ធិពលតិចបំផុតលើការជ្រើសរើសមុខវិជ្ជាសិក្សាគឺមានតែ១% បើប្រៀបធៀបទៅនឹងកត្តាផ្សេងៗទៀត(Yep, 2008)។ ការសិក្សាស្រាវជ្រាវបានបង្ហាញថាសិស្សភាគច្រើនបានជ្រើសរើសមុខវិជ្ជាសម្រាប់សិក្សាតាម និងដូចគ្នាជាមួយមិត្តជិតស្និទ្ធរបស់ពួកគេ(Alnaqbi, 2015)។

កត្តាគ្រូបង្រៀន មានកម្រិតយល់ស្របចំនួនសរុប៥៤% និងយល់ស្របទាំងស្រុងមានចំនួនសរុប ១០% លទ្ធផលនេះអាចបញ្ជាក់បានថាឥទ្ធិពលនៃគ្រូបង្រៀនក្នុងការរួមចំណែកជាមួយសាលាគឺមិនទាន់បានទូលំទូលាយនៅឡើយទេ។ បើតាមការសិក្សារបស់ Athanasou & Petoumenos (1998) បានបង្ហាញថា គ្រូបង្រៀនអាចមានឥទ្ធិពល ក្នុងការលើកទឹកចិត្តសិស្សតាមរយៈទិដ្ឋភាពជាក់លាក់ នៃការបង្រៀនរបស់ពួកគាត់ ប៉ុន្តែរឿងដែលសំខាន់ គឺតាមរយៈ ការតម្រង់ទិសរបស់ពួកគាត់។ បើតាមការសិក្សារបស់ Khaled (2013) បានបង្ហាញថា សេចក្តីសាទរ និងការចូលរួមរបស់គ្រូបង្រៀន បានធ្វើឱ្យមានឥទ្ធិពលជាវិជ្ជមាន ចំពោះការសិក្សាផ្នែកជំនាញវិជ្ជាជីវៈរបស់សិស្សានុសិស្សនៅវិទ្យាល័យ។

កត្តាថ្នាក់រៀន និងសាលារៀន មានកម្រិតយល់ស្របចំនួនសរុប៥៣% និងយល់ស្របទាំងស្រុងមានចំនួនសរុប៨% លទ្ធផលនេះអាចបញ្ជាក់បានថាការផ្សព្វផ្សាយ និងការផ្តល់សេវាជួយសិស្សមិនទាន់ទូលំទូលាយនៅឡើយទេ។ តាមរយៈការសិក្សាមួយរបស់ Komba (2014) បានបង្ហាញថា កត្តាសាលារៀនបានរួមចំណែកផងដែរក្នុងការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សានោះ។ បរិយាកាសសិក្សាក្នុងថ្នាក់សំដៅលើលំហ ឬជាកន្លែងដែលអ្នកសិក្សា/សិស្ស និងគ្រូមានអន្តរកម្មជាមួយគ្នា ហើយប្រើប្រាស់ឧបករណ៍ និងធនធានព័ត៌មានផ្សេងៗក្នុងការបន្តការសិក្សា (Wilson, 1996)។

កត្តាអាជីព និងសក្តានុពលការងារនាពេលអនាគត មានកម្រិតយល់ស្របចំនួនសរុប៦៥% និងយល់ស្របទាំងស្រុងមានចំនួនសរុប៧% លទ្ធផលនេះអាចបញ្ជាក់បានថាសាលាបានរៀបចំការផ្តល់សេវា និងការផ្តល់ប្រឹក្សាអាជីពដល់អ្នកមានតម្រូវការសេវានេះ។ Stanislav (2019) បានសិក្សាស្រាវជ្រាវឃើញថា ការងារបច្ចុប្បន្ន និងការងារនាពេលអនាគតមានឥទ្ធិពលលើជម្រើសរបស់សិស្ស។ បើតាម Tripney, Newman, Bangpan, Niza, MacKintosh & Sinclai (2010) បានបង្ហាញថា កត្តាតម្រូវការការសិក្សានៅមហាវិទ្យាល័យ និងការងាររបស់ពួកគេ គឺជាកត្តានៃការសម្រេចចិត្ត សម្រេចចិត្តជ្រើសរើសមុខវិជ្ជាសិក្សាបានត្រឹមត្រូវ។

**៤.៣.១.២ សំណួរស្រាវជ្រាវទី២**

លទ្ធផលដែលបានរកឃើញលើការសិក្សាស្រាវជ្រាវនេះមានបញ្ហាប្រឈមសំខាន់ៗ ដូចជាប្រព័ន្ធ

ផ្សព្វផ្សាយរបស់សាលារៀន ឥទ្ធិពលគ្រូបង្រៀន ធនធានហិរញ្ញវត្ថុរបស់សាលា កត្តាសេដ្ឋកិច្ចគ្រួសារ ឥទ្ធិពលអាណាព្យាបាលសិស្ស ការរីសអើងពីមជ្ឈដ្ឋានជុំវិញ ឥទ្ធិពលការងារពេលអនាគត។ គោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ(២០១៧-២០២៥) បានបង្ហាញថា បញ្ហាប្រឈមសំខាន់ៗមានដូចជា គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសមិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការទីផ្សារការងារនៅឡើយ ការមិនសូវឲ្យតម្លៃទៅលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការទទួលស្គាល់ពុំទាន់ទូលំទូលាយចំពោះកម្មវិធីអប់រំបច្ចេកទេសឆ្លងប្រព័ន្ធ កម្រិតនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ កង្វះខាតការគាំទ្រទាំងសម្ភារៈសិក្សានិងធនធានថវិកាសម្រាប់សិក្ខាកាមសិស្ស និស្សិត។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ លើប្រធានបទ «**កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តស្វាយរៀង**» ការសិក្សាស្រាវជ្រាវនេះបានផ្តល់ជារបកគំហើញមួយចំនួន ស្តីពី កត្តាជះឥទ្ធិពលលើសិស្សក្នុងការសម្រេចចិត្តជ្រើសរើសជំនាញអប់រំបច្ចេកទេសសម្រាប់សិក្សារៀនសូត្រ។ តាមរយៈលទ្ធផលនៃការស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវអាចសនិដ្ឋានបានថា៖

ចំពោះកត្តាខាងក្នុង ដែលមានឥទ្ធិពលអវិជ្ជមានខ្ពស់ជាងគេទៅលើការសម្រេចចិត្តជ្រើសរើសការអប់រំបច្ចេកទេសគឺកត្តាភេទ ដែលមានការយល់ស្របបួ២% និងយល់ស្របទាំងស្រុង៦%ប៉ុណ្ណោះ ដែលអាចបញ្ជាក់បានថាបញ្ហានៃការរើសអើងភេទនៅតែជាឧបសគ្គសម្រាប់សិស្សស្រីដែលចង់រៀន និងចាប់យកជំនាញអប់រំបច្ចេកទេសនេះ។ ចំពោះកត្តាសមត្ថភាពសិស្សសម្រាប់ចូលរៀនជំនាញអប់រំបច្ចេកទេសនេះ លទ្ធផលបង្ហាញថា មានការយល់ស្រប៣៩% និងយល់ស្របទាំងស្រុង១៥% ដែលបញ្ជាក់បានថាសិស្សចូលរៀនជំនាញនេះមិនដោយសារពួកគេមានចំណេះដឹង និងជំនាញអប់រំបច្ចេកទេសនេះហើយទេ ឬមិនដោយសារតែពួកគេរត់គេចពីសាលាចំណេះទូទៅនោះទេ គឺដោយសារតែពួកគេចង់រៀន ចង់ក្លាយជាអ្នកជំនាញបច្ចេកទេសសម្រាប់អនាគត។ ចំពោះកត្តាតម្រូវការការសិក្សា និងការអប់រំបច្ចេកទេសរបស់សិស្សដែលមានសូចនាករមួយបង្ហាញថា សិស្សរៀនជំនាញអប់រំបច្ចេកទេសមិនមានការចំណាយលើការសិក្សា ដែលមានការយល់ឃើញរវាងសិស្ស និងគ្រូបង្រៀនមានការយល់ស្រប២៧%ប៉ុណ្ណោះ លទ្ធផលនេះអាចបញ្ជាក់បានថា សិស្សដែលរៀនជំនាញអប់រំបច្ចេកទេសគឺត្រូវការថវិកាសម្រាប់ចំណាយលើការសិក្សាជំនាញនេះ និងមានសូចនាករមួយទៀតដែលថាសិស្សរៀនជំនាញនេះបានទទួលសម្ភារ និងប្រាក់ឧបត្ថម្ភពីសាលារៀនមានការយល់ស្រប២៣%ប៉ុណ្ណោះ ដូចនេះ អាចបញ្ជាក់បានថាសិស្សដែលទទួលបានការឧបត្ថម្ភពីសាលារៀននៅមានកម្រិតទាបនៅឡើយ។

ចំពោះកត្តាខាងក្រៅ ដែលមានឥទ្ធិពលអវិជ្ជមានទៅលើការសម្រេចចិត្តជ្រើសរើសការអប់រំបច្ចេក

ទេសគឺកត្តាអាណាព្យាបាលសិស្សដែលលទ្ធផលបង្ហាញថាឪពុកម្តាយចូលចិត្ត និងចង់ឱ្យកូនរៀនជំនាញអប់រំបច្ចេកទេសមានការយល់ស្របទ៤៩%ប៉ុណ្ណោះ ដែលអាបញ្ជាក់បានថាឥទ្ធិពលឪពុកម្តាយនៅតែជាឧបសគ្គសម្រាប់ការសិក្សារបស់កូនៗ។ ចំពោះកត្តាមិត្តភ័ក្ត លទ្ធផលបង្ហាញថាសិស្សដែលចូលរៀនជំនាញអប់រំបច្ចេកទេសតាមមិត្តភ័ក្តមានការយល់ស្របទ២៦%ប៉ុណ្ណោះ ដូចនេះមានន័យថាសិស្សដែលចូលរៀនការអប់រំបច្ចេកទេសតាមមិត្តភ័ក្ត ឬមិត្តភ័ក្តណែនាំឱ្យរៀននៅមានកម្រិតទាប។

## ៥.២.សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវដោយផ្ទាល់នៅវិទ្យាល័យចំណេះទូទៅនិងអប់រំបច្ចេកទេសបារិត នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង និងការសិក្សាស្រាវជ្រាវទិន្នន័យដែលមានស្រាប់នៅវិទ្យាល័យនេះបានបង្ហាញឱ្យឃើញថា ភាពខ្វះខាតនៃការផ្សព្វផ្សាយជ្រើសរើសសិស្សចូលរៀន ការទាញចំណាប់អារម្មណ៍សិស្ស និងភាគីពាក់ព័ន្ធនានាមានការផ្លាស់ប្តូរអាកប្បកិរិយាពីអវិជ្ជមាន មកជាវិជ្ជមានវិញនៅមិនទាន់ឆ្លើយតមទៅនឹងតម្រូវការរបស់សាលារៀន និងសង្គមនៅឡើយ។ កត្តានេះមិនអាចអូសបន្លាយក្នុងស្ថានភាពដដែលនេះតទៅទៀតបានទេ បើមិនបានដោះស្រាយទាន់ពេលវេលា នោះនឹងធ្វើឱ្យគុណភាពអប់រំ នៅកម្រិតវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេសក្នុងខេត្តស្វាយរៀងនឹងមិនឆ្លើយតបទៅនឹងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំឡើយ។ ក្នុងន័យនេះ អ្នកសិក្សាស្រាវជ្រាវបានផ្តួចផ្តើមលើកឡើងនូវសំណូមពរ ដល់ក្រសួង មន្ទីរ និងអ្នកពាក់ព័ន្ធដូចខាងក្រោម៖

### ១. គណៈគ្រប់គ្រងសាលារៀន

- សាលាបន្ត និងបង្កើនការរៀបចំផែនការចុះផ្សព្វផ្សាយតាមគ្រប់រូបភាពទៅដល់អ្នកសិក្សា អាណាព្យាបាលសិស្ស សហគមន៍ និងភាគីពាក់ព័ន្ធនានា ឱ្យបានទទួលព័ត៌មាន និងសារប្រយោជន៍ពីការសិក្សាជំនាញអប់រំបច្ចេកទេសនេះ។
